**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

Kingdom of Cambodia
Nation Religion King

Royaume du Cambodge
Nation Religion Roi

**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

---

**អង្គជំនុំជម្រះសាលាដំបូង**

Trial Chamber
Chambre de Premiere instance

# <u>កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី</u>

# <u>ជំនុំជម្រះក្តីនៅដំណាក់កាលដំបូង</u>

**<u>សាធារណៈ</u>**

សំណុំរឿងលេខ ០០២/១៩-០៩-២០០៧/អវតក/អជសដ

**ថ្ងៃទី០៦ ខែឧសភា ឆ្នាំ២០១៣**

**ម៉ោង ០៩: ០៣នាទី**

**សវនាការលើកទី១៧៦**

**ចៅក្រមសាលាដំបូង៖**

ចៅក្រម និល ណុន ជាប្រធាន

ចៅក្រម ស៊ីលវៀ ខាតរ៉ាយថ៍ *(Judge Silvia CARTWRIGHT)*

ចៅក្រម យ៉ា សុខន

ចៅក្រម ហ្សង់ម៉ាក ឡាវ៉ែន៍ *(Judge Jean-Marc LAVERGNE)*

ចៅក្រម យូរ ឧត្តរា

ចៅក្រម ធូ មណី (បម្រុង)

ចៅក្រម ក្លូឌា ហ្វេនស៍ (បម្រុង) *(Judge Claudia FENZ)*

**ក្រឡាបញ្ជីសាលាដំបូង៖**

លោក ដាវ អានសាន

លោក ឌុច ផារី

លោក ហ្វីលីព រ៉ូជើ *(Mr. Roger Phillips)*

**ការិយាល័យសហព្រះរាជអាជ្ញា៖**

លោក វេង ហ៊ត់

លោក ឃីត រេយន័រ *(Mr. RAYNOR Keith)*

លោក អាប់ឌុលហ្វាក់ ថារីក *(Mr. Tarik Abdulhak)*

**ជនជាប់ចោទ៖**

លោក នួន ជា

លោក ខៀវ សំផន

**មេធាវីការពារជនជាប់ចោទ នួន ជា៖**

លោក សុន អរុណ

លោក វ៉ិចទ័រ កូប៉េ *(Mr.Victor KOPPE)*

**មេធាវីការពារជនជាប់ចោទ ខៀវ សំផន៖**

លោក គង់ សំអុន

កញ្ញា អង់តា ហ្គីសសេ *(Ms. Anta GUISSE)*

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

លោក ពេជ អង្គ

លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត

*(Ms. Elisabeth SIMONNEAU-FORT)*

លោកស្រី ទី ស្រីនណា

លោក សំ សុគង់

លោកស្រី ម៉ុច សុវណ្ណារី

លោកស្រី គ្រីស្ទីន ម៉ាទីណូ

*(Ms. Christine MARTINEAU)*

**ផ្នែកគ្រប់គ្រងតុលាការ៖**

លោក អ៊ុច អរុណ

លោកស្រី សួ សុទ្ធាវី

ប្រតិចារឹកដែលត្រូវបានកែតម្រូវ។ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។

**បញ្ជីឈ្មោះអ្នកនិយាយ៖**

ភាសាដែលបានប្រើ លើកលែងតែមានការបញ្ជាក់ផ្សេងទៀតនៅក្នុងប្រតិចារឹក

| អ្នកនិយាយ | ភាសា |
|---|---|
| ចៅក្រម និល ណុន (ប្រធានអង្គជំនុំ) | ខ្មែរ |
| ចៅក្រម ស៊ីលវៀ ខាតវ៉ាយថ៍ | អង់គ្លេស |
| ចៅក្រម ហ្សង់ម៉ាក ឡាវែន៍ | បារាំង |
| លោក រ៉ិចឆ័រ កូប៉េ | អង់គ្លេស |
| លោក ហ្វីលីព ស្មូត (TCE-65) | អង់គ្លេស-បារាំង |

## ឧបសម្ព័ន្ធ

**ការសួរសំណួរទៅសាក្សី៖ លោក ហ៊ីលីព ស្បេត** (TCE-65)


សួរដោយប្រធានអង្គជំនុំ ផ្តើមពី ........ ទំព័រ ២

សួរដោយចៅក្រម ស៊ីលវៀ ខាតវ៉ាយថ៍ ផ្តើមពី ........ ទំព័រ ៧

សួរដោយចៅក្រម ហ្សង់ម៉ាក ឡាវែន៍ ផ្តើមពី ........ ទំព័រ ៦៥


ប្រតិចារឹកដែលត្រូវបានកែតម្រូវ។ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។

# កិច្ចដំណើរការនីតិវិធី

*(ចៅក្រមចូលក្នុងបន្ទប់សវនាការ)*

[០៩:០៣:១៨]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ នៅក្នុងសប្ដាហ៍នេះ តាមការបរិច្ឆេទដែលបានកំណត់ទុក អង្គជំនុំជម្រះសាលាដំបូងធ្វើសវនាការស្ដាប់សក្ខីកម្មសាក្សី -- សក្ខីកម្មអ្នកជំនាញឈ្មោះ ហ្វីលីព ស្បូត ដែលមានរយៈពេល៤ថ្ងៃ គឺចាប់ពីថ្ងៃនេះទី០៦ ខែឧសភា រហូតដល់ថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០១៣ ដោយអង្គ -- ចៅក្រមនៃអង្គជំនុំជម្រះសាលាដំបូងមានរយៈពេល១ថ្ងៃក្នុងការសួរ។ សហព្រះរាជអាជ្ញារួមនឹងសហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណីមានរយៈពេល១ថ្ងៃកន្លះ។ ក្រុមមេធាវីការពារក្ដីពីរក្រុមមានរយៈពេល១ថ្ងៃកន្លះដូចគ្នា ជាមួយនឹងសហព្រះរាជអាជ្ញានិងសហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណីដែរ។ ហើយអង្គជំនុំជម្រះក៏សូមរំឭកដល់ភាគីអំពីសេចក្ដីសម្រេចមុខៗរបស់អង្គជំនុំជម្រះ អនុស្សរណៈចុះថ្ងៃទី០៨ ខែមករា ឆ្នាំ២០១៣, ឯកសារ E236/4, អ្នកជំនាញ ហ្វីលីព ស្បូត អាចនឹងត្រូវបានតាំងសំណួរអំពីបញ្ហាទាំងឡាយ ដែលគាត់មានសមត្ថភាពអាចផ្ដល់សក្ខីកម្មក្នុងវិសាលភាពនៃដីកាដំណោះស្រាយក្នុងសំណុំរឿង០០២ ឯកសារ E174/24។

ថ្វីត្បិតបើអង្គជំនុំជម្រះសាលាដំបូងបានលើកទឹកចិត្តឱ្យភាគីផ្ដោតនូវសំណួរពាក់ព័ន្ធ និងវិសាលភាពនៃការជំនុំជម្រះដែលត្រូវបំបែកសាជាថ្មីនៅសំណុំរឿង០០២ បន្ទាប់ពីមានសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូលចុះថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០១៣, ឯកសារ E284។

ដូច្នេះគឺវិសាលភាពគឺអង្គជំនុំបើកទូលំទូលាយនៅក្នុងវិសាលភាពនៃសំណុំរឿង០០២ ក៏ពិតមែន ប៉ុន្តែអង្គជំនុំជម្រះលើកទឹកចិត្តដល់ភាគីនៅក្នុងការសង្កត់ធ្ងន់ ឬក៏ផ្ដោតការយកចិត្តទុកដាក់នៅសំណួរទាំងឡាយដែលពាក់ព័ន្ធនៅក្នុងវិសាលភាពនៃសំណុំរឿងដែលបានបំបែកមកធ្វើការនៅដំណាក់កាលដំបូងនេះ គឺសំណុំរឿង០០២/០១។

ក្រឡាបញ្ជីលោក អានសាន ឡើងរាយការណ៍អំពីស្ថានភាពៗវត្តមាន អវត្តមានភាគី និងបុគ្គលដែលអង្គជំនុំជម្រះកោះអញ្ជើញឱ្យចូលរួមនៅក្នុងកិច្ចដំណើរការសវនាការថ្ងៃនេះ។

[០៩:០៦:០០]

**ក្រឡាបញ្ជី៖**

សូមគោរពជម្រាបលោកប្រធាន សម្រាប់សវនាការនៅថ្ងៃនេះ គ្រប់ភាគីទាំងអស់មានវត្តមាន ដោយឡែកលោក នួន ជា មានវត្តមាននៅបន្ទប់ខាង -- ឃុំខ្លួនខាងក្រោមបន្ទប់សាលសវនាការតាម សេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ដោយមូលហេតុបញ្ហាសុខភាព។

អ្នកជំនាញដែលនឹងមកផ្តល់សក្ខីកម្មនៅថ្ងៃនេះ ដែលមានរហស្សនាម TCE-65 លោក ហ្វីលីព ស្សូត។ តាមសមត្ថភាពដែលគាត់អាចដឹងបាន គឺគាត់បានបញ្ជាក់ថា គាត់មិនមានជាប់ចំណងញាតិ លោហិត ឬញាតិពន្ធជាមួយនឹងជនជាប់ចោទទាំងពីរគឺលោក នួន ជា និងលោក ខៀវ សំផន ឬភាគីដើម បណ្តឹងរដ្ឋប្បវេណីណាមួយដែលត្រូវបានទទួលស្គាល់នៅក្នុងរឿងក្តីនេះនោះទេ។ អ្នកជំនាញរូបនេះនឹង ធ្វើសម្បថនៅចំពោះមុខអង្គជំនុំជម្រះ។ ហើយលោកត្រៀមខ្លួនជាស្រេចនៅក្នុងបន្ទប់រង់ចាំខាងក្រៅ រង់ចាំការកោះហៅពីអង្គជំនុំជម្រះ។ សូមអរគុណលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

អរគុណលោក ដាវ អានសាន។

មន្ត្រីរដ្ឋបាលតុលាការ អញ្ជើញលោក ហ្វីលីព ស្សូត ចូលមកកាន់កន្លែងផ្តល់សក្ខីកម្មនៅក្នុង បន្ទប់សវនាការ!

*(អ្នកជំនាញចូលក្នុងបន្ទប់សវនាការ)*

[០៩:០៨:០៤]

**ការតាំងសំណួរដោយចៅក្រម**

**សួរដោយប្រធានអង្គជំនុំ៖**

**ស៖** សួស្តីលោក ហ្វីលីព ស្សូត! តើលោកឈ្មោះ ហ្វីលីព ស្សូត អ៊ីចឹងពិតមែនដែរទេ?

**លោក ហ្វីលីព ស្សូត៖**

**ឆ៖** បាទ ខ្ញុំឈ្មោះ ហ្វីលីព ស្សូត។

**ស៖** បាទ អរគុណ។ ហើយលោក ហ្វីលីព ស្សូត លោកមានអាយុប៉ុន្មាន?

**ឆ៖** ខ្ញុំអាយុ៦៨ឆ្នាំ។

**សៈ** បាទ អរគុណ។ ហើយលោក ហ្វីលីព ស្សូត តើលោកមានសញ្ជាតិអ្វីដែរ?

**ឆៈ** ខ្ញុំជនជាតិអង់គ្លេស។

**សៈ** បាទ អរគុណ។ ហើយតើទីលំនៅបច្ចុប្បន្នរបស់លោក លោករស់នៅទីកន្លែងណា?

**ឆៈ** ខ្ញុំរស់នៅក្នុងប្រទេសបារាំង នៅក្នុងកន្លែងមួយឈ្មោះ ឡាំហ្កាត ជា-- ឡឺហ្កាត ហ្វ្រេណោត ប្រទេសបារាំង។

**សៈ** បាទ អរគុណ។ ហើយតើសព្វថ្ងៃនេះ លោកប្រកបមុខរបរអ្វីដែរ?

**ឆៈ** ខ្ញុំជាអ្នកនិពន្ធប្រវត្តិសាស្ត្រ ហើយនិងសរសេរប្រវត្តិរូបរបស់បុគ្គលផ្សេងៗផងដែរ។

**សៈ** បាទ អរគុណ។ ហើយតាមរបាយការណ៍របស់ក្រឡាបញ្ជីសវនាការអម្បាញ់មិញនេះថា តាមសមត្ថភាពដែលលោកអាចដឹង គឺលោកមិនមានចំណងញាតិលោហិត ឬក៏ញាតិពន្ធជាមួយនឹងភាគីនៃរឿងក្តីនេះទេ គឺជាមួយនឹងភាគីដើមបណ្តឹងរដ្ឋប្បវេណី ហើយនិងជនជាប់ចោទពីររូប គឺលោក នួន ជា និងលោក ខៀវ សំផន។ តើពិតមែនដែរឬទេ?

[០៩:០៩:៥៧]

**ឆៈ** បាទ ត្រឹមត្រូវហើយលោកប្រធាន ខ្ញុំមិនមានទំនាក់ទំនងសាច់ញាតិអ្វីជាមួយលោក ខៀវ សំផន, លោក នួន ជា ឬក៏ភាគីដើមបណ្តឹងរដ្ឋប្បវេណីណានោះទេ។

**សៈ** បាទ អរគុណ។ ហើយលោក ហ្វីលីព ស្សូត ផ្អែកតាមវិធាន៣១ អនុវិធាន២ នៃវិធានផ្ទៃក្នុងនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា លោកក្នុងនាមជាអ្នកជំនាញដែលត្រូវផ្តល់សក្ខីកម្មចំពោះមុខអង្គជំនុំជម្រះនាពេលនេះ អង្គជំនុំជម្រះតម្រូវឲ្យលោកធ្វើសម្បថ ឬធ្វើសច្ចាប្រណិធានជាមុនសិន មុននឹងផ្តល់សក្ខីកម្ម តើលោកយល់ព្រមដែរទេ?

**ឆៈ** បាទ ខ្ញុំនឹងធ្វើបែបនោះ។

**ប្រធានអង្គជំនុំ៖**

លោក ក្រឡាបញ្ជីអន្តរជាតិ លោក រ៉ូជ្ជី រៀបចំនីតិវិធីធ្វើសម្បថចំពោះលោក ហ្វីលីព ស្សូត នៅចំពោះមុខអង្គជំនុំជម្រះនេះ។

**ក្រឡាបញ្ជី៖**

លោក ស្មូត សូមលោកអានតាមខ្ញុំ: ខ្ញុំសូមស្បថជាឱឡារិកថា ខ្ញុំនឹងជួយដល់អង្គជំនុំជម្រះដោយស្មោះត្រង់អស់ពីសមត្ថភាព និងអស់ពីសមត្ថភាព។

[០៩:១១:១០]

**លោក ហ្វីលីព ស្មូត៖**

ខ្ញុំសូមស្បថថា ខ្ញុំនឹងជួយដល់អង្គជំនុំជម្រះដោយស្មោះត្រង់ ដោយរក្សាការសម្ងាត់ និងអស់ពីសមត្ថភាពរបស់ខ្ញុំ។ សូមអរគុណ។

**សួរដោយប្រធានអង្គជំនុំ៖**

បាទ អរគុណលោក ហ្វីលីព ស្មូត ហើយឥឡូវនេះលោកបានធ្វើសម្បថនៅចំពោះមុខអង្គជំនុំជម្រះរួចហើយ ហើយអង្គជំនុំជម្រះសាលាដំបូងមានសំណួរមួយចំនួនពាក់ព័ន្ធនឹងលោក ក្នុងនាមលោកជាអ្នកជំនាញ។

**ស៖** លោក ហ្វីលីព ស្មូត តើលោកអាចប្រាប់អំពីជីវប្រវត្តិរបស់លោក ប្រវត្តិសិក្សារបស់លោកនៅកម្រិតថ្នាក់មហាវិទ្យាល័យជូនដល់អង្គសវនាការបានដែរឬទេ?

[០៩:១១:៤៦]

**លោក ហ្វីលីព ស្មូត៖**

**ឆ៖** បាទ ខ្ញុំទទួលការអប់រំនៅសាលាសាធារណៈនៅប្រទេសអង់គ្លេស ហើយបន្ទាប់មកនៅសាកលវិទ្យាល័យខេមប្រ៊ីជ ដែលខ្ញុំបានសិក្សា ធម្មជាតិវិទ្យា ហើយនិងអក្សរសាស្ត្រភាសាអង់គ្លេស។

**ស៖** បាទ អរគុណ។ ហើយតាមឯកសារ គឺអង្គជំនុំជម្រះកត់សម្គាល់ឃើញថា លោកបានធ្លាប់ធ្វើជាអ្នកសារព័ត៌មានឯករាជ្យសម្រាប់សាជីវកម្មផ្សព្វផ្សាយអង់គ្លេស ប៊ី.ប៊ី.ស៊ី និងជាអ្នកឆ្លើយឆ្លងព័ត៌មានបរទេសប្រចាំនៅទីក្រុងមួយចំនួនដូចជាទីក្រុងម៉ូស្គូ, ទីក្រុងប៉េកាំង, ទីក្រុងប៉ារីស, ទីក្រុងតូក្យូ និងទីក្រុងវ៉ាស៊ីនតោន តើពិតមែនដែរទេ?

**ឆ៖** បាទ ពិតដូច្នោះមែន។ ក្នុងជីវិតភាគច្រើនរបស់ខ្ញុំធ្វើការឲ្យ ប៊ី.ប៊ី.ស៊ី ជាអ្នកឆ្លើយឆ្លងព័ត៌មានអន្តរជាតិ។ នៅក្នុងពេលនោះដែរ ខ្ញុំបានសរសេរសៀវភៅអំពីមេដឹកនាំនយោបាយ អំពីប្រទេសនានា ដូចជាសហភាពសូវៀត ហើយខ្ញុំក៏បានសរសេរប្រវត្តិរូប ហើយនិងប្រវត្តិសាស្ត្រចាប់តាំងពីចុងឆ្នាំ១៩៦០មក គឺក្នុងរយៈពេល៤៥ឆ្នាំចុងក្រោយនេះ គឺពីរឆ្នាំ។ បាទ គឺខ្ញុំធ្វើការស្របគ្នា។ មួយគឺជាអ្នក

សារព័ត៌មាន មួយទៀតគឺអាជីពជាអ្នកសរសេរប្រវត្តិសាស្ត្រ ហើយនិងជាអ្នកសរសេរប្រវត្តិរូបឲ្យអ្នកនយោបាយ អ្នកប្រាជ្ញជាដើមបាទ។

[០៩:១៣:៥៥]

**សៈ** បន្ទាប់ពីលោកចូលនិវត្តន៍ពីការងារសារព័ត៌មាន លោកបានធ្វើជាគ្រូបង្រៀន បង្រៀនមុខវិជ្ជាអំពីនយោបាយប្រៀបធៀបនៅសាកលវិទ្យាល័យអាយអូវ៉ា តើពិតអ៊ីចឹងដែរឬទេ?

**ឆៈ** បាទ ត្រឹមត្រូវ។ ខ្ញុំបានចំណាយពេលមួយឆ្នាំជាសាស្ត្រាចារ្យម្តងម្កាលនៅសាកលវិទ្យាល័យអាយអូវ៉ា ពីឆ្នាំ១៩៧៩ ដល់ ១៩៨៨ បាទ។

**សៈ** បាទ អរគុណ។ ហើយក្រោយមកលោកក៏បានប្រកបវិជ្ជាជីវៈជាអ្នកនិពន្ធវិញ ហើយលោកប្រកបរបរវិជ្ជាជីវៈ -- តើលោកប្រកបមុខរបរវិជ្ជាជីវៈជាអ្នកនិពន្ធនេះអស់រយៈពេលប៉ុន្មានឆ្នាំហើយ?

**ឆៈ** ខ្ញុំចាប់ផ្តើមការងារនេះជាអ្នកសរសេរប្រវត្តិរូបហ្នឹងឆ្នាំ១៩៦៨ គឺនៅចុងទសវត្សរ៍ឆ្នាំ៦០ ខ្ញុំបានបោះពុម្ពចេញនៅឆ្នាំ១៩៧៤ ហើយខ្ញុំបានសរសេរសៀវភៅអស់រយៈពេល៤៤ ឬ៤៥ឆ្នាំបាទ។

[០៩:១៥:១៨]

**សៈ** បាទ តាមស្នាដៃរបស់លោក លោកធ្លាប់បានសរសេរសៀវភៅអំពីជីវប្រវត្តិរបស់បុគ្គលសំខាន់ៗមួយចំនួន ហើយនៅក្នុងក៏មានសរសេរអំពីជីវប្រវត្តិរបស់មេដឹកនាំក្នុងរបបកម្ពុជាប្រជាធិបតេយ្យផងដែរ។ ហេតុអ្វីបានជាលោកមានការចាប់អារម្មណ៍ និងសរសេរអំពីជីវប្រវត្តិរបស់មេដឹកនាំក្នុងរបបកម្ពុជាប្រជាធិបតេយ្យ?

**ឆៈ** ខ្ញុំបានធ្វើការជាអ្នកសារព័ត៌មាន ហើយឆ្លើយឆ្លងព័ត៌មានអន្តរជាតិ នៅទីក្រុងប៉េកាំង ក្នុងទសវត្សរ៍ឆ្នាំ១៩៧០ ហើយបន្ទាប់មកនៅពេលដែលខ្ញុំនៅក្រុងប៉េកាំងនោះ ខ្ញុំបានដឹងអំពីកម្ពុជាប្រជាធិបតេយ្យ ហើយដឹងពីការទូតរបស់គេ គឺ ពេជ ចាន់ *(តាមសូរស័ព្ទ)* ហើយខ្ញុំក៏បានចាប់អារម្មណ៍ក្នុងការ -- អ្វីដែលបានកើតឡើងនៅក្នុងកម្ពុជាប្រជាធិបតេយ្យនៅកម្ពុជាកាលនោះ។នៅខែកញ្ញាឆ្នាំ១៩៧៧ ប៉ុល ពត ហើយនិង អៀង សារី, វន វ៉េត ផងដែរ ជួន ជឿន មួយទៀតបានធ្វើទស្សនកិច្ចទីក្រុងប៉េកាំង គឺជាទស្សនកិច្ចទី១ ហើយផ្លូវការតែមួយគត់នៅបរទេសរបស់កម្ពុជាប្រជាធិបតេយ្យ ហើយខ្ញុំបាននៅជាមួយ នៅទីនោះរហូតដល់ពេលពួកគេចាកចេញពីទីនោះ។ ពេលនោះហើយដែលខ្ញុំចាប់អារម្មណ៍

ខ្លាំងអំពីអ្វីដែលបានកើតឡើងនៅប្រទេសកម្ពុជានៅកាលនោះ ប៉ុន្តែការប្រឹងប្រែងរបស់ខ្ញុំនៅពេលនោះ ដើម្បីទទួលបានវីសា ពីលោក ពេជ ឈាង *(តាមសូរស័ព្ទ)* នៅកាលនោះ គឺមិនទទួលបានការជោគជ័យ ដើម្បីមកទស្សនកិច្ចប្រទេសកម្ពុជាទេ នៅក្នុងអំឡុងឆ្នាំទាំងនោះ នោះ។

[០៩:១៧:១៥]

**ស៖** អរគុណ។ ហើយតើលោកធ្លាប់បានសិក្សាអំពីប្រវត្តិសាស្ត្ររបស់ប្រទេសកម្ពុជាដែរឬទេ ហើយជាពិសេសគឺទាក់ទងទៅនឹងប្រវត្តិសាស្ត្រនៃរបបកម្ពុជាប្រជាធិបតេយ្យ?

**ឆ៖** បាទ ខ្ញុំបានចាប់ផ្ដើមសិក្សាយ៉ាងហ្មត់ចត់អំពីកម្ពុជាប្រជាធិបតេយ្យនោះ។ ពេលដែលខ្ញុំសម្រេចចិត្ត ជីវប្រវត្តិ -- ពេលដែលខ្ញុំចង់ចាប់ផ្ដើមសរសេរជីវប្រវត្តិរបស់ ប៉ុល ពត បន្ទាប់មកគឺប្រវត្តិជីវប្រវត្តិដែលខ្ញុំបានសរសេរលោកប្រធាន ម៉ៅ អំពីមេដឹកនាំចិន។ បន្ទាប់ពី ម៉ៅ មក ហើយខ្ញុំចោទជាបញ្ហា តើខ្ញុំត្រូវសរសេរអ្នកណាទៀត ហើយខ្ញុំយល់ឃើញថា ដល់ពេលសមស្របដើម្បីសរសេរពីជីវប្រវត្តិរបស់ ប៉ុល ពត។ ហើយខ្ញុំគ្រាន់តែបន្ថែមអំពីជីវប្រវត្តិនេះ គឺសៀវភៅនីមួយៗត្រូវប្រើពេលពី ៥ឆ្នាំ ទៅ៦ឆ្នាំ ដើម្បីសិក្សាស្រាវជ្រាវ និងសរសេរ។ ដូច្នេះគឺជាការងាររយៈពេលវែងណាស់ក្នុងការសរសេរបែបនេះបាទ។

[០៩:១៨:២៨]

**ស៖** បាទ អរគុណណាស់ ហើយតើលោកបានសរសេរសៀវភៅអ្វីខ្លះអំពីរបបកម្ពុជាប្រជា-ធិបតេយ្យ?

**ឆ៖** ខ្ញុំបានសរសេរសៀវភៅមួយ ជីវប្រវត្តិរបស់ ប៉ុល ពត ដែលមានចំណងជើងថា "ប្រវត្តិនៃសុបិនអាក្រក់" បោះពុម្ពនៅក្នុងឆ្នាំ២០០៤ នៅចក្រភពអង់គ្លេស ហើយនៅក្នុងសហរដ្ឋអាមេរិកផងដែរបាទ។

**ស៖** នៅក្នុងការសិក្សាស្វែងយល់អំពីកម្ពុជាប្រជាធិតេយ្យ តើលោកមានឱកាសណាមួយដែលបានជួបផ្ទាល់ជាមួយនឹង -- ធ្វើសម្ភាសជាមួយនឹង ប៉ុល ពត ដែរឬទេ?

**ឆ៖** ខ្ញុំមិនបានសម្ភាសជាមួយ ប៉ុល ពត ទេ ពីព្រោះនៅកាលនោះ នៅពេលដែលខ្ញុំចាប់ផ្ដើមសរសេរសៀវភៅរបស់ខ្ញុំ ខ្ញុំចាប់ផ្ដើមធ្វើការនៅចុងឆ្នាំ១៩៧៩ -- បាទ នៅដើមឆ្នាំ១៩៧៩ -- បាទ ១៩៩៩ បានដូច្នេះហើយបន្ទាប់មក គឺយើងគិតថា គាត់បានខូចមុនពេលនោះទៅហើយ។

**ស៖** បាទ អរគុណ។ ហើយតើលោកធ្លាប់ធ្វើដំណើរចូលមកប្រទេសកម្ពុជានៅក្នុងរបប -- អំឡុងពេលរបបកម្ពុជាប្រជាធិបតេយ្យដែរឬទេ?

**ឆ៖** ខ្ញុំមិនបានទេ។ ដោយខ្ញុំបានជម្រាប ខ្ញុំមិនអាចបានទទួលវីសា ដើម្បីចូលរួម អ៎! ដើម្បីទស្សនៈកម្ពុជាប្រជាធិបតេយ្យទេ នៅពេលដែលគេកាន់អំណាចនោះ បាទ។

[០៩:២០:៣៨]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។

តើអស់លោក អស់លោកស្រីចៅក្រម មានសំណួរអ្វីត្រូវសួរដល់អ្នកជំនាញរូបនេះទេ?

សូមអញ្ជើញចៅក្រម ស៊ីវៀល ខាតវ៉ាយថ៍!

**ចៅក្រម ស៊ីលវៀ ខាតវ៉ាយថ៍៖**

សូមអរគុណលោកប្រធាន។

**សួរដោយចៅក្រម ស៊ីលវៀ ខាតវ៉ាយថ៍៖**

**ស៖** សូមអរគុណលោក ស្សូត ដែលលោកបានអញ្ជើញមកបំភ្លឺដល់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ហើយពិភាក្សាអំពីសៀវភៅរបស់ "ជីវប្រវត្តិ ប៉ុល ពត : សុបិនអាក្រក់" គឺឯកសារ E3/9។ ដើម្បីជូនជាព័ត៌មានដល់លោក សៀវភៅនេះ គឺដាក់ចូលនៅក្នុងភាសា -- សំណុំរឿងមានជាភាសាបារាំង និងអង់គ្លេស តែប៉ុណ្ណោះ ហើយមិនទាន់មានបកប្រែជាភាសាខ្មែរជាផ្លូវការទេ។ ហើយខ្ញុំនឹងពិភាក្សាជាមួយលោក។ ខ្ញុំនឹងយោងទៅរកទំព័រជាភាសាអង់គ្លេសតែប៉ុណ្ណោះ។ម្តងម្កាល ខ្ញុំនឹងអាន និងចំណុច ឬសរសេរដកស្រង់វែងតាមរយៈប្រព័ន្ធអេឡិចត្រូនិក។ ដូច្នេះ សូមលោកជ្រាប។

[០៩:២១:៥៥]

ដើម្បីត្រឡប់ដោយសង្ខេបទៅរកគុណវុឌ្ឍិ ហើយនិងបទពិសោធន៍របស់លោក ដែលលោកប្រធានបានសួរលោកមួយចំនួនហើយនោះ។ ខ្ញុំបញ្ជាក់ឲ្យច្បាស់ថា នៅពេលដែលលោកតាមរឿងរ៉ាវរបស់ ប៉ុល ពត ក្នុងទីក្រុងប៉េកាំង ជាអគ្គរដ្ឋទូតរបស់គេនោះ ថាតើលោកមានឱកាសជាមួយគាត់ ឬក៏ជជែក ឬក៏សម្ភាសជាមួយគាត់ផ្ទាល់ដែរឬទេ នៅកាលនោះក្នុងឆ្នាំ១៩៧៧នោះ?

**លោក ហ្វីលីព ស្សូត៖**

**ឆ៖** ត្រឹមត្រូវ។

**ស៖** អរគុណ។ ឥឡូវនេះ នៅក្នុងសៀវភៅរបស់លោក លោកបានបញ្ជាក់ថា ការសម្ភាសជាមួយលោក ខៀវ សំផន ហើយនិងលោក អៀង សារី។ តើលោកធ្លាប់បានសម្ភាសជាមួយលោក នួន ជា ទេ?

**ឆ៖** ទេ ខ្ញុំមិនបានសម្ភាសជាមួយលោក នួន ជា ទេ។

[០៩:២៣:០១]

**ស៖** អរគុណ។ រីឯការសម្ភាសជាមួយលោក ខៀវ សំផន ជាសម្ភាសតែម្តង ឬក៏សម្ភាសនៅប្រើរយៈពេលសប្តាហ៍ ឬ១ខែ ឬច្រើនខែ ដើម្បីបានព័ត៌មានគ្រប់គ្រាន់? សូមលោកជម្រាបតុលាការ។

**ឆ៖** ខ្ញុំបានទៅប៉ៃលិន ខ្ញុំគិតថា ប្រាំ ឬប្រាំមួយដង ក្នុងរយៈកាលប្រហែលជា១៨ខែ។ នៅពេលម្តងៗដែលខ្ញុំបានទៅនោះ ខ្ញុំបានបញ្ជូនពាក្យទៅឲ្យលោក ខៀវ សំផន ថាខ្ញុំចង់ជួបលោក។ ទាំងប្រាំមួយដងនោះ ខ្ញុំបានទទួលចម្លើយថា គាត់នឹងយល់ស្រប។ ខ្ញុំពន្យល់ថា ខ្ញុំចង់សម្ភាសគាត់អំពីការសរសេរអំពីកម្ពុជាប្រជាធិបតេយ្យ ជាប្រវត្តិរូប។ ហើយខ្ញុំក៏ ខ្ញុំអាចនឹងមើលឯកសារ ដើម្បីផ្តល់ជូនលោកស្រីចៅក្រម អំពីកាលបរិច្ឆេទ ប្រហែលជាប្រាំ ឬប្រាំមួយដង ដែលខ្ញុំបានជួបគាត់។ ហើយប្រហែលប្រាំដងក្នុងថ្ងៃបន្តបន្ទាប់។ ហើយមួយទៀត ជាទស្សនកិច្ចម្តងទៀត ទៅប៉ៃលិន។

[០៩:២៤:២៩]

**ស៖** ដូច្នេះ លោកមានឱកាសទូលំទូលាយ ដើម្បីពិភាក្សាជាមួយគាត់អំពីត្រៀមរៀបចំអំពីការសរសេរប្រវត្តិរូប ប៉ុល ពត នៅក្នុងការសម្ភាសទាំងនោះ។ តើលោកបានដឹងអំពីលោក ខៀវ សំផន អំពីតួនាទីរបស់គាត់នៅក្នុងកម្ពុជាប្រជាធិបតេយ្យក្នុងរដ្ឋាភិបាលរបស់គេដែរឬទេ ក្នុងការសម្ភាសទាំងនោះ?

**ឆ៖** យើងបានពិភ្សាជាច្រើនអំពីសម័យកាលពីមុនៗ។ ពេលដែលខ្ញុំថាពីមុនៗនោះ គឺនៅពេលដែលគាត់ធ្វើនៅប៉ារីស ជានិស្សិតនៅឡើយ។ លោក ខៀវ សំផន មានបទពិសោធន៍ក្នុងឆ្នាំ១៩៦០ នៅពេលដែលគាត់ត្រឡប់មកប្រទេសកម្ពុជាវិញ។ ហើយនិងកាសែតដែលគាត់បានបោះពុម្ពផ្សាយនោះ គឺឡូបស៊ែវ៉ាទ័រ។ យើងបានជជែកអំពីសម័យកាលដែលគាត់នៅរៀនដែលគាត់នៅរៀនសាលាជាមួយប៉ុល ពត នោះនៅខេត្តកំពង់ចាម។

[០៩:២៥:៤៥]

ប្រតិចារិកដែលត្រូវបានកែតម្រូវ។ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារិកក្នុងភាសាទាំងបី។

យើងបានពិភាក្សាមួយចំនួនអំពីសម័យកាលកម្ពុជាប្រជាធិបតេយ្យ។ ប៉ុន្តែខ្ញុំគិតថា នេះជាមតិទូទៅអំពីមេដឹកនាំជាផ្លូវការគឺ -- ហើយនិងជាមួយលោក អៀង សារី ដូច្នោះដែរ ពួកគាត់មានការរីករាយក្នុងការនិយាយអំពីកាលពីគាត់នៅក្មេងៗនៅសាលា។ ប៉ុន្តែមានការអល់អែកបន្តិចបន្តួចនៅពេលដែលគាត់ជជែកអំពីកម្ពុជាប្រជាធិបតេយ្យ។ ចំពោះខ្ញុំជាអ្នកប្រវត្តិវិទូ ឆ្នាំដែលនៅក្មេងៗនោះ ដែលនៅវ័យកុមារនោះ ក៏ខ្ញុំយល់ថាចាប់អារម្មណ៍ផងដែរ។ នៅក្នុងការសម្ភាសបែបនោះនៅពេលដែលយើងដឹងអំពីមូលហេតុថាអ្វីបានបុគ្គលម្នាក់មានការវិវឌ្ឍពីយុវវ័យរហូតដល់ពេញវ័យ យើងនឹងទាញយកការចាប់អារម្មណ៍ ហើយនិងចូលទៅដល់កិច្ចការ និងការសិក្សាដែលគេចេញក្រោយមកនោះ។

**ស៖** បន្ទាប់ពីសៀវភៅរបស់លោកអំពីប៉ុល ពត ត្រូវបានបោះពុម្ពមក ហើយលោកខៀវ សំផនបានបោះពុម្ពអំពីប្រវត្តិមួយរបស់គាត់។ គាត់ថា ប្រវត្តិសាស្ត្រកម្ពុជាថ្មីៗនេះ មូលហេតុដែលខ្ញុំសម្រេចនោះ ឯកសារ E3/18 ដែលបោះពុម្ពនៅចុងឆ្នាំ២០០៣។ តើលោកបានអានសៀវភៅរបស់គាត់នោះដែរឬទេ លោក ហ្វីលីព ស្បូត?

**ឆ៖** បាទ ខ្ញុំបានអាន។

[០៩:២៧:៣៨]

**ស៖** តើលោកបានដឹងដែរឬទេ ជាទូទៅថាបានដឹងអ្វីច្រើនអំពីការអានសៀវភៅផ្ទាល់របស់គាត់នោះ គឺតើដែលសម្ភាសផ្ទាល់ជាមួយគាត់ហ្នឹងដឹងរឿងច្រើន ឬក៏ក្នុងសៀវភៅហ្នឹងលោកដឹងរឿងច្រើនជាងបាទ?

**ឆ៖** យើងបាននិយាយអំពីសៀវភៅដែលខ្ញុំបានសរសេរ ១០ឆ្នាំកន្លងមកហើយ។ ខ្ញុំគិតថាមិនដូច្នោះទេ។ នៅពេលដែលដឹងអំពីសៀវភៅរបស់គាត់នោះ ហើយតាមពិតអំពីផ្នែកខ្លះនៃការសម្ភាសរបស់ខ្ញុំជាមួយលោក ខៀវ សំផន នោះ គឺវាមានលក្ខណៈពីរបៀបដែរអ្វីដែលគាត់ចង់យល់ឃើញទស្សនៈរបស់គាត់ក្នុងសម័យនោះ។ បាទ គឺជាពិសេស គឺមិនទាក់ទងទៅនឹងអង្គហេតុពិតនៅក្នុងសម័យនោះទេ។ ដូច្នោះគឺជាការពិតហើយដែលបុគ្គលម្នាក់ដែលចាត់ទុកសម័យមួយបែបនេះ។

**ស៖** តើត្រឹមត្រូវដែរឬទេ បើយើងនិយាយថាសៀវភៅរបស់គាត់គឺជារបៀបរបស់គាត់ក្នុងការកត់ត្រាផ្នែកតាមទស្សនៈរបស់គាត់សម្រាប់សាធារណៈ ប៉ុន្តែមិននិយាយអំពីសេចក្តីលម្អិតនៃរបបនោះទេ។ ជាពិសេសការពិនិត្យនៅតុលាការជាដើមនោះ។ តើអ៊ីចឹងដែរឬទេ?

**ឆ៖** នេះហើយគឺពិតណាស់។ គាត់បញ្ជាក់ពីទស្សនវិស័យរបស់គាត់ដែលគាត់ចង់បង្ហាញ ចង់ឱ្យគេយល់ដឹងអំពីគាត់។

[០៩:២៩:២៨]

**សៈ** លោក ខៀវ សំផន ក៏បានសរសេរសៀវភៅមួយផងដែរ មិនច្បាស់ថាបោះពុម្ពនៅពេលណាទេ ប៉ុន្តែហៅថា "ការពិចារណាលើប្រវត្តិសាស្ត្រកម្ពុជាពីចំណុចចាប់ផ្ដើមរហូតទៅដល់សម័យកម្ពុជាប្រជាធិបតេយ្យ"។ យើងមានជំពូកទី៥ និយាយអំពីកម្ពុជាប្រជាធិបតេយ្យ, ឯកសារ E3/16 នៅក្នុងសំណុំរឿង។ តើលោកបានអានផ្នែកសៀវភៅហ្នឹងដែរឬទេ ឬក៏លោកបានអានសៀវភៅនោះដែរឬទេ?

**ឆ៖** ខ្ញុំមិនប៉ានឆ្លើយទេដោយហេតុថា ដោយស្មោះត្រង់នោះខ្ញុំមិនច្បាស់ ខ្ញុំដូចជាមិនចាំថាបានអាន បើសិនជាបោះពុម្ពនៅដើមឆ្នាំ២០០០ នៅពេលដែលធ្វើការលើសៀវភៅហ្នឹងខ្ញុំពិតជាបានអាន។ ប៉ុន្តែតាមឮសៀវភៅ និងទម្រង់ដែលលោកស្រីលើកឡើងនេះខ្ញុំដូចសង្ស័យ ខ្ញុំមិនច្បាស់ថាខ្ញុំបានអានទេ។

**សៈ** ដើម្បីឱ្យលោកច្បាស់លោកមិនបានមានឱកាសក្នុងការជួបពិភាក្សាព្រឹត្តិការណ៍ទាក់ទងទៅនឹងកម្ពុជាប្រជាធិបតេយ្យអ្វីជាមួយលោក នួន ជា ទេ។ តើត្រូវអ៊ីចឹងដែរឬទេ?

**ឆ៖** បាទ ត្រឹមត្រូវ។

[០៩:៣០:៥២]

**សៈ** បាទ អរគុណលោក ស្សូត។ ឥឡូវនេះខ្ញុំនឹងចូលទៅដល់ផ្នែកមួយចំនួននៃសៀវភៅរបស់លោក។ ខ្ញុំត្រូវពន្យល់លោក លោក ស្សូត អំពីសៀវភៅរបស់លោកទោះបីជាសៀវភៅរបស់លោកមានព័ត៌មានដ៏សំខាន់ៗ ក៏ប៉ុន្តែយើងមិនអាចលម្អិតទាំងអស់បានទេ។ ចំណុចទី២ យើងមានពេលវេលាមានកំណត់មួយចំនួនទាក់ទងនឹងសម័យកាលដែលយើងយកមកពិចារណាក្នុងបរិបទនៃសវនាការនេះ។ ខ្ញុំនឹងផ្ដោតទៅលើផ្នែកសំខាន់ៗមួយចំនួនហើយសហព្រះរាជអាជ្ញា ភាគីមេធាវីដើមបណ្ដឹងរដ្ឋប្បវេណី មេធាវីការពារក្ដីនឹងសួរចំណុចផ្សេងៗទៀតផងដែរ។

ខ្ញុំចង់ចាប់ផ្ដើមជាដំបូងអំពីការចាប់អារម្មណ៍ អំពីអ្វីដែលលោកបានសរសេរនៅក្នុងរយៈពេល ១៨ខែ -- ១២ខែមុននឹងជម្លៀសទីក្រុងភ្នំពេញដូចជាឆ្នាំ១៩៧៣ នៅពេលដែលលោកនិយាយថា -- ទំព័រអង់គ្លេសនោះគឺ២១៨, អង់គ្លេស ERN 00396418, បារាំង ERN 00639736 ដល់ 737។ ហើយ

យើងមានការកត់សម្គាល់នៅក្នុងសៀវភៅរបស់លោកនោះគឺថា ប៉ុល ពត បានបញ្ជាការវាយប្រហារ វាយលុកចូលទីក្រុងភ្នំពេញ។ ដូច្នេះ តើលោកអាចជម្រាបខ្ញុំ និងតុលាការបន្ថែមទៀតអំពីការវាយសម្រុក នោះទេ តើនៅក្នុងឆ្នាំណា? ខែណាតាមដែលលោកចាំ?

**ឆ៖** សូមអភ័យទោសលោកស្រីចៅក្រមនិយាយថា ទំព័រ២១៨ ខ្ញុំរកមិនឃើញ។

**ស៖** អូ៎! ប្រហែលជាខ្ញុំច្រឡំ ខ្ញុំសូមមើលលេខទំព័រយោងម្តងទៀត។

*(សម្រាករយៈពេលខ្លី)*

[០៩:៣៤:២៥]

**ឆ៖** ខ្ញុំបានរកឃើញទំព័រ២៤៩។

**ស៖** សូមអភ័យទោសខ្ញុំបានបង្ហាញលេខជូនលោកដែលខុសលេខដែលត្រូវគឺទំព័រ២៤៩។ ខ្ញុំចង់ដឹងអំពីលោកថាតើពេលណានៅក្នុងឆ្នាំហ្នឹងដែលថាមានការវាយសម្រុកយកទីក្រុងឬក៏យកភ្នំពេញនោះ?

**ឆ៖** បាទ នៅក្នុងរដូវភ្លៀង និយាយគឺថាតាមន័យយោធានោះ មិនត្រឹមត្រូវតាមន័យហ្នឹងទេ ប៉ុន្តែមូលហេតុគាំទ្រនោះ គឺខ្មែរក្រហម និង ប៉ុល ពត ចង់បង្ហាញឲ្យអ្នកផ្សេងដឹងថា គេអាចយកជ័យជម្នះបានមុនដែរការទម្លាក់គ្រាប់បែករបស់អាមេរិកហ្នឹងបញ្ចប់ទៅ។ បើសិនជាគេអាចយកភ្នំពេញបាន នៅពេលដែលសហរដ្ឋអាមេរិកកំពុងតែទម្លាក់គ្រាប់បែកកម្ពុជានោះ ជាវិធីដែលគេបង្ហាញថាពួកគេបាន ធ្វើឲ្យអាមេរិកាំងទទួលបរាជ័យទាំងមូល។

**ស៖** ដើម្បីបញ្ជាក់ នៅពេលដែល -- តើគាត់យកភ្នំពេញបានវាយប្រហារហ្នឹង ក្នុងពេលដែល អាមេរិកកំពុងតែទម្លាក់គ្រាប់បែកដែរឬទេ?

[០៩:៣៦:០៥]

**ឆ៖** ប្រហែលនៅក្នុងខែសីហា ឆ្នាំ១៩៧៣។

**ស៖** អ្វីដែលលោកបាននិយាយនូវអំពីថាក្នុងរដូវភ្លៀង ដែលមានការវាយប្រហារទីក្រុងភ្នំពេញ ហ្នឹង រឿងអ៊ីចឹងគឺថាការវាយប្រហារនោះ គឺមិនជោគជ័យទេ។ តើអ៊ីចឹងដែរឬទេ?

**ឆ៖** ការវាយប្រហារនោះមិនជោគជ័យទេ។

**ស៖** នៅទំព័របន្ទាប់នោះទៀត គឺបន្ទាប់ពីទំព័រ២៤៩នោះ គឺថា២៥១ ជាឧទាហរណ៍នោះ លោកបានពិភាក្សាអំពីផលវិបាកនៃការវាយប្រហារលើកដំបូងយកភ្នំពេញនោះ។ ខ្ញុំចង់ដឹងអំពីការផ្គត់ផ្គង់សព្វាវុធ គ្រាប់រំសេវទៅឲ្យខាងខ្មែរក្រហម។ តើលោកបានដឹងអ្វីខ្លះ?

**ឆ៖** កម្ពុជា ខ្មែរក្រហមបានទទួលការផ្គត់ផ្គង់ពីវៀតណាមមក ហើយក៏ទទួលពីប្រទេសចិនផងដែរ ប៉ុន្តែអាវុធដែលពួកគេទទួលបាននោះ គេៗទិញមកអំពីទាហាន លន់ នល់ ពីរដ្ឋាភិបាល លន់ នល់ ពីមន្ត្រីពុករលួយរបស់របប លន់ នល់ ផងដែរ។

**ស៖** តាមពិត ខាងវៀតណាមហ្នឹងគឺថាមុនពេលដែលនេះ ពួកវៀតណាមបានកាត់ផ្តាច់អំពីការផ្គត់ផ្គង់សព្វាវុធគ្រាប់រំសេវដល់កម្ពុជា។ នេះហើយដែលបន្ទាប់មកមានការផ្គត់ផ្គង់បន្តមកវិញដែរឬទេ ទៅដល់កងទ័ពកម្ពុជាប្រជាធិបតេយ្យនោះ?

[០៩:៣៨:០៣]

**ឆ៖** បាទ គឺត្រឹមត្រូវ។

**ស៖** ហេតុអ្វីបានជាគេសម្រេចនៅចុងឆ្នាំ១៩៧៣ ដើម្បីផ្តល់អាវុធគ្រាប់រំសេវមកវិញ ម្តងទៀតមកឲ្យខ្មែរក្រហមនោះ?

**ឆ៖** ដោយហេតុថា ពួកគេបានប្រឈមមុខ គឺថា "*ហ្សេដាកកំភ្លី*" គឺថាវៀតណាម គឺថាចង់ឲ្យខ្មែរក្រហមជាសម្ព័ន្ធមិត្តរបស់គេ។ នៅក្នុងឆ្នាំ១៩៧៣ គឺចុងឆ្នាំ៧២ វៀតណាមយល់ឃើញថាខ្មែរក្រហមគឺមានអំណាចគ្រប់គ្រាន់ ហើយនិងគ្រប់គ្រងតំបន់ធំគួរសមនៅទឹកដីកម្ពុជានោះ។ ហើយពួកគេត្រូវធ្វើសេចក្តីសម្រេច ថាតើពួកគេត្រូវបន្តបង្ខំឲ្យខ្មែរក្រហមធ្វើតាមឆន្ទៈរបស់ ហាណូយ ឬក៏ពួកគេត្រូវចាត់ទុកពួកគេជាសម្ព័ន្ធមិត្តដែលថាអាច ដែលនាំឲ្យគេពួកគេជោគជ័យនៅកម្ពុជា ទោះបីវៀតណាមជួយ មិនជួយនោះក្តី នៅក្នុងឆ្នាំ១៩៧៣ ឬពាក់ពាក់កណ្តាលឆ្នាំ៧៣នោះ គេយល់ឃើញថា គេដឹងថាពួកគេត្រូវតែចាត់ទុកខ្មែរក្រហមថាជាសម្ព័ន្ធមិត្ត។ បើសិនថាសមភាគីស្មើគ្នា គឺធ្វើឲ្យគេនឹងអស់ឥទ្ធិពល ប៉ុន្តែគេផ្គត់ផ្គង់ជាអាវុធគ្រាប់រំសេវ។

[០៩:៣៩:៤១]

**ស៖** ទាក់ទងទៅនឹងការបន្តផ្តល់អាវុធមកជាថ្មីនោះ ថាតើខ្មែរក្រហមកាន់តែកាន់អំណាចកាន់តែច្រើន កាន់-- គ្រប់គ្រងទឹកដីកាន់តែច្រើននៅទំព័រ២៥១ ហើយនៅចុងឆ្នាំ១៩៧៣ ខ្មែរក្រហមកាន់កាប់ទឹកដីពីរភាគបីនៃដីកម្ពុជា ហើយនិងប្រជាជនជាងពាក់កណ្តាលឯណោះ។ សូមលោកប្រាប់តុលាការហេតុអ្វីបានជាលោកសម្រេចរកឃើញអ្វីខ្លះ បានកំណត់ថាសម្រាប់គោលបំណងសៀវភៅនេះ ឬក៏បានតួលេខនេះពីលោក ខៀវ សំផន ដែលថាពីរភាគបីនៃទឹកដី ហើយជាងពាក់កណ្តាលនៃប្រជាជនដែលខ្មែរក្រហមបានត្រួតត្រានោះ?

**ឆ៖** អត់ទេ មិនមែនចេញពី ខៀវ សំផន ឬក៏ការសម្ភាសទេ។ វាចេញមកពីឯកសារបណ្ណសារយោធារបស់សហរដ្ឋអាមេរិកដែលគេកត់ត្រាការពិតនៅកម្ពុជា។ ហើយគេធ្វើការវាយតម្លៃថាប្រហែលជាទឹកដីពីរភាគបី ហើយប្រជាជនជាងពាក់កណ្តាល ខ្មែរក្រហមបានកាន់កាប់។

[០៩:៤០:៥៩]

**ស៖** ហើយផលវិបាកនៃការវាយប្រហារដែលមិនជោគជ័យដំបូងនៅទីក្រុងភ្នំពេញនោះ នៅក្នុងចុងឆ្នាំ១៩៧៣ នោះគឺថា ប៉ុល ពត តាមសៀវភៅរបស់លោកដែលបានគាត់ប្តូរទីតាំងកាន់តែកៀកមកភ្នំពេញហើយក្នុងឆ្នាំ៧៣នោះ ហើយគាត់បានប្តូរមន្ទីររបស់គាត់មកជិតភ្នំពេញ ហើយលោកនិយាយថាប្រហែលជា៣០គីឡូម៉ែត្រនៅពាយ័ព្យកម្ពុជានៅផ្លូវឧដុង្គ និងខេត្តពោធិ៍សាត់។

សូមលោកជម្រាបតុលាការ ហើយនិងខ្ញុំអំពីប្រភពព័ត៌មានដែលលោកទទួលបានពីប្រភពរបស់ទាហានអាមេរិកាំង ឬក៏ពីប្រភពអ្វី?

**ឆ៖** តាមអ្វីដែលខ្ញុំចងចាំនោះគឺថា ព័ត៌មានខ្លះដែលខ្ញុំទទួលបាន នី កន ដែលជាប្អូនប្រុសរបស់សុន សេន-- នី កន ហើយខ្ញុំបានធ្វើដំណើរហើយពី -- សួរប្រជាជនដែលបាននៅទីនោះនៅក្នុងសម័យកាលនោះដែលបានចងចាំ ហើយថា ប៉ុល ពត និងមេដឹកនាំផ្សេងៗទៀត ដែលអ្នកខ្លះចាំថា ជួន ជឿន បានបង្កើតមន្ទីរពេទ្យនៅកន្លែងមួយដែលនៅទីបញ្ជាការយោធា ហៅ “វ៉ាស្នាច់” ជាដើមហ្នឹង។ បាទ ជាដំបូងគឺថា ខ្ញុំបានមានសម្ភាសបាន ដើម្បីបានព័ត៌មាននោះ បន្ទាប់មកខ្ញុំទៅដល់ទីតាំង ហើយខ្ញុំបានសួរអ្នកភូមិចាស់ៗ អ្វីដែលគេចងចាំអំពីកាលនោះមក។

[០៩:៤២:៥៥]

**សៈ** នៅក្នុងពេលដែលគាត់បោះទីតាំងនៅក្នុងខាងពាយ័ព្យ អ៎! និរតីនៃ -- ពាយ័ព្យនៃទីក្រុងភ្នំពេញថា តើសចក្ដីសម្រេចរបស់ ប៉ុល ពត ដែលថាចាប់ផ្ដើមនៅក្នុងទំព័រខាងក្រោម ទំព័រ២៥២ នៃសៀវភៅរបស់លោករហូតទៅដល់ទំព័រ២៥៣, ERN នោះគឺថាភាសាអង់គ្លេស 00396453, បារាំង ERN 00639781-782 សេចក្ដីសម្រេចទាំងនោះដែលលោកបានសរសេរក្នុងសៀវភៅនោះ គឺថាជាពិសេសគឺដើម្បីបង្កឱ្យមានការរីករវរនៅក្នុងភ្នំពេញ។ ចំណុចទី២ ដើម្បីឱ្យស្ថានភាពសន្តិសុខនោះមានភាពតានតឹង ជុំវិញភ្នំពេញ, ទី៣ គឺជាវិធីសាស្ត្រ ដើម្បីត្រួតត្រាលើខ្មាំងសត្រូវ ដូចជាការកសាងមន្ទីរឃុំឃាំង ហើយនិងបន្ដឹងការធ្វើដំណើរជាដើម។ សូមលោកប្រាប់តុលាការ តើលោកបានព័ត៌មានទាំងបីចំណុចសំខាន់ៗនេះតាមប្រភពណា?

**ឆៈ** បាទ ខ្ញុំយកសំណួរកណ្ដាលរបស់លោកស្រីមុន។ ការបន្តឹងរឹតបន្តឹងសន្តិសុខ អំពី គង់ ដួង ដែលគាត់ប្រាប់ខ្ញុំ គាត់ជាអតីតកម្មាភិបាលខ្មែរក្រហម គាត់នៅប៉ៃលិន ហើយគាត់បានរៀបរាប់អំពីបទពិសោធន៍ ហើយគាត់បានមកភ្នំពេញ មកភូមិភាគពិសេស ហើយគាត់មានសំណាងដោយថាគាត់រក្សាសុវត្ថិភាពបាន គឺថាអ្នកដែលនាំគាត់មកពីតំបន់រដ្ឋាភិបាលរហូតទៅដល់ខ្មែរក្រហមគេ -- បើគេមិនសំណាងល្អ គេនឹងត្រូវគេសម្លាប់ហើយ។ ដូច្នេះអ្នកណាម្នាក់ដែលមកពីភ្នំពេញ ចេញទៅដល់ទីនោះនោះ។ ដូចដែលខ្ញុំបានជម្រាប គឺជាឧទាហរណ៍មួយ គឺមានអ្នកសារព័ត៌មានបារាំង នៅទីក្រុងភ្នំពេញមានទំនាក់ទំនងបានស្គាល់ខ្មែរក្រហមខ្លះនៅពេលដែលពួកគាត់ធ្វើជានិស្សិតនៅទីក្រុងប៉ារីស ហើយបាន -- គាត់នោះបានទៅដល់តំបន់នោះ តំបន់ -- នៅក្នុងឯកសាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជាមានរបាយការណ៍នគរបាលដែលជារបាយការណ៍ត្រឹមត្រូវ ដែលរៀបរាប់អំពីពេល ដែលគាត់បានទៅដល់តំបន់នោះ និយាយថា ស៊ែល ជុំង *(តាមសូរស័ព្ទ)* ហ្នឹងបានទៅកន្លែងមួយគឺថា ទៅដល់នោះ មុនពេលដែលការបន្តឹងសន្តិសុខនោះ។ ហើយគាត់និយាយថា ប្រសិនបើព័ត៌មានរបស់ លន់ នល់ និយាយច្បាស់អំពីអ្វីដែលគាត់ទៅដល់នោះ គាត់បានធ្វើទៅដល់ទីនុំង អាហ្នឹងគឺជារបាយការណ៍ចារកិច្ចរបស់ លន់ នល់ អំពីតំបន់ដែលខ្មែរក្រហមរឹតបន្តឹងសន្តិសុខ។ នេះហើយជាប្រភពដែលខ្ញុំទទួលបាននូវព័ត៌មាន។

[០៩:៤៦:៥១]

ឯកសារផ្សេងៗទៀត គឺថាតាមពិតខ្ញុំទទួលបានពីចម្លើយសារភាពនៅទួលស្លែង បើយើងអានឱ្យប្រុងប្រយ័ត្នទៅ គឺថាអាចជាប្រភពព័ត៌មានដ៏គួរឱ្យចាប់អារម្មណ៍ដែរ។ សេចក្ដីសម្រេចដើម្បីបន្តឹង

សន្តិសុខ រូបភាពតានតឹងនៅភ្នំពេញនៅពេលនោះ ៗ គឺថា ថាតើខ្ញុំបានប្រភពនេះមកពីណាខ្ញុំគិតរក ខ្ញុំៗដោយស្មោះត្រង់ ខ្ញុំមិនចាំប្រភពទេលោកស្រី។ បើសិនជានិយាយពីសៀវភៅបែបនេះ គឺថាដូចជា -- ហើយជាប្រភពតូចៗ ដូចយើងប្រមូលគ្រាប់ល្ងអ៊ីចឹង យើងគួបមកបានជាសៀវភៅមួយ។ បើលោកស្រីសួរខ្ញុំថា តើអាព័ត៌មានប៉ុនគ្រាប់ល្ងមួយនេះយកមកពីណា? អាហ្នឹងខ្ញុំឆ្លើយមិនរួចទេ។

**ស៖** ផលវិបាកនៃវាយប្រហារទីក្រុងភ្នំពេញ ហើយនិងការបន្តឹងនៃការត្រួតត្រាជុំវិញទីក្រុងភ្នំពេញដោយខ្មែរក្រហមនេះ ថាតើអ្វីដែលលោកបានរៀបចំនោះ ថាតើមានការជម្លៀស ការផ្លាស់ប្តូរទីតាំងប្រជាជនដែរឬទេ ដូចនិយាយពីខេត្តក្រចេះ ត្រូវបានជម្លៀសនៅក្នុងពាក់កណ្តាលឆ្នាំ១៩៧៣។ ខ្មែរក្រហមវាយប្រហារទីក្រុងកំពង់ចាម ហើយរុញប្រជាជនជាង១៥.០០០នាក់ចេញពីតំបន់ ហើយពីរទំព័រទៅខាងមុខទៀត គឺថា ២៥៧ ទំព័រនោះ។ នៅទំព័រ២៥៥ លោកនិយាយអំពីការវាយប្រហារទីក្រុងឧដុង្គ ERN នោះគឺថា 00396455, បារាំង ERN 00639784 រហូតដល់ 785។ លោកបានិយាយនៅក្នុងទំព័រនេះ អំពីមនុស្ស ២០.០០០នាក់ ចេញពីទីក្រុងឧដុង្គត្រូវបានគេជំរុញទៅទីតាំងសហករណ៍ថ្មីៗបន្ទាប់មកទៀត ប្រហែលជា ៤០.០០០ ត្រូវបានបញ្ជូនទៅកំពង់ធំ។ ចំនួននេះ គឺជាចំនួនប៉ាន់ប្រមាណគឺថាយើងមិនដឹងថា ២០.០០០ ឬក៏ ៤០.០០០ នោះច្បាស់ទេ ជាចំនួនប៉ាន់ប្រមាណ។ ថាតើលោកអាចឈានដល់ចំណុចប៉ាន់ស្មាននេះ ដោយវិធីណានៅក្នុងសៀវភៅរបស់លោកអំពីខេត្តក្រចេះ កំពង់ចាម ហើយនិងឧដុង្គនេះ និយាយពីចំនួនក្តី ព័ត៌មានក្តីនោះ?

[០៩:៤៩:៥៨]

**ឆ៖** បាទ ឧដុង្គនោះ គឺថាងាយទេ អំពីវាមានឯកសារគាំទ្រដែលយើងមាន ដែលយើងយកបានពីបទសម្ភាសន៍ អំពីមកពី ភី ភួន នៅម៉ាឡៃ ហើយនិងគាត់បានរៀបរាប់ -- ខ្ញុំចាំពីគាត់និយាយថា "ការជម្លៀសឧដុង្គនោះ គឺថាសំខាន់ណាស់ ព្រោះថាជាការអនុវត្តសាកល្បង ដែលបង្ហាញឲ្យឃើញច្បាស់ថា ប្រជាជននៅជាយក្រុង គឺថាអាចនឹងជម្លៀសចេញ ហើយនិងដាក់ទៅក្នុងសហករណ៍" ដែលគាត់និយាយថា "ដោយមានបញ្ហាធំដុំអីកើតទេ" គាត់និយាយអ៊ីចឹង។ នេះហើយជាចំណុចសំខាន់។ ខ្ញុំសូមពិនិត្យមើលចំណុចមួយទៀត ដែលលោកស្រីបានយោងអម្បាញ់មិញនេះ។

សម្រាប់កំពង់ធំ ខ្ញុំគិតថា ច្បាស់ថាជាការប៉ាន់ប្រមាណតួលេខដោយភ្នាក់ងារសម្ងាត់អាមេរិកាំង គឺប្រជាជន៤០.០០០នាក់ ដែលមកពីភូមិភាគឧត្តរ ហើយបានធ្វើដំណើរទៅកំពង់ធំ។ មានឯកសារបាន

មកពីភ្នាក់ងារអាមេរិកាំងជាច្រើន វាមិនប្រាកដជាថា ត្រឹមត្រូវសុក្រិតទាំងអស់ទេ ប៉ុន្តែវាជាព័ត៌មានដែលអាចប្រាប់យើងថា អ្វីបានកើតឡើងនៅក្នុងតំបន់របស់ខ្មែរក្រហម ក្នុងឆ្នាំ៧៣។ ហើយគេបានធ្វើការហោះហើរតាមបណ្តោយព្រំដែនកម្ពុជា-វៀតណាម ដែលបង្កលក្ខណៈឲ្យពួកគេអាចធ្វើសេចក្តីសន្និដ្ឋានទៅដល់អ្វីដែលបានកើតឡើងនៅក្នុងតំបន់ខ្មែរក្រហម។ យការដែលស្ថានភាពមានការលំបាកប្រជាជនព្យាយាមរត់គេចខ្លួន។ នេះគឺជាឯកសារដែលបានមកពី -- ព័ត៌មានដែលបានពីឯកសាររបស់ភ្នាក់ងារអាមេរិកាំង។ ដោយសារឯកសារនេះ មិនមែនសម្រាប់ការប្រើប្រាស់របស់សាធារណៈសម្រាប់ឲ្យមានជំនឿទុកចិត្តពីសាធារណជននោះទេ។

[០៩:៥២:២២]

**ស៖** លោកបាននិយាយអំពីកិច្ចប្រជុំរបស់គណៈមជ្ឈិមដែលកោះប្រជុំដោយ ប៉ុល ពត នៅក្នុងពេលដែលប្រហែល១គ្នានោះ នៅក្នុងឆ្នាំ១៩៧៣ ខែកញ្ញា។ អង្គជំនុំជម្រះគឺមានកំណត់ហេតុនៃប្រជុំនេះ ហើយលោកបានកត់ត្រានូវសេចក្តីសម្រេចសំខាន់ៗ ដែលផ្តើមចេញសេចក្តីសម្រេចចេញពីគណៈមជ្ឈិម។ តើលោកអាចជម្រាបជូនអង្គជំនុំជម្រះអំពីប្រភពនៃព័ត៌មាននោះបានទេ?

**ឆ៖** មានឯកសារយោង គឺចម្លើយសារភាពដែលមាននៅបណ្ណាល័យមជ្ឈមណ្ឌលឯកសារកម្ពុជាបណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា។ ការចងចាំរបស់ខ្ញុំនោះ គឺថាមានឯកសារយោងបី ឬបួន ទៅលើកិច្ចប្រជុំរបស់គណៈមជ្ឈិម នៅឆ្នាំ៧៣។ ហើយខ្ញុំក៏បានទទួលបានព័ត៌មានពីការសម្ភាសជាមួយ ភី ភួន ដែលមានវត្តមាន។ ស្ទើរតែនៅគ្រប់កិច្ចប្រជុំរបស់គណៈមជ្ឈិម គឺនៅក្នុងអំឡុងពេល ៧៣, ៧៤ និង៧៥។

[០៩:៥៣:៤៧]

**ស៖** លោកបានរំឭកឡើងវិញថា កិច្ចប្រជុំរបស់គណៈមជ្ឈិម គឺការធ្វើសេចក្តីសម្រេចមួយចំនួន។ ទី១ គឺនិយាយអំពីពួកក្បត់ ត្រូវតែបញ្ជូនឲ្យទៅធ្វើការនៅតាមមូលដ្ឋាន។ ដូច្នេះ កម្ពុជាប្រជាធិបតេយ្យអាចកុងត្រូល -- អាចត្រួតត្រា ត្រួតពិនិត្យទៅលើផលិតផលទាំងអស់។ ទី២ គឺនៅទំព័រ ២៥៥៧, ERN អង់គ្លេស 00396457, បារាំង 00639737។ នៅត្រង់នេះ គឺនិយាយអំពីសេចក្តីសម្រេចឯកច្ឆន្ទក្នុងការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ បន្ទាប់ពីរំដោះទីក្រុងភ្នំពេញភ្លាម។ នេះគឺជាសេចក្តីសម្រេចរបស់គណៈមជ្ឈិមដែលបញ្ជាក់អំពីថា លើកទី១ហើយ ដែលគណៈមជ្ឈិមអនុញ្ញាតឲ្យ

សម្លាប់សមាជិករបស់ខ្លួនម្នាក់ គឺឈ្មោះ ប្រសិទ្ធិ គឺទំព័រ៦០, អង់គ្លេស 00396468, បារាំង 00639790 ដល់ 91។

សេចក្តីសម្រេចទាំងបីនេះ គឺថាគួរឲ្យចាប់អារម្មណ៍ណាស់ វាពាក់ព័ន្ធទៅនឹងគោលនយោបាយផ្សេងទៀតដែលគិតថាត្រូវបានរៀបចំឡើងដោយថ្នាក់ដឹកនាំកម្ពុជាប្រជាធិបតេយ្យ ហើយត្រូវបានយកអនុវត្តនៅក្នុងរបបនោះទាំងមូលតែម្តង។ លោកអាចបកស្រាយ ឬក៏ពន្យល់អំពីសេចក្តីសម្រេចណាមួយក្នុងចំណោមសេចក្តីសម្រេចទាំងបីនេះបានទេ?

[០៩:៥៥:៥៩]

**ផ៖** ខ្ញុំគិតថាសេចក្តីសម្រេចសម្លាប់ ប្រសិទ្ធិ ចោលដែលចេញពីគណៈមជ្ឈិមនេះមកពីខាងផ្នែកនិរតីនេះ គឺបើសិនណាជាលោកស្រីពិនិត្យទៅលើប្រវត្តិបក្សកុម្មុយនីស្តចិននោះ គឺវាមានចំណុចដែលអាចមានលក្ខណៈប្រហែលគ្នា ក្នុងឆ្នាំ១៩៣០ ដែលជាលើកទី១ហើយ វាមានបញ្ហាមេដឹកនាំខេត្តចំនួនបួនរូប ដែលអនុវត្តតាមគោលនយោបាយខុសគ្នាពីគោលបំណងរបស់គោលនយោបាយរបស់ថ្នាក់ដឹកនាំបក្សកុម្មុយនីស្តចិន។ ហើយសេចក្តីសម្រេចដែលបក្សកុម្មុយនីស្តចិនធ្វើឡើង គឺដោយសារតែឥរិយាបថរបស់អ្នកទាំងនោះដែលប្រឆាំងទៅនឹងបដិវត្តន៍។ ហើយដូច្នេះអ្នកទាំងនោះគឺថាត្រូវតែដកចេញ ត្រូវតែកម្ចាត់។

[០៩:៥៧:០៣]

នៅក្នុងប្រទេសចិន មានលក្ខណៈស្រដៀងគ្នាគឺចលនាបក្សកុម្មុយនីស្តចិននៅក្នុងឆ្នាំ១៩៣០ និងអ្វីដែលបានកើតឡើងនៅក្នុងឆ្នាំមួយពាន់ប្រាំបួនរយ -- ទសវត្សរ៍១៩៧០។ វាមានលក្ខណៈស្រដៀងគ្នាមែនទែន។ វាខុសពីវប្បធម៌បដិវត្តន៍ វប្បធម៌របស់ចិន ហើយដែលនៅក្នុងប្រទេសចិននោះ គឺថាវាមានសម្ពាធខ្លាំងណាស់។ មានបទពិសោធន៍ទូលំទូលាយដោយការចាប់ផ្តើមសម្លាប់សមាជិកខ្លួនឯងនៅពេលណាដែលជួបប្រទះទៅនឹងស្ថានភាពដែលមានលក្ខណៈតឹងតែងបែបហ្នឹង។ ដូច្នេះសម្រាប់ខ្ញុំ ការសម្លាប់ ប្រសិទ្ធិ នៅក្នុងឆ្នាំ១៩៧៣ គឺជាដើមដំបូងហើយនៃការបោសសម្អាតផ្ទៃក្នុងដែលវាចេះតែរីករាលដាលនៅក្នុងបក្សកុម្មុយនីស្តកម្ពុជានេះ។

**ស៖** ឥឡូវហ្នឹង ខ្ញុំចង់ចូលទៅប្រធានបទទូទៅមួយដែលនិយាយអំពីមូលហេតុផ្សេងៗដែលបានសម្រេចឡើងដើម្បីជម្លៀសប្រជាជនចេញពីក្រុងភ្នំពេញនៅថ្ងៃ១៧មេសា ៧៥។ ទី១ ការចូលទៅដល់

ការជម្លៀសប្រជាជនចេញពីបណ្ដាផ្នែកផ្សេងៗនៃប្រទេសកម្ពុជានៃតំបន់ដែលបានរំដោះនោះ យើងបានទទួលព័ត៌មានថាប្រជាជននៅទីក្រុងភ្នំពេញ គឺថាមានការកើនឡើងយ៉ាងសម្បើមនៅមុនឆ្នាំ មុន១៧ មេសា ៧៥នោះ។ តើវាត្រឹមត្រូវទេ បើខ្ញុំនិយាយថាចំនួនប្រជាជនដ៏ច្រើនបែបនេះ គឺជាកសិករ ឬក៏ជាអ្នកទីក្រុងដូចជាមកពីឧដុង្គ ឬក៏បណ្ដាទីរួមខេត្តផ្សេងៗនោះ ឬក៏យ៉ាងម៉េច លោកអាចរៀបរាប់បានទេ?

[០៩:៥៩:០៣]

**ឆ៖** ចំនួនប្រជាជនភាគច្រើនរស់នៅទីក្រុងភ្នំពេញនៅក្នុង -- នៅដើមឆ្នាំ៧៥នោះ គឺជាកសិករដែលបានរត់ភៀសខ្លួនមកពីតាមជនបទ។ ទី១ ដោយសារតែអាមេរិកាំងទម្លាក់គ្រាប់បែកនៅទីកន្លែងខ្លះ ហើយអ្នកខ្លះក៏គេចខ្លួនដោយសារតែសង្គ្រាម។ ហើយពួកនោះគេធ្វើដំណើរដោយថ្មើរជើងមក ហើយអ្នកទាំងនោះបញ្ជាក់ថានៅអ្វីដែលប៉ះពាល់ទៅដល់ពួកគេ។ ដោយសារពេលនោះ យើងដឹងថាខ្មែរក្រហមនោះ-- តាមពិតទៅគឺខ្ញុំដឹងថា ហ៊ូ យន់ បាននិយាយក្នុងការផ្សព្វផ្សាយមួយនៅដើមឆ្នាំ៧៥ថា "យើងត្រូវធ្វើសេចក្ដីសម្រេចចិត្ត បើសិនណាជាអ្នកឯងជ្រើសរើសចូលរួមជាមួយ លន់ នល់ នៅភ្នំពេញ យើងជាខ្មែរក្រហម គឺថានឹងពិចារណាទៅតាមនោះ។ បើអ្នកឯងចូលរួមជាមួយបដិវត្តន៍ នោះអ្នកឯងនឹងត្រូវបដិវត្តន៍ស្វាគមន៍។ នេះគឺជាចំណុចមួយដែលបញ្ជាក់អំពី ការញែកពីគ្នារវាងការដែលត្រូវជ្រកកោនក្នុងរបបណាមួយ។

[១០:០០:០៦]

អ៊ីចឹងឯងបានជានៅដំណាក់កាលនោះ ប្រជាជានថ្មីត្រូវបានគេប្រព្រឹត្តផ្សេងដោយសារតែអ្នកនោះជ្រកក្រោមស្លាប លន់ នល់។ ហើយអ្នកដែល ប្រជាជនដែលនៅជាមួយខ្មែរក្រហម ហើយគាំទ្រដោយចលនានោះត្រូវគេប្រព្រឹត្តផ្សេង។ ប្រសិនយើងប៉ាន់ប្រមាណ ត្រួសៗទៅ បើមានប្រជាជន៣លាននាក់នៅភ្នំពេញនាពេលនោះ នៅឆ្នាំ៧៥ គឺថា ប្រជាជនចំនួន ៦.០០០ ហ្នឹងគឺពិតជាអ្នកទីក្រុងមែនទែន -- ៦០.០០០ បាទ ៦០០.០០០នាក់ ជិតអ្នកទីក្រុងមែនទែនហើយ។ ទោះបីគាត់មកពីទីជនបទក៏ដោយគឺគេបានសម្រេចរើស ជ្រើសរើសរស់នៅទីក្រុងភ្នំពេញ។ ដូច្នេះហើយការជម្លៀសប្រជាជនគឺវាប៉ះពាល់ទៅដល់ក្រុមប្រជាជនទាំងពីរហ្នឹង គឺអ្នកទីក្រុងតែម្ដង។ តាមការយល់ឲ្យច្បាស់លាស់គឺជាការចាប់ផ្ដើមដំបូងដែលពីបាត់ដៃទទេរបស់ពួកគេហើយ។ ហើយភាគច្រើន គេត្រឡប់ទៅផ្ទះសម្បែងភូមិកំណើតគេវិញ។

**ស៖** ដូច្នេះជាការប្រសើរគួរតែចាត់ថ្នាក់ប្រជាជនពីទីក្រុងភ្នំពេញជាអ្នកថ្មីគឺអ្នកទីក្រុងតែម្ដង។ អ្នកទាំងអស់នេះគឺថាចែករំលែកជោគវាសនាប្រហែលៗតែគ្នាទោះបីជាអ្នកនោះជាកសិករចូលមកក៏ដោយ ឬក៏ជាអ្នកទីក្រុងពិតប្រាកដនោះក៏ដោយ។ អ៊ីចឹងមែនទេ?

[១០:០២:០០]

**ឆ៖** បាទគឺអ្នកទាំងពីរក្រុមនេះ គឺថាមានជោគវាសនាប្រហែលៗគ្នានៅពេលដែលបញ្ជូនចេញពីទីក្រុងទៅ។ ប៉ុន្តែអ្នកទីក្រុងមែនទែននោះដែលមានទ្រព្យសម្បត្តិច្រើនខុសពីអ្នកក្រដែលមិនមានស្អីសោះ។ អ្នកទីក្រុងមែនទែនគឺមានការអប់រំខ្ពស់ មានការរៀនសូត្រខ្ពស់ ដូច្នេះបញ្ឈរមុខទៅនឹងការសង្ស័យហើយ។ ខ្ញុំអាចនិយាយបានថា ការសង្ស័យទៅលើអ្នកដែលមានការរៀនសូត្រអប់រំខ្ពស់នេះ តាមការគិតនេះគឺអ្នកដែលពាក់វ៉ែនតា គេសំដៅទៅតែអ្នកពាក់វ៉ែនតា ដែលវាចម្លែកណាស់សម្រាប់ពួកខ្មែរក្រហម បើគិតពីឆ្នាំ១៩៧៤ក្តី ឬក៏ពីជំនាន់ឥស្សរៈនោះគឺគេបញ្ជាក់អំពីអ្នកណាជាបញ្ញវន្ត ឬមិនមែនជាបញ្ញវន្ត គេយោងទៅលើអ្នកពាក់វ៉ែនតាហ្នឹងដែរ។ ដោយសារតែយល់ឃើញថាអ្នកហ្នឹងគឺជាបញ្ញវន្ត។

ដូច្នេះយើងគួរតែចងចាំថាអ្នកភូមិក្រីក្រនៅក្នុងប្រទេសកម្ពុជាយើងនេះគឺមិនមានលក្ខណៈអ្វីខុសគ្នាទេរវាងអ្នកមាន និងអ្នកអប់រំ។ ដូចថាអ្នកទាំងអស់ហ្នឹងមើលងាយអ្នកក្រ។ ដូច្នេះអ្នកដែលគេមើលឃើញថាជាអ្នកមាន ឬក៏ជាអ្នកអប់រំខ្ពស់នោះគឺថា ជួបប្រទះពេលវេលាពិបាកជាងអ្នកក្រីក្រហើយ។ ដូច្នេះហើយអ្នកដែលគេមើលឃើញយ៉ាងដូច្នេះហើយជួបប្រទះការលំបាកត្រូវគេសម្លាប់។

[១០:០៣:៣៨]

**ស៖** ដូចខ្ញុំបញ្ជាក់ជូនរួចមកហើយ មានមូលហេតុមួយចំនួនយោងទៅលើការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ លោកបានលើកឡើងនៅទំព័រ២៧១, ERNជាភាសាអង់គ្លេស 00396479, បារាំង 00639804 ដល់ 05។ កងទ័ពបានដើរពីផ្ទះមួយទៅផ្ទះមួយដោយប្រាប់ថាឲ្យប្រជាជនចេញតែពីរ ឬ បីថ្ងៃដោយយកលេសថាអាមេរិកាំងមានផែនការទម្លាក់គ្រាប់បែកនៅក្នុងទីក្រុងភ្នំពេញនេះតែម្តង។ យើងបានទទួលព័ត៌មានបែបនេះច្រើនណាស់តាមរយៈសាក្សីជាច្រើនអំពីការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ។ អ្វីដែលខ្ញុំចង់ផ្តល់ការយកចិត្តទុកដាក់នៅពេលនេះគឺអំពីជំនឿទុកចិត្តទៅលើមូលហេតុដែលថាអាចនឹងមានការទម្លាក់គ្រាប់បែកនោះ។ ហើយដូចលោកបានពិភាក្សាចំណុចនេះយ៉ាងច្រើននៅក្នុងសៀវភៅរបស់លោក។ លោកអាចផ្តល់មតិយោបល់មួយចំនួនលើចំណុចនេះបានទេ?

[១០:០៥:៥៨]

**ឆ៖** ការដែលពន្យល់នោះគឺថា តាមដែលដឹងមកគឺមានការបង្ខំតែម្តង។ គឺមិនមានការទម្លាក់គ្រាប់បែកអីទេ។ ខ្មែរក្រហមថាមិនមាន -- ខ្មែរក្រហមយល់ថាមិនមានការទម្លាក់គ្រាប់បែកអី ប៉ុន្តែហេតុផលដែលប្រាប់ទៅប្រជាជនបែបនេះ អ្នកឯងចាកចេញតែពីរបីថ្ងៃបានហើយ គឺដើម្បីបង្កលក្ខណៈដើម្បីអូសទាញឲ្យពួក -- បញ្ចុះបញ្ចូលឲ្យពួកគាត់ចេញបានដោយងាយនោះ ហើយជាមធ្យោបាយមួយបញ្ចុះបញ្ចូលកុំឲ្យរបស់របរទៅច្រើន ពីព្រោះថាតែពីរបីថ្ងៃនឹងត្រឡប់មកវិញហើយ។ អ៊ីចឹងមិនបាច់យកទ្រព្យសម្បត្តិអីច្រើនទៅជាមួយទេ។

មានលក្ខណៈស្រដៀងគ្នាដែរនៅវៀតណាម ដែលមានមូលហេតុស្រដៀងគ្នានៅខាងពីខាងដើមនោះនៅពេលដែលត្រូវជម្លៀសប្រជាជន យើងហៅទីក្រុងហ្វេនោះ ជាទីក្រុងស្តេចមួយនោះកាលនោះ។ ខ្មែរក្រហមបានដឹងរឿងជម្លៀសចេញពីទីក្រុងវេនោះ។ ប៉ុន្តែ នេះគឺអ្វីដែលបានកើតឡើងពីមុនភ្នំពេញនេះ ហើយនៅក្នុងប្រទេសកម្ពុជា ភ្នំពេញនេះគឺគេបានធ្វើសេចក្តីសម្រេចដើម្បីបញ្ជូនអ្នកទីក្រុងឲ្យទៅជនបទ ហើយនេះគឺដើម្បី -- ហើយអ្វីដែលងាយនឹងឲ្យអូសពួកគាត់ចេញបាន គឺគេត្រូវតែប្រាស់មធ្យោបាយនេះ។

[១០:០៦:៣០]

**ស៖** ជាការពិតហើយលោកបានដឹងអំពីឯកសារដែលលោកបានយោងនៅក្នុងសៀវភៅរបស់លោក គឺឯកសារ E3/196 ជាសេចក្តីថ្លែងការណ៍របស់បក្សកុម្មុយនីស្តកម្ពុជាទៅដល់បក្សពលករដាណឺម៉ាក នៅក្នុងឆ្នាំ១៩៧៨ ដែល នួន ជា -- នៅខែកក្កដា ៧៨ -- ដែល នួន ជា បានលើកឡើង គឺតាំងនាមឲ្យលេខាបក្សនោះ ពេលនោះនៅត្រង់ទំព័រ៣០។ ខ្ញុំសូមដកស្រង់តែម្តង ដែល នួន ជា បាននិយាយ។ សូមដកស្រង់ "មានការដឹងឮឡើងទូលំទូលាយដែលថាអាមេរិក ព្យាយាមក្តោបក្តាប់អំណាចពីយើង ទាញយកអំណាចពីយើង៦ខែក្រោយពីថ្ងៃរំដោះ។ ហើយ កា.ហ្វេ.បេ និង ភ្នាក់ងារវៀតណាមក៏ដូច្នោះដែរ គឺវាមានការចូលរួមគ្នារវាងខាងក្នុង និងខាងក្រៅ។ ប៉ុន្តែយើងបានវាយកម្ទេចផែនការនេះអស់ហើយ។ យើងបានរំដោះប្រជាជន យើងជម្លៀសប្រជាជនចេញពីទីក្រុងនានា"។ ខ្ញុំមិនចង់ឲ្យលោកផ្តល់មតិយោបល់ទៅលើស្ថានភាពណាមិនប្រក្រតីដែលថាពួកអាមេរិក វៀតណាម កា.ហ្វេ.បេ សហការគ្នាក្នុងអំឡុងពេលនោះ តែអ្វីដែលលោកត្រូវនិយាយនោះ គឺថាយោបល់របស់គាត់នៅពេលនោះ

ហើយនិងគាត់មានហេតុផលផ្តល់បែបនេះ។ តើយើងអត់ -- សេចក្តីសម្រេចពីខាងដើម យើងមិនមានកំណត់ត្រាជាលាយលក្ខណ៍អក្សរទេ ទាក់ទងការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ។ តើវាមាននៅក្នុងព័ត៌មានកម្ពុជា ឬក៏លោកអាចផ្តល់យោបល់ដោយយោងប្រភពណាមួយបានទេ?

[១០:០៨:២២]

**ឆ៖** បន្ទាត់ទី៤ ទី៥ នៅត្រង់ហ្នឹង គឺថាវាមានការតស៊ូរួមគ្នាពីខាង រួបរួមគ្នាពីខាងក្នុងខាងក្រៅ តែយើងកម្ទេចកម្ចាត់ផែនការហ្នឹងចោល ហើយយើងរំដោះ និងជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ។ ផលប៉ះពាល់មួយនៃការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ ក៏ដូចជាបណ្តាទីរួមខេត្តផ្សេងៗ ប៉ុន្តែពិសេសក្រុងភ្នំពេញតែម្តង គឺដើម្បីកម្ទេចបណ្តាញ -- ដើម្បីឲ្យអស់តែម្តង គឺបណ្តាញវាយការណ៍ទៅលោកខាងលិចនោះតែម្តង។ មានអាមេរិក, មាន សេ.អ៊ី.អា ដែលគេបានកត់ត្រាទុកថា ព័ត៌មានទាំងអស់ដែលបានពីភ្នំពេញ គឺថាសូមឲ្យបញ្ឈប់ភ្លាមៗក្នុងយប់នោះតែម្តង កុំឲ្យមានព័ត៌មានលេចទៅក្រៅបាន។

ដូច្នេះគំនិតយោបល់នៃការរួមរួមកម្លាំងគ្នានេះ គឺជាការពន្យល់នូវដំណើររឿងរ៉ាវមួយដែលថ្នាក់ដឹកនាំកម្ពុជាប្រជាធិបតេយ្យកសាងឡើង រៀបចំឡើងដើម្បីខ្លួនឯង ដើម្បីយកទៅពន្យល់ យកទៅបញ្ជាក់អះអាងជាទឡ្ហីករណ៍។ ប៉ុន្តែការបោសសម្អាតនេះ គឺកើតមានឡើងមក ៦ខែក្រោយថ្ងៃរំដោះ។

[១០:០៩:៥១]

**ស៖** ខៀវ សំផន ខ្លួនគាត់ផ្ទាល់នៅក្នុងប្រវត្តិរូបរបស់ គឺប្រវត្តិកម្ពុជានាពេលថ្មីៗបានផ្តល់នូវការពន្យល់មួយចំនួនអំពីការដួលរលំនៃទីក្រុងភ្នំពេញ ក៏ដូចជានៅតាមបណ្តាទីរួមខេត្តផ្សេងៗ នៅត្រង់ទំព័រ ៥៥, ERN ជាភាសាអង់គ្លេស 00103750, បារាំង 00595427 ទៅដល់ 28 នៃសៀវភៅរបស់គាត់ គាត់និយាយថា "គាត់អត់បានដឹងអំពីសេចក្តីសម្រេចជម្លៀសប្រជាជនចេញពីក្រុងភ្នំពេញទេ" នៅក្នុងពេលលោកជួបពិភាក្សាជាមួយគាត់ តើលោកមានបាននិយាយថា អំពីការដឹងឮជាមុនរបស់គាត់នៅក្នុងការជម្លៀសប្រជាជនចេញពីក្រុងភ្នំពេញដែរទេ?

**ឆ៖** លោក ខៀវ សំផន បានរៀបរាប់ស៊ីសង្វាក់គ្នាអំពីព្រឹត្តិការណ៍ទាំងឡាយដែលគាត់បានរៀបរាប់មកខ្ញុំ គាត់បាននិយាយប្រាប់ខ្ញុំហើយនិងអ្វីដែលគាត់សរសេរក្នុងសៀវភៅរបស់គាត់ គឺថាគាត់មិនបានចូលរួមពាក់ព័ន្ធក្នុងការជម្លៀសប្រជាជនចេញពីភ្នំពេញទេ គាត់បានប្រាប់ខ្ញុំថា "គាត់បានមក

ភ្នំពេញយូរដែរក្រោយពីការជម្លៀសប្រជាជនហើយ" ដែលចំណុចនេះវាស៊ីសង្វាក់គ្នាទៅនឹងអ្វីដែលលោកស្រីទើបតែជម្រាបជូនខ្ញុំអម្បាញ់មិញនេះ។ អ៊ីចឹងបើសិនណាជាអ្នកណាម្នាក់យល់ឃើញថាយកចំណុចហ្នឹងយកមកប្រៀបធៀប ដើម្បីថាតើលោក ខៀវ សំផន អាចចាំដែរឬក៏អត់ ឬក៏ថាចង់សួរទៅលើបញ្ហាការពិតជាក់លាក់ណាមួយនោះ វាជារឿងមួយផ្សេងគ្នា។

[១០:១១:៥០]

**ស៖** នៅក្នុងសៀវភៅរបស់គាត់ គាត់រៀបរាប់ត្រង់ទំព័រដដែល នៅចុងបញ្ចប់នៃខែមីនា ៧៥ "ខ្ញុំត្រូវបានអញ្ជើញចូលរួមប្រជុំនៅទីបញ្ជាការរបស់បក្សកុម្មុយនីស្តកម្ពុជា នៅភាគខាងលិចនៃឧដុង្គ ដើម្បី តាមដានអំពីការវាយប្រយុទ្ធយកទីក្រុងភ្នំពេញដំណាក់កាលចុងក្រោយ" ហើយរៀងរាល់ថ្ងៃក៏គាត់តាមដានអំពីការវាយប្រយុទ្ធតាមវិទ្យុ -- ខ្ញុំសូមដកស្រង់៖ នៅខែមេសា នៅថ្ងៃ១៧ មេសា នៅម៉ោងប្រាំបួនយើងបានស្តាប់ឮមេបញ្ជាពីអង្គភាពផ្សេងៗនិយាយអំពីទីកន្លែងផ្សេងៗនៅក្នុងទីក្រុង ដោយសារពេលនោះគឺថាក្តៅណាស់ គាត់បានអង្គុយនៅក្នុងខ្ទមរបស់គាត់ ក្តៅមែនទែន ហើយគាត់បានស្តាប់ទៅពួកកងទ័ពដែលត្រឡប់មកទីក្រុងភ្នំពេញវិញនោះ រៀបរាប់ថា ប្រជាជនយ៉ាងច្រើនបានចាកចេញពីទីក្រុងហើយក្រដាសប្រាក់ផ្សេងៗគឺគេក្រវាត់ចេញពីពេញផ្លូវ ពេញថ្នល់ទាំងអស់ គឺវាមានការគួរឲ្យភ្ញាក់ផ្អើលមែនទែន។ តើលោកមានមតិយោបល់អីបានទេ ដែលអាចរៀបរាប់បន្ថែមទៅលើការភ្ញាក់ផ្អើលរបស់គាត់ទៅលើរបាយការណ៍ដែលគាត់ទទួលបានពីកងទ័ពទាំងនោះ?

[១០:១៣:១៨]

**ឆ៖** ខ្ញុំសូមបញ្ជាក់ថា លោក ខៀវ សំផន ក៏បានប្រាប់ខ្ញុំ ថាគាត់បានចូលទៅកាន់ទីបញ្ជាការរបស់ ប៉ុល ពត នៅភាគខាងលិចនៃទីក្រុងភ្នំពេញ គឺនៅជា ប៉ុល ពត នៅថ្ងៃទី១៧ មេសា ៧៥ គឺថាគាត់មិនបានចូលមកភ្នំពេញទេ ថ្ងៃ១៧ មេសា ៧៥ ហ្នឹង គាត់ចូលមកពេលក្រោយ រយៈពេលប៉ុន្មានថ្ងៃក្រោយមកទេ។ ការភ្ញាក់ផ្អើលរបស់គាត់នោះគឺ-- ខ្ញុំភ្ញាក់ផ្អើលដែរ ភ្ញាក់ផ្អើលនូវអ្វីដែលគាត់ភ្ញាក់ផ្អើល។

**ស៖** ពីរទំព័រមកខាងមុខទៀតនេះ "ខ្ញុំមានការភ្ញាក់ផ្អើលយ៉ាងខ្លាំង នៅពេលខ្ញុំនិយាយជាមួយលេខាបក្សកុម្មុយនីស្តកម្ពុជានៅក្នុងឆ្នាំ១៩៧៥ គឺថាថ្នាក់សហករណ៍ថ្នាក់លើ ត្រូវបានប្រើប្រាស់សម្រាប់អ្នកដែលភៀសខ្លួននៅក្នុង តាំងពីឆ្នាំ៧៣ម្ល៉េះ"។ ហើយដែលគាត់និយាយថា វាជាគោលនយោបាយ

មួយចាំបាច់ណាស់។ តើលោកភ្ញាក់ផ្អើលដែរឬអត់ ភ្ញាក់ផ្អើលចំពោះអ្វីដែលគាត់ភ្ញាក់ផ្អើលទេ រឿងសហករណ៍មានតាំងពីឆ្នាំ៧៣ហ្នឹង?

**ឆ៖** ខ្ញុំក៏អាចនិយាយបានថា ខ្ញុំភ្ញាក់ផ្អើលចំពោះអ្វីដែលគាត់ភ្ញាក់ផ្អើលដែរ។ លោក ខៀវ សំផន បានស្នាក់នៅជាមួយនឹងថ្នាក់លើ ហើយវាពិបាកនឹងគិតមើលថា តើនឹងមានអ្វីដែលកើតមានឡើងនៅក្នុងតំបន់ខ្មែរក្រហម។ គាត់ធ្វើដំណើរខ្លះដែរ គាត់ចំណាយពេលយ៉ាងច្រើនជាមួយនឹងក្បាលម៉ាស៊ីនដឹកនាំ ប៉ុន្តែវាពិតណាស់គាត់មិនមែនជាសមាជិកគណៈអចិន្ត្រៃយ៍ទេនៅពេលហ្នឹង មិនមែនសមាជិកអចិន្ត្រៃយ៍នៅថ្នាក់កំពូលរបស់ថ្នាក់ដឹកនាំនោះទេ។ ប៉ុន្តែខ្ញុំយល់ឃើញថា គាត់អាចដឹងអ្វីដែលត្រូវតែមានតម្លាភាពនោះ តែខ្ញុំអាចនិយាយថា វាជាជំហរមួយបន្ទាប់បន្សំទេ។ ខ្ញុំអាចលើកដៃឡើងនិយាយថា ខ្ញុំដឹងនូវអ្វីដែលគាត់ដឹង។ វា -- ខ្ញុំសន្និដ្ឋានថា បើនិយាយបែបនេះ វាអាចសមហេតុសមផលជាង នេះគឺអ្វីដែលខ្ញុំអាចនិយាយបានបាទ។

[១០:១៥:៣៨]

**ស៖** គាត់បាននិយាយនៅក្នុងសៀវភៅរបស់គាត់ដដែលថា នៅទំព័រ៥៧ ការនិយាយជាមួយ ប៉ុល ពត ជាឯកជន ហើយនិងប្រាប់គាត់អំពីការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញនោះ ហើយសម្រាប់ ខៀវ សំផន គឺគាត់និយាយអំពីវាសនាអាក្រក់ គាត់នៅក្នុងខ្ទមមួយដែលក្តៅ ហើយនៅពេលវេលាដ៏ក្តៅបំផុត ដែលប្រជាជនត្រូវចាកចេញពីទីក្រុងភ្នំពេញ។ គឺគាត់និយាយទៅកាន់ ប៉ុល ពត នូវក្តីអស់សង្ឃឹម និងការសោកស្តាយរបស់គាត់នោះ គាត់និយាយថា "ប៉ុល ពត បានប្រាប់គាត់ថាហេតុផលនៃការធ្វើឲ្យភ្នំពេញគ្មានមនុស្សនៅតែម្តង"។ គឺថាគាត់បានឈានដល់ការសម្រេចបញ្ជូនប្រជាជនទៅទីក្រុងភ្នំពេញមុនពេលបញ្ចប់សង្គ្រាម។ គោលនយោបាយសមូហភាពនេះ គឺជាគោលនយោបាយបក្សកុម្មុយនីស្តកម្ពុជា ដើម្បីត្រួតត្រាទៅលើការផលិតផលស្រូវអង្ករ ដែលនឹងដើម្បីដោះប្តូរយកអាវុធ ដើម្បីប្រឈមមុខទៅនឹងកងទ័ពវៀតណាម ដើម្បីបណ្តេញ ហើយនិងបង្ខំឲ្យវៀតណាមគោរពបូរណភាពដែនដីកម្ពុជា ជាពិសេសគឺកងទ័ពវៀតណាមដែលប្រតិបត្តិការក្នុងប្រទេសកម្ពុជា"។ តើនេះជាគោលនយោបាយដែលរៀបរាប់អំពីសមូហភាវូបនីយកម្ម ដែលលោករៀបរាប់ហ្នឹងមែនទេ?

[១០:១៧:១៥]

**ឆៈ** គឺថា ខ្ញុំគិតថាចំណុចមួយអំពីសមូហភាពភាវូបនីយកម្មនៅគឺថាបក្សកុម្មុយនីស្តកម្ពុជាត្រួតត្រាលើការផ្គត់ផ្គង់ស្បៀងអាហារស្រូវ អង្ករ។ រីឯវៀតណាមក៏មានលក្ខណៈកាលនោះដែរ។ នេះជាចំណុចមួយ គឺជាមូលដ្ឋានដ៏សំខាន់មួយសម្រាប់ធ្វើសមូហភាវូបនីយកម្មរបស់គេនោះ។ អ្វីដែលខ្ញុំដឹងនោះ គឺថា គឺគាត់ -- គេអនុវត្តនយោបាយទ្រព្យសម្បត្តិសមូហភាពប្រឆាំងនឹងឯកជន គឺប្រជាជនទាំងអស់ហ្នឹង គឺត្រូវតែគេចាត់ទុកក្នុងស្ថានភាពមួយថា មិនមានទ្រព្យសម្បត្តិអ្វីទៀតទេ ហើយជីវភាពរស់នៅវាត្រូវគេកម្រិតនោះផងដែរ ទៅតាមទ្រព្យសម្បត្តិនោះ។ រីឯការជម្លៀសទីក្រុងភ្នំពេញនេះ គឺជាផ្នែកមួយនៃជាយុទ្ធកម្មដែលជាផ្នែកមួយនៃនយោបាយសមូហភាវូបនីយកម្ម។

**សៈ** បាទ ប៉ុន្តែការអនុវត្តជាក់ស្តែងនោះ គឺវាខុសគ្នាឆ្ងាយតាមគោលការណ៍ ទំព័រ២៨៧ នៅក្នុងអត្ថបទភាសាអង់គ្លេស សៀវភៅរបស់លោក លោកបានរៀបរាប់អំពីមូលហេតុពីរយ៉ាងខុសគ្នាដែល ប៉ុល ពត បានលើកឡើងនោះ។ គាត់បានប្រាប់អ្នកបស្ចិមប្រទេសថា "ចំណាត់ការនោះមិនបានរៀបចំជាមុនទេ គឺថាផ្អែកលើសភាពការណ៍ពិតដែលថា បញ្ហាស្បៀងអាហារនោះវាកើតឡើង គឺថាអាចនឹងជាការរៀបចំរបស់បរិវារអាមេរិក ដើម្បីវាយប្រហារបក្សកុម្មុយនីស្តកម្ពុជា" ហើយគាត់និយាយតទៅទៀត គឺថា "ចំណុចនេះមិនពិតទេ ប៉ុន្តែប្រភពនៃយោបល់របស់ ប៉ុល ពត ដែលបង្ហាញអំពីមូលហេតុសម្រាប់គាំទ្រការជម្លៀសនោះទេ"។ ទោះជាវាមិនពិតនោះក៏ដោយ ក៏គាត់ប្រើយុទ្ធកម្មនេះ។

[១០:១៩:៣៥]

**ឆៈ** សូមអភ័យទោសដែលខ្ញុំអល់អែក ខ្ញុំស្ទាក់ស្ទើរ។ សៀវភៅដែលខ្ញុំពិនិត្យមើលនោះ គឺមិនឃើញមាន មិនមានកំណត់ដៃទាំងស្រុងនោះទេ។ យើងមានតែជាអេឡិចត្រូនិក ខ្ញុំប្រាកដថា សេចក្តីដកស្រង់នេះ តាមពិតជាឯកសារដែលដកស្រង់នេះ គាត់ៗបានប្រាប់ទៅគណៈប្រតិភូបស្ចិមប្រទេស ប៉ុន្តែខ្ញុំមិនចាំថាពួកនោះជាអ្នកណាទេ។ ប្រសិនជាខ្ញុំមានពេល ខ្ញុំអាចរកប្រភពដែលពាក់ព័ន្ធជូនបាន។

**សៈ** លោក ស្បូត សៀវភៅនេះ គឺបោះពុម្ពរយៈពេលយូរដែរហើយ លោកមិនបានចាំចំណុចជាក់ស្តែងលម្អិតនោះទេ ប៉ុន្តែលោកទទួលស្គាល់ទេ គឺថាតើលោកមានប្រភពចំណុចលម្អិតទាំងអស់ គឺថាប្រសិនជាលោកអាចធ្វើបែបនោះបាន យើងក៏ចង់ដឹងដែរ។ ហើយលោកក៏បាននិយាយអំពីមូលហេតុដែលគេបានបញ្ជាក់ ថាទីក្រុងភ្នំពេញត្រូវបានជម្លៀស ដោយសារថាមានការកង្វះស្បៀងអាហារ។ ហើយលោកនិយាយថា ការនោះមិនពិតទេ គឺមិនដូច្នោះទេ មិនត្រឹមតែស្បៀងនោះវាខ្វះខាតទេ ប៉ុន្តែការដឹកជញ្ជូន

ប្រតិចារឹកដែលត្រូវបានកែតម្រូវ។ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ
ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។

ហើយនិងការបញ្ជូនមនុស្សចេញនោះ គឺថាបើសិនជាគេមានវិធីអ្វីសមល្មម ដែលគ្រប់គ្រងបាននោះ គេអាចធ្វើបាន។ សូមលោកពិភាក្សាអំពីខ្លឹមសារដែលលោកនិយាយថា "ការអះអាងរបស់ខ្មែរក្រហមបែបនេះ គឺមិនត្រឹមត្រូវទេ"។ តើលោកអាចពន្យល់អ្វីបន្ថែមទេ?

[១០:២១:២៨]

**ឆ៖** គឺស្បៀងអាហារមិនមានគ្រប់គ្រាន់ក្នុងគុណភាព ក្នុងបរិមាណដ៏ច្រើននោះទេ គឺយើងមានការទម្លាក់ស្បៀងអាហារពីយន្តហោះ គឺត្រូវបានបញ្ចប់។ ហើយអ្នកក្រុងជាច្រើននោះ គឺថាមិនអាចផ្គត់ផ្គង់បានក្នុងរយៈពេលយូរទេ ប៉ុនបើពីរបីថ្ងៃនោះគឺបាន។ បើលទ្ធភាពមួយផ្សេងទៀត គឺពួកគេអាចស្នើសុំឱ្យមានគេបញ្ជូនស្បៀងអាហារពីខាងក្រៅមក ប៉ុន្តែស្ថានភាពស្ថិតិប្រជាជននោះ គឺថាផ្អែកលើការពិត គឺថាវាមានការងាយស្រួលក្នុងការផ្តល់ស្បៀងអាហារ។ បើថាមានគឺថា១លាន ឬ២លាន ដែលនៅចន្លោះនោះ គឺថាគេចេញពីក្រុងគ្រប់ទិសដៅ គឺថាមិនមានផ្តល់សេវាសុខភាព សុខភិបាលអ្វីទេ មិនមានស្បៀងអាហារ បម្រុងសម្រាប់ផ្តល់ឱ្យតាមផ្លូវដែលគេធ្វើដំណើរនោះទេ។ នៅពេលដែលទៅដល់តំបន់នានា តំបន់ទាំងនោះ ក៏គ្មាន គ្មានឃ្លាំង គ្មានស្បៀងអាហារសម្រាប់ផ្គត់ផ្គង់ពួកគេដែរ។ ការងារទាំងអស់នោះ ដែលធ្វើឱ្យអ្នកទាំងនោះមានការលំបាកជាងនៅមួយកន្លែង។ នេះហើយដែលខ្ញុំបញ្ជាក់តាមពិតនោះ គឺថាការដែលបញ្ជូនចេញនោះ វាលំបាកជាង គឺថាសភាពការណ៍នោះឯង ជាភស្តុតាងខ្លួនឯង។

[១០:២២:៥៥]

**ស៖** លោក ខៀវ សំផន បានធ្វើយោបល់ទៅលើបញ្ហានេះ ដែលថាទាក់ទងទៅនឹងមូលហេតុនៃការជម្លៀសទីក្រុងភ្នំពេញដោយសារខ្វះស្បៀងអាហារ ហើយនិងផ្អែកលើការពិចារណាលើប្រវត្តិសាស្ត្រកម្ពុជា គឺ E3/15 នៅទំព័រ៦៤, ជាភាសាអង់គ្លេស 00498283, បារាំង ERN 00643890។ គាត់បាននិយាយថា "ជាយូរមកហើយនៅជនបទ គឺថាដីជាច្រើនត្រូវបានបោះបង់ចោល មិនបានដាំដុះអ្វីទេ។ ប្រជាជនប្រហែលជា៣លានជាង មិនមានអ្វីផ្គត់ផ្គង់ទេ គឺថានៅទីក្រុងមាន៣លានទៀត គឺថាកំពុងតែខ្វះស្បៀងអាហារ"។ នេះហើយដែលមូលហេតុ ដែល ប៉ុល ពត និយាយថា សូមសេចក្តីដកស្រង់គាត់និយាយ "បើបន្តឱ្យគេនៅក្នុងក្រុង នឹងធ្វើឱ្យមានទុរ្ភិក្ស ហើយការជម្លៀសចេញពីទីក្រុង គឺជាល្អដើម្បីជៀសផុតអំពីការទុរ្ភិក្ស និងការបះបោរ។ ខៀវ សំផន និយាយថា គឺថាតាមពិតមានការបះបោរ

ពេលនោះ វៀតណាមនឹងចូលមកធ្វើអន្តរាគមន៍ហើយ”។ ដូច្នេះនេះគឺជាចំណុចខ្លះនៃមូលហេតុមួយចំនួន។ តើលោកមានមតិយោបល់អ្វីដើម្បីបន្ថែមទៅលើសេចក្ដីដកស្រង់ដែលខ្ញុំអានអម្បាញ់មិញនេះទេ?

[១០:២៤:៣៩]

**ឆ៖** ចំណុចចុងក្រោយ គឺសំខាន់ណាស់ គឺថាគ្រោះថ្នាក់នៃការបះបោរនោះ គឺជាវិធីដែលគេប្រឌិតនោះទេ។ ការពិត គឺថាប្រសិនបើអ្នកក្រុងគេបំបែកឲ្យទៅតាមជនបទនោះ គឺថាបណ្ដាញនៅក្នុងរវាងពួកគេ គឺថាត្រូវបំបែក។ គឺថាតាមពិត ដើម្បីគេងាយកុងត្រូល ងាយត្រួតត្រានោះទេ។ គឺថាដោយនិយាយលទ្ធភាពនៃការតស៊ូប្រឆាំងនឹងខ្មែរក្រហមនឹងត្រូវបានបំបាត់ចោល។ បើសិនជាយើងពិនិត្យមើលមូលហេតុដើម្បីគ្រប់គ្រងអំពីការបះបោរ គឺថាជាការត្រឹមត្រូវ ប៉ុន្តែមិនមែនជាមូលហេតុសម្រាប់ទប់ការបះបោរទេ ប៉ុន្តែមូលហេតុដើម្បីថាការជម្លៀសទីក្រុងភ្នំពេញនោះទេ។ បើនិយាយពីទុរ្ភិក្សវិញ ខ្ញុំមិនជឿទាំងស្រុងនោះទេ។

**ស៖** បើនិយាយតាមជាក់ស្ដែង តើត្រូវប្រើពេលប៉ុន្មានដើម្បីបញ្ចេញប្រជាជន ១លាន, ២លាននាក់ចេញពីទីក្រុងភ្នំពេញឲ្យចេញឲ្យអស់ ហើយបន្ទាប់មកដើម្បីផ្ដល់ស្បៀងអាហារឲ្យគ្រប់គ្រាន់នៅកន្លែងដែលពួកគេទៅ ក្នុងករណីដែលនៅទីកន្លែងដែលគេទៅនោះមិនមានស្បៀងអាហារ។ តើប៉ុន្មានអាទិត្យ ប៉ុន្មានខែទើបអាចនឹងផ្គត់ផ្គង់បាន? តើលោកអាចជម្រាបបានទេ?

[១០:២៦:០០]

**ប្រធានអង្គជំនុំ៖**

កុំអាលទាន់ឆ្លើយ!

សូមអញ្ជើញលោក កូប៉េ!

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណលោកប្រធាន។ ខ្ញុំដឹងថា ខ្ញុំមិនចង់នឹងជំទាស់សំណួរដែលចៅក្រមសួរទៅអ្នកជំនាញទេ។ ក៏ប៉ុន្តែសុំធ្វើសេចក្ដីសង្កេតមួយថា ខ្ញុំមិនច្បាស់ប្រាកដថាការឆ្លើយរបស់អ្នកចម្លើយអាចនឹងស្ថិតនៅក្នុងគុណវុឌ្ឍិរបស់គាត់ទេ។ គាត់ជាអ្នកប្រវត្តិវិទូ។ ដូច្នេះហើយ នេះជាយោបល់របស់ខ្ញុំ លោកស្រីចៅក្រម។ បាទ សូមជ្រាប។

**ចៅក្រម ស៊ីលវៀ ខាតវ៉ាយថ៍៖**

ខ្ញុំនឹងបន្តសំណួរបែបនេះ។ ហើយលោក កូប៉េ ហើយខ្ញុំទទួលថាមិន ថាវាមិនទាក់ទងនៅក្នុងវិសាលភាពនៃជំនាញរបស់អ្នកជំនាញនោះទេ។ ប៉ុន្តែអាចនឹងផ្អែកទៅលើសតិសម្បជញ្ញៈដែលគាត់ចេះដឹង យល់ដឹងបាន។

[១០:២៧:១០]

**សួរដោយចៅក្រម ស៊ីលវៀ ខាតវ៉ាយថ៍៖**

**ស៖** ដូច្នេះលោកអ្នកជំនាញ ចំពោះមូលហេតុទាំងឡាយដែលគេលើកឡើងសម្រាប់គាំទ្រការជម្លៀសទីក្រុងភ្នំពេញនោះ ថាតើទាក់ទងទៅនឹងស្បៀងអាហារហ្នឹងដែរឬទេ? តើមានលទ្ធភាពដែលគេអាចផ្តល់ជំនួយស្បៀងពីបរទេសដែរឬទេ ដើម្បីឆ្លើយដែលថាអាចនឹងគ្រប់គ្រងបាន។ ដូចថាជាប្រវត្តិគឺថាមួយសតវត្សរ៍ ឬក៏មុនហ្នឹងគឺថា គឺមានគេផ្តល់ស្បៀងអាហារទៅកន្លែងផ្សេង គេថាគេអាចផ្គត់ផ្គង់ទៅដល់មនុស្សមួយរយពាន់ ឬក៏លើសពីហ្នឹងសម្រាប់ថាកុំឱ្យគេមានទុរ្ភិក្ស គេមានប្រវត្តិផ្តល់បែបនោះ តើលោកយល់ដូចម្តេចក្នុងលក្ខណៈសម័យខ្មែរក្រហមនេះ?

**ឆ៖** ស្បៀងអាហារស្រូវ អង្ករ គឺមកពីប្រទេសចិន។ ប៉ុន្តែបរិមាណវាមានកម្រិត។ ទោះជាយ៉ាងនេះក្តី គឺថាអាចនឹងចាត់ទុកថាជាជំនួយស្បៀងអាហារនោះដែរ។ ប៉ុន្តែមេដឹកនាំកម្ពុជាប្រជាធិបតេយ្យដែលគេប្រកាន់កិត្តិយសរបស់គេថា ខ្លួនទីពឹងខ្លួន។ គឺគេយល់ថាវាផ្ទុយអំពីគំនិត គឺថាបើដើរកាន់ផ្តិលសុំពីបរទេសអ៊ីចឹង មិនល្អទេ ពីព្រោះយើងទទួលបានមហាជោគជ័យហើយ យើងមិនធ្វើអ៊ីចឹងទេ។ នេះហើយគឺជាតថភាពផ្ទៃក្នុងដែលគេយល់ឃើញ។

[១០:២៨:៤៥]

លោកស្រីអាចនឹងគិតថា អាចនឹងគឺថាការធ្វើបែបនេះគឺផ្តល់ស្បៀងអាហារតិចតួចណាស់ចំពោះអ្នកអត់ឃ្លាន ប៉ុន្តែបើតាមទ្រឹស្តីនោះវិញ បើការជួយជាជាក់ស្តែងដើម្បីជួយឱ្យប្រជាពលរដ្ឋទូទាំងប្រទេសដែលកំពុងអត់ឃ្លានហ្នឹង នេះវាជាបញ្ហាមួយ។ ប៉ុន្តែនេះជានយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជានៅក្នុងអំឡុងនៅពេលដែលគេកាន់កាប់អំណាច រហូតទៅដល់ទីបញ្ចប់។ គេមានសេចក្តីប្រាថ្នាចង់ឱ្យប្រទេសមួយខុសប្លែកពីមុន ផ្អែកតាមទស្សនៈរបស់គេ គឺចង់ឱ្យមានសមភាព បរិសុទ្ធ អស្ចារ្យបាទ ជាពិភពកុម្មុយនីស្ត។ ចេតនាហ្នឹង គឺត្រូវហើយ ប៉ុន្តែមិនមានការព្រួយបារម្ភអំពីការឈឺចាប់តាមបណ្តោយផ្លូវដែលដើរឱ្យទៅដល់ទីនោះទេ។

**ស៖** មូលហេតុផ្សេងៗទៀត។ ជាការបញ្ជាក់អំពីមូលហេតុគាំទ្រការជំទាស់នោះ គឺថាដែលលោកដកស្រង់ហ្នឹងគឺ ថាទំព័រ២៨៧, ទំព័រអង់គ្លេស 00396494, បារាំង ERN 00639824 ដល់25។ នៅកន្លែងនោះលោកដកស្រង់ពី ប៉ុល ពត ថា បានប្រាប់ទៅអ្នកកាសែតចិនដូចខាងក្រោមនេះ "រហូតដែលយើងបានកម្ទេចចារកម្មខ្មាំងគ្រប់គ្រាន់ហើយ។ យើងមិនមានកម្លាំងគ្រប់គ្រាន់ ដើម្បីការពាររបបកុម្មុយនីស្តទេ បើយើងមិនកម្ទេចខ្មាំងនោះ"។ ចំពោះមូលដ្ឋានដែលគេបានផ្ដល់ជា ឋានានុក្រមថាតើណាមួយដែលសំខាន់ជាងគេ បើសិនជាកាត់ផ្ដាច់អំពីបណ្ដាញចារកិច្ចទើបបានយើងធ្វើបដិវត្តន៍បាន។ តើលោកគិតថាណាមួយសំខាន់ជាងស្បៀងអាហារ ហើយនិងចំណុចដែលគាត់លើកក្រោយនេះ?

[១០:៣០:៥៧]

**ឆ៖** ខ្ញុំគិតថាអាចនឹងស្មើគ្នាជាលំដាប់ទីពីរឬក៏ទីបី។ បើយើងទុកមូលហេតុទី១ជាមនោគមន៍វិជ្ជាជាលក្ខខណ្ឌមនោគមវិជ្ជាដើម្បីធ្វើឲ្យមានសមភាពរវាងទីក្រុងនិងទីជនបទ គឺថាដោយលុបបំបាត់ទីក្រុង គឺថាមិនឲ្យមានអារម្មណ៍ មិនឲ្យមានសតិអារម្មណ៍អីហ្នឹងនេះគឺជាចំណុចមួយ។ ចំណុចទីពីរ ដើម្បីបំបាត់បណ្ដាញចារកិច្ចពួកគេបានធ្វើរឿងនេះដោយជោគជ័យដោយមានប្រសិទ្ធភាព ដើម្បីបំបែកប្រជាជនទីក្រុងដើម្បីឲ្យអ្នកក្រុងហ្នឹងអាចនឹងតស៊ូបះបោរបាន។

**ស៖** លោក អៀង សារី បានពិភាក្សាអំពីមូលហេតុនៃការជម្លៀសជាមួយលោក ដែលពេលលោកសម្ភាសគាត់នៅទំព័រ២៨៧ គាត់និយាយថា យើងកត់សម្គាល់ថាការបរាជ័យក្នុងការ -- របស់វណ្ណៈអធនក្នុងការបំបាត់សក្ដិភូមិនោះគឺថា គឺការបរាជ័យក្នុងការមិនបានផ្ដួលរបបនោះ។ លោកបានដកស្រង់ថា ប៉ុល ពត មិនធ្វើឲ្យមានកំហុសដូចនៅប៉ារីសទេដែលគេមិនបានកម្ចាត់ពួកសក្ដិភូមិនោះ។ តើនេះជាមូលហេតុមួយផ្សេងទៀត ឬក៏នៅក្នុងផ្នែកមូលហេតុដែលលោកបានលើកពីខាងដើមហើយដែរ?

[១០:៣២:៣៧]

**ឆ៖** ខ្ញុំគិតថា អាចជាមូលហេតុទីបីដែលខ្ញុំបានផ្ដល់ គឺដើម្បីបំបែកបណ្ដាញនៅក្នុងប្រជាជនអ្នកក្រុងគេហៅថា គហបតី ឬក៏ពួកសក្ដិភូមិនោះ។ ហើយនៅក្នុងឆ្នាំ១៨៧០ ឬ៧១ នៅក្នុងក្រុងនៅប៉ារីសជាចលនាកុម្មុយនីស្តនោះគឺថាពេលនោះគឺថា ខៀវ សំផន, ប៉ុល ពត, លោក អៀង សារី គេជានិស្សិតនៅទីក្រុងប៉ារីសនៅក្នុងពេលដែលកុម្មុយនីស្តប៉ារីសហ្នឹង ទី១៨ គេធ្វើពិធីខួបឆ្នាំរបស់គេ ហើយ

ពួកគេបានរៀនសូត្រពីរឿងហ្នឹងច្រើន។ ហើយពួកគេ គេយកគំរូហ្នឹងជាមេរៀន ដូចជាកុម្មុយនីស្តនៅអាស៊ីផ្សេងៗទៀតដែរ។

**ស៖** នៅទំព័រ២៨៨ បន្ទាប់នោះ លោកបានសន្និដ្ឋានថា គោលបំណងនៃការជម្លៀសនោះគឺមិនដើម្បីកម្ទេចទេ គឺដើម្បីបំប្លែង។ ប៉ុល ពត បាននិយាយពេលក្រោយថា ការជម្លៀសនោះគឺវិធានការពិសេសដែលយើងមិនបានឃើញនៅក្នុងកុម្មុយនីស្តរបស់យើងផ្សេងៗទៀតទេ។ លោកនិយាយថា នេះគឺជាយុទ្ធសាស្ត្ររបស់សេដ្ឋកិច្ច យុទ្ធសាស្ត្ររបស់បក្សដើម្បីធ្វើការងារនេះ ហើយសម្រេចនៅក្នុងកិច្ចប្រជុំគណៈអចិន្ត្រៃយ៍ ធ្វើនៅស្ថានីយ៍រថភ្លើង ហើយនិងកិច្ចប្រជុំផ្សេងៗទៀតនៅកន្លែងផ្សេងទៀត។ តើលោកអាចមានយោបល់ អ្វីបន្ថែមទៅលើមតិរបស់ ប៉ុល ពត ដែលលោកនិយាយនេះដែរឬទេ?

[១០:៣៤:២៩]

**ឆ៖** ចម្លើយនៅពេលដែលខ្ញុំសរសេរផ្នែកនេះនៅក្នុងសៀវភៅរបស់ខ្ញុំ ខ្ញុំបានគិតថា នៅពេលនោះខ្ញុំនៅតែគិតថា ជាការសំខាន់ក្នុងការបញ្ជាក់ឲ្យច្បាស់អំពីគោលដៅរបស់ខ្មែរក្រហមហ្នឹងគឺមិនបំផ្លាញប្រជាជនទាំងមូលរបស់ប្រជាជនទេ។ គេមិនបានកំណត់ដើម្បីសម្លាប់ទេ។ គេកំណត់ដើម្បីបំប្លែង ដើម្បីផ្លាស់ប្តូរជីវភាពរបស់ប្រជាជន។

ប៉ុល ពត គាត់មានមោទនភាពថា បក្សបានធ្វើអ្វីតាមរយៈការជម្លៀសទីក្រុងភ្នំពេញ ដែលគេមិនបានធ្វើទេនៅក្នុងកុម្មុយនីស្តផ្សេងៗ ប្រទេសផ្សេងទៀតនោះ។ ប៉ុល ពត, សូមអភ័យទោស, គឺថានៅពេលដែល ម៉ៅ សេទុង នៅចុងឆ្នាំ១៨៧០ នោះបានជួបបក្សវៀតណាម ឡេ យន់ នោះគឺថា ម៉ៅ បាននិយាយថា “លោកបានធ្វើបែបហ្នឹងទេ?” ឡេ យន់ ថា “អត់បានធ្វើទេ”។ ហើយ ម៉ៅ ក៏និយាយថា “ខ្ញុំក៏មិនដែលជម្លៀសនោះដែរ នោះទេ” ហើយខ្មែរក្រហមដែលបានធ្វើអ្វីៗនោះវិញ បានប្រើនូវវិធានការដាច់ខាតជម្លៀសប្រជាជនទីក្រុងភ្នំពេញដែលបក្សកុម្មុយនីស្តផ្សេងទៀតមិនបានធ្វើឡើងនោះ គឺថាពួកគេនិយាយថា “ការធ្វើបែបនេះ វាសំខាន់ណាស់”។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ អ្នកជំនាញ។ ឥឡូវនេះដល់ពេលសម្រាកហើយ ហើយមានឱកាសសម្រាកចាប់ពីពេលនេះតទៅរហូតដល់ម៉ោងដប់មួយ សូមអញ្ជើញចូលវិញដើម្បីបន្តកិច្ចដំណើរការសវនាការ។

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលផ្ដល់កន្លែងសម្រាកនៅបន្ទប់រង់ចាំសម្រាប់សាក្សី និងអ្នកជំនាញដល់លោក ហ្វីលីព ស្សូត ក្នុងរយៈពេលសម្រាកនេះ។ ហើយឱ្យអញ្ជើញគាត់មកកាន់កន្លែងផ្ដល់សក្ខីកម្មនេះវិញនៅវេលាម៉ោងដប់មួយ។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១០:៣៦ នាទី ដល់ម៉ោង ១១:០១ នាទី)*

[១១:០១:២២]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ និងផ្ដល់វេទិកាជូនទៅលោកស្រីចៅក្រម ស៊ីលវៀ ខាតវ៉ាយថ៍ ដើម្បីបន្តការតាំងសំណួរដេញដោលចំពោះអ្នកជំនាញ។

សូមបង្អង់សិនមានការស្នើឡើង លើកឡើងដោយមេធាវីការពារលោក នួន ជា។ សូមអញ្ជើញលោកមេធាវី!

**លោក វ៉ិចទ័រ កូប៉េះ៖**

សូមអរគុណលោកប្រធាន។ លោកស្រីចៅក្រម ខាតវ៉ាយថ៍ ខ្ញុំសូមសួរ -- តើខ្ញុំសូមសួរទៅលោកស្រីឱ្យលោកស្រីសួរទៅអ្នកជំនាញនិយាយអំពីកំណត់ត្រារបស់គាត់ជាអេឡិចត្រូនិក បើគាត់មានតាមពិតខ្ញុំ ដើម្បីឱ្យខ្ញុំពិនិត្យមើលឯកសារនេះបានជាមុន។

**សួរដោយចៅក្រម ស៊ីលវៀ ខាតវ៉ាយថ៍៖**

**ស៖** លោក ស្សូត – លោក ហ្វីលីព ស្សូត បានដឹងហើយប៉ុន្មានសប្ដាហ៍នេះ គឺគេបានសូមឱ្យលោកផ្ដល់នូវប្រភពព័ត៌មាន រួមទាំងកិច្ចប្រជុំរបស់គណៈមជ្ឈិមនៅក្នុងឆ្នាំ១៩៧៣ លោកបានបញ្ជាក់ថាលោកមិនមានលទ្ធភាពចូលទៅបណ្ណសាររបស់លោកទេ ប៉ុន្តែថ្ងៃនេះលោកបានផ្ញើ ឌីសមួយដែលមានឯកសារនៅក្នុងហ្វ៊ីងមួយចំនួន ដែលខ្ញុំមិនទាន់មានពេលវេលា ឬឱកាសដើម្បីពិនិត្យមើលឌីស ដែល

លោកបានឱ្យមកនោះទេ។ តើលោកអាចរៀបរាប់ជូនអង្គជំនុំជម្រះបានទេ ថាតើនៅក្នុងឌីសហ្នឹងមានអ្វីដែរលោក?

[១១:០៣:១០]

**លោក ហ្វីលីព ស្បូត៖**

**ឆ៖** ខ្ញុំសូមអភ័យទោសចំពោះតុលាការ ដែលខ្ញុំមិនអាចផ្តល់ឯកសារនេះជាមុនមកបាននោះ។ អង្គជំនុំជម្រះបានស្នើសុំឯកសារមួយចំនួនដែលទាំងអស់នោះ នៅក្នុងឃ្លាំងឯកសាររបស់ខ្ញុំនៅកន្លែងណាមួយនោះ។ មុននឹងមកកម្ពុជា ខ្ញុំបានរកឃើញឌីសមួយ ដែលខ្ញុំគិតថាអាចនឹងជួយបង្ហាញឯកសារនោះ។ ជាការពិតហើយវាមានឯកសារមួយចំនួនក្នុងហ្នឹង។ ឌីសដែលខ្ញុំផ្ញើជូនអង្គជំនុំជម្រះ គឺជាឌីសដែលបញ្ចាក់ពីឯកសារដែលស្នើសុំអំពីកងទ័ពវៀតណាមនៅហាណូយ ដែលមានប្រភពដើមជាភាសាវៀតណាម ហើយត្រូវបានវាយឡើងវិញ ហើយក៏បកប្រែទៅជាភាសាបារាំង។

ហើយឯកសារនៅក្នុងដែររបស់ខ្ញុំនេះ គឺជាឯកសារអេឡិចត្រូនិកដែលយកចេញពីសៀវភៅនោះតែម្តង ដែលមានប្រភពព័ត៌មានពេញលេញតែម្តង។ ហើយឥឡូវនេះ ខ្ញុំអាចទើបតែ អាចពិនិត្យមើលនិយាយអំពីសម្រង់សម្តីរបស់ ប៉ុល ពត និយាយអំពីការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញដែលថាមិនមែនជាផែនការដែលបានរៀបចំជាមុននោះទេ ហើយកិច្ចសម្ភាសន៍ជាមួយអ្នកកាសែតយូហ្គោស្លាវីនៅចុងឆ្នាំ៧៧ ឬក៏ដើមឆ្នាំ៧៨។ ខ្ញុំស្មុគស្មាញបន្តិចចំពោះស្នើសុំឯកសារសំអាងនៅក្នុងកិច្ចប្រជុំឆ្នាំ១៩៧៣។ ខ្ញុំគិតថាកិច្ចប្រជុំរបស់គណៈអចិន្ត្រៃយ៍នៅក្នុងខែកញ្ញា ៧៤ បាទ នៅមាឃ--

[១១:០៤:៥៨]

**សៈ** ខ្ញុំមិនចង់ឱ្យលម្អិតក្នុងដំណាក់កាលនេះ ប៉ុន្តែអាចជម្រាបជូនទៅមេធាវីការពារក្តីបាន ឬយ៉ាងណានោះ? លោក កូប៉េ ឃើញហើយគឺថាមានឯកសារវិភាគរបស់អ្នកជំនាញ ហើយអ្នកជំនាញក៏មានវត្តមាននៅចំពោះមុខយើង។ ប្រហែលជាយើងនឹងបន្តទៅទៀត លោក ហ្វីលីព ស្បូត។

ខ្ញុំចង់ចូលទៅដល់ការជម្លៀសប្រជាជនដោយផ្ទាល់តែម្តង។ លោកបានរៀបរាប់នៅក្នុងត្រង់ទំព័រ២៧៥ នៅក្នុងសៀវភៅរបស់លោក។ ERN ជាភាសាអង់គ្លេស 00396483 និងបារាំងគឺ 00639810 ទៅដល់ 811។ លោកនិយាយអំពីការបាត់បងជីវិតប្រហែល២០.០០០នាក់ ក្នុងអំឡុងនៃការជម្លៀស

ចេញពីទីក្រុងភ្នំពេញនោះ។ តើលោកផ្តល់ព័ត៌មានបន្ថែមទេ សម្រាប់ប្រភពព័ត៌មានដែលនាំឲ្យលោកធ្វើការប៉ាន់ប្រមាណការបាត់បង់ជីវិតនេះ?

**ឆ៖** វាមានការវាយតម្លៃផ្សេងៗពីអ្នកសរសេរផ្សេងៗ ប៉ែន ឃៀវនិន ថា ១០.០០០នាក់។ ការប៉ាន់ប្រមាណមួយទៀត គឺ៣៥.០០០នាក់។ អៀង សារី នៅពេលមួយ និយាយថា ប្រហែលជា ២ ទៅ ៣០០០នាក់ ហើយ ម៉ៃ មីដៀន -- តួលេខពី ម៉ៃ មីដៀន ប្រហែលជា២០.០០០ មិនអាចអះអាងបាន។ ថាតើអ្នកណាមានតួលេខរៀបរាប់ដំណើររឿងនេះឲ្យបានច្បាស់លាស់? ក៏ប៉ុន្តែព័ត៌មានទាំងអស់នេះ គឺថាស្រដៀងៗនឹងគ្នា។

[១១:០៦:៤៥]

**ស៖** ដូចខ្ញុំនិយាយខាងដើមហើយ គឺសាក្សីមួយចំនួនបាននិយាយអំពីអ្វីដែលបានកើតឡើងនៅក្នុងពេលជម្លៀសប្រជាជនចេញពីទីក្រុងនោះ។ ប៉ុន្តែខ្ញុំចង់ពិនិត្យមើលគោលនយោបាយនៅក្នុងអំឡុងពេលនោះ ឧទាហរណ៍ តើការជម្លៀសប្រជាជនចេញពីទីក្រុងនេះ គឺដើម្បីមិនអនុញ្ញាតឲ្យគេយកអីវ៉ែអីវ៉ាន់។ ចុះចំពោះលុយកាក់វិញ តើលោកអាចនិយាយបានទេរឿងនេះ?

**ឆ៖** ខ្ញុំមិនមានវត្តមានទេនៅពេលនេះ ខ្ញុំគ្មានព័ត៌មានដោយផ្ទាល់នោះទេ។ អ្វីដែលខ្ញុំអាចសន្និដ្ឋានបាន គឺយោងទៅលើសក្ខីកម្មអ្នកដែលមានវត្តមាន ឬអ្នកដែលបានឃើញនូវអ្វីដែលបានកើតឡើង។ ទាក់ទងនឹងទ្រព្យសម្បត្តិនេះ អ្នកទីក្រុងខ្លះៗ គឺអ្នកមានៗបានបើកឡានចេញទៅ តែក្នុងករណីខ្លះ គឺអ្នកខ្លះអាចជិះឡានបានទៅឆ្ងាយដែរ អ្នកខ្លះ គឺត្រូវបោះបង់ឡានរបស់ខ្លួនចោលតាមផ្លូវភ្លាមៗតែម្តង។ ដូច្នេះ វាបញ្ជាក់ស្មុគស្មាញ វាមានស្ថានភាពខុសគ្នាៗក្នុងរបៀបដែលកងទ័ពមកពីភូមិភាគផ្សេងៗ ប្រព្រឹត្តទៅលើប្រជាជនទីក្រុងនោះ។ ឧទាហរណ៍ អ្នកមកភូមិភាគបូព៌ា មានគោលនយោបាយមួយ។ អ្នកនិរតីនិយាយមានគោលនយោបាយមួយ។ ទ័ពមកពីឧត្តរមានគោលនយោបាយផ្សេង។ ប៉ុន្តែជារួមទៅ គឺប្រជាជនអាចយកអីវ៉ាន់បានតិចឡើងៗ ហើយបោះបង់ចោលនៅតាមផ្លូវទៀតផង។

[១១:០៨:១៩]

នៅម៉ោងដំបូងៗ ប្រហែលជានៅថ្ងៃដំបូង ក្រដាសប្រាក់ខ្មែរពេលនោះ គឺថាត្រូវចាយវាយបានទេ ប៉ុន្តែដោយសារតែខ្មែរក្រហម ដែលអមដំណើរជនភៀសខ្លួននេះ ថាលុយអស់តម្លៃអីហើយ មិនបាច់យក

ទៅទេ។ ហើយហាងផ្សេងៗ មានហាងនៅតាមផ្លូវដែរ ដែលមានរបស់របរតិចតួច ប៉ុន្តែឈប់លក់តែម្ដង គឺថាលក់យករបស់មានតម្លៃទៅវិញ ដូចជាយកជាមាស យកជាស្អីទៅវិញ។

**ស៖** លោកបាននិយាយនៅត្រង់ទំព័រ២៨០ នៃសៀវភៅរបស់លោក ERN ជាភាសាអង់គ្លេស 00396488, បារាំង 00639816 ដល់ 817 ដែលនិយាយថា "អ្នកដែលជម្លៀសខ្លួន ត្រូវមានភារកិច្ចគឺថាត្រូវតែរាយការណ៍អំពីប្រវត្តិរូបរបស់ខ្លួន"។ តើលោកអាចសង្ខេបបានទេ ហេតុអ្វីបានជាគេបង្ខំឲ្យប្រជាជនត្រូវតែរាយការណ៍ប្រាប់អំពីប្រវត្តិរូបរបស់ខ្លួន? ហើយថាតើលទ្ធផលនៃការប្រមូលប្រវត្តិរូបនេះ គឺដើម្បីអ្វីដែរ?

**ឆ៖** នេះគឺជាទិចនិករបស់ខ្មែរក្រហមហើយ ដែលគេលើនមកពីបក្សកុម្មុយនីស្តវៀតណាម ហើយដែលថាវៀតណាមនោះរៀនសូត្រតមកពីបក្សកុម្មុយនីស្តចិន។ ខ្មែរក្រហមបានយកទិចនិកនេះយកមកប្រើប្រាស់។ គោលបំណងដំបូង គឺដើម្បីចង់ដឹងអំពីប្រវត្តិរូបប្រវត្តិសាវតាររបស់អ្នកដែលចេញពីទីក្រុងនេះតែម្ដង។

[១១:១០:១០]

**ស៖** ហើយនៅត្រង់ទំព័រដដែលលោកនិយាយថា អ្នកដែលបច្ចេកទេស និងកម្មករ គឺអាចនឹងត្រូវគេយកខ្លួនចេញទៅឆ្ងាយ។ អ្នកភៀសខ្លួនមួយចំនួនបាននិយាយ ដោយសារតែមិនមានព័ត៌មានរបស់អ្នក -- ព័ត៌មានពីអ្នកទាំងនោះៗសន្មតថាត្រូវគេយកទៅសម្លាប់ចោលហើយ។ លោកអាចពន្យល់បានទេ អ្នកដែលត្រូវយកខ្លួនចេញទៅហ្នឹង?

**ឆ៖** បាទជំហរមួយចំនួនដែលថាត្រូវបានគេនាំខ្លួន និងសម្លាប់ចោលជាការបញ្ជាក់ឲ្យឃើញអំពីប្រជាជនដែលចេះតែយល់ឃើញអំពីគោលនយោបាយខ្មែរក្រហម។ អ្នកដែលគេយកខ្លួនទៅ វាបាត់អត់ឃើញមកវិញ។ ហើយអ្នកកម្មករជំនាញត្រូវបានគេយកមកភ្នំពេញ ដើម្បីឲ្យធ្វើការនៅក្នុងរោងចក្រផ្សេងៗ។ រោងចក្រខ្លះ គឺជារោងចក្រផលិតនូវផលិតផលមួយចំនួន។ កម្មកររថភ្លើងយកមកស្ថានីយរថភ្លើង។ កម្មករនៅតាមកប៉ាល់ផ្សេងៗយកទៅឲ្យធ្វើនៅកប៉ាល់។

**ស៖** ក្រុមក្រៅពីនេះនៅត្រង់ទំព័រដដែល គឺសមាជិកទាហាន និងរដ្ឋការនៃរបបលន់ នល់ ដែលលោកបាននិយាយថា ត្រូវបានយកទៅអប់រំរៀនសូត្រ។ តើលោកអាចជម្រាបជូនអង្គជំនុំជម្រះបានទេថាតើការសិក្សាស្រាវជ្រាវរបស់លោកបានបង្ហាញនូវអ្វីដែលកើតឡើងទៅចំពោះប្រជាជនបែបនេះទេ?

[១១:១១:៤៣]

**ឆ៖** បើនិយាយអំពីប្រភេទប្រជាជនទាំងនេះ គឺថាត្រូវបានគេសម្លាប់ចោលតែម្តង។ ហើយក្រុមមួយចំនួនណានោះ គឺថាអាចនឹងត្រូវគេមិនសម្លាប់។ ប៉ុន្តែលក្ខណៈនៃរបបនេះ គឺការប្រព្រឹត្តមកលើប្រជាជនមិនបានដូចគ្នាទេ។ វាអាស្រ័យទៅលើភូមិភាគ ឬក៏ទៅតាម អាស្រ័យទៅលើកម្មាភិបាលខ្មែរក្រហមថ្នាក់ក្រោមបន្តបន្ទាប់នោះ។ ដូច្នេះ វាមានមន្ត្រីរាជការ មន្ត្រីរដ្ឋការ ឬក្រុមព្រះរាជវង្សានុវង្សដែលនៅរស់រានមានជីវិតដែរ។ ជាទូទៅ យើងអាចនិយាយថាប្រសិនណាជាប្រវត្តិរូបរបស់*(ឮមិនច្បាស់)* គិតឃើញថាមិនអាចយោគយល់បានទេ អនុគ្រោះបានទេ ត្រូវតែសម្លាប់ចោលតែម្តង។

**ស៖** ប៉ុន្មានថ្ងៃ យើងបានស្តាប់សាក្សី សាខន បាននិយាយអំពីការជម្លៀសប្រជាជនចេញពីទួលពោធិ៍ជ្រៃនៅក្នុងខេត្តពោធិ៍សាត់ គឺប៉ុន្មានថ្ងៃក្រោយពីការដួលរលំទីក្រុងភ្នំពេញដែលធ្លាក់ទៅក្នុងកណ្តាប់ដៃខ្មែរក្រហមនោះ។ តាមការស្រាវជ្រាវរបស់លោកដែលលោកសរសេរសៀវភៅនេះ តើលោកមានជួបប្រទះឯកសារណាពាក់ព័ន្ធទៅនឹងការចោទប្រកាន់អំពីជោគវាសនាកងទ័ព លន់ នល់ ក៏ដូចជាមន្ត្រីរដ្ឋការចំពោះជោគវាសនារបស់ពួកគេនៅទួលពោធិ៍ជ្រៃដែរទេ? គឺថាមិនមាន អ៊ីនឌិច នៅក្នុងសៀវភៅរបស់ខ្ញុំទេ?

[១១:១៣:២០]

**ឆ៖** ខ្ញុំមិនមានឯកសារពាក់ព័ន្ធទៅនឹងតំបន់នោះទេ។ ប៉ុន្តែមន្ត្រីយោធាជាន់ខ្ពស់ត្រូវគេសម្លាប់ចោលនៅទីកន្លែងផ្សេងៗនៅក្នុងដំណាក់កាលណាមួយនៃពេលជម្លៀសប្រជាជននេះ។ ជាពិសេសគឺអ្នកដែលចេញពីភ្នំពេញនេះ សម្លាប់ក្នុងភ្នំពេញតែម្តង។ ហើយអ្នកដទៃទៀត ខ្លះត្រូវគេសម្លាប់នៅដំណាក់កាលក្រោយតាមដងផ្លូវដែលត្រូវធ្វើដំណើរ។

**ស៖** ប្រជាជនមួយប្រភេទទៀត ដូចជាវិស្វករ វេជ្ជបណ្ឌិត អាំងស៊ីញើ គ្រូពេទ្យ ក៏ត្រូវបាននាំខ្លួនយកទៅអប់រំរៀនសូត្រដែរ។ នេះតាមយោបល់របស់លោកនៅទំព័រ២៨០ នេះឯង។ តើលោកមានដឹងថាមានអ្វីកើតឡើងចំពោះប្រជាជនក្នុងប្រភេទនេះទេ?

**ឆ៖** បាទបានដឹង។ គោលបំណងនៃការយកទៅឲ្យអប់រំរៀនសូត្រ នេះបានធ្វើឡើងតាំងពីដំណាក់កាលដំបូងម្ល៉េះ ហើយក្រុមមន្ត្រីរដ្ឋការនេះ គឺថាជារបបមួយ -- ក្នុងស្ថានភាពលំបាកបំផុត។ មនុស្សជាច្រើនត្រូវបានស្លាប់ អ្នកខ្លះរស់រានមានជីវិត។ ហើយអ្នកទាំងនេះក៏ក្លាយទៅជាប្រជាជនថ្មី

អនុញ្ញាតឲ្យទៅរស់នៅជនបទ ហើយត្រូវតែកែទម្រង់ខ្លួនឯង រស់នៅជារបៀបកសិករ ធ្វើកសិកម្ម។ សុន សេន រដ្ឋមន្ត្រីក្រសួងការពារជាតិ -- បាទ ឥឡូវនេះខ្ញុំនិយាយឆ្នាំ១៩៧៦ ឬក៏ដើមឆ្នាំ១៩៧៧ -- ដែលថាពេលនោះ គឺតែមានគោលបំណងអប់រំប្រជាជន។ គេវិនិច្ឆ័យប្រជាជនអាស្រ័យទៅលើថាតើប្រជាជនហ្នឹងតម្រង់ខ្លួនបានដោយប៉ុនណា។ ហើយបើសិនណាជារបបណាថាជាអ្នកទាំងអស់ហ្នឹង ប្រព្រឹត្តិអ្វីមិនល្អ ធ្វើអ្វីមិនល្អទេ គឺថាអាចនឹងបាត់បង់ជីវិតហើយ។

[១១:១៥:១៩]

**ស៖** នៅត្រង់ទំព័រដដែល លោកនិយាយអំពីអត្តចរិតនៃប្រជាជនទីក្រុងភ្នំពេញ ហើយនិងអ្នកទីក្រុងដទៃៗទៀត ដែលថាធ្វើឲ្យមានការភ្ញាក់ផ្អើលយ៉ាងខ្លាំង។ លោកបានសរសេរត្រង់ទំព័រ២៦៧, អង់គ្លេស ERN 00396475, បារាំង 00639799 ដល់ 800។ សូមដកស្រង់ "ពិបាកយល់ណាស់ ដែលថាពួកប្រជាជនកម្ពុជា *អេលីត*ៗថ្នាក់ខ្ពស់ៗនេះ ក្នុងការឃើញសង្គ្រាមបែបហ្នឹង"។ លោកផ្តល់ហេតុផលពីរយ៉ាង។ ទី១ គឺថាភ្ញាក់ផ្អើលនៅត្រង់ថា ពួកគេត្រូវបានជម្លៀសខ្លួន។ លោកអាចពន្យល់បន្ថែមទេ តើមូលហេតុទាំងពីរហ្នឹងវាយ៉ាងម៉េចដែរ?

**ឆ៖** ហេតុផលមួយគឺថាពិតណាស់ហើយ ដែលពួកខ្មែរ*អេលីត*ៗបែបហ្នឹង ថាអាចនឹងត្រូវគេរៀបចំឲ្យខ្លួនរស់នៅបានជាមួយរបបថ្មីហ្នឹង ប៉ុន្តែលោកឃើញថាពិបាកហ្នឹងឲ្យជឿ ដែលតាមរបាយ-ការណ៍ដែលពួកគេទទួលនៅក្នុងទីក្រុងភ្នំពេញ ពីព្រោះអ្នកជាវណ្ណៈប្រឆាំងនឹងរបបនេះ មិនអាចយោគយល់បាន។ បើសិនអ្នកខ្លះគេអាចនិយាយទាំងបិតភ្នែកបាន ត្រង់ថាអ៊ីចេះ បើសិនណាជាយើងមើលទៅលើប្រវត្តិសាស្ត្រកម្ពុជានៅក្នុងរបប សីហនុ ពីខាងដើមនោះ នៅពេលណាដែលមានព្រឹត្តិការណ៍ដែលគួរឲ្យរន្ធត់ណាមួយ គឺមានការរៀបចំទៅដល់អ្នកទាំងអស់ហ្នឹង។ ប៉ុន្តែក្នុងករណីនេះ គេមិនបានរៀបចំសម្រាប់ប្រជាជននៅក្នុងវណ្ណៈនេះទេ។ ខ្ញុំមិនអាចពន្យល់ហេតុផលឲ្យលើសពីហ្នឹងបានទេ។

**ស៖** *(គ្មានការបកប្រែ)*

**ឆ៖** សូមជួយរំឭកខ្ញុំផងលោកស្រីចៅក្រម។

[១១:១៧:២៤]

**ស៖** ត្រង់ទំព័រ២៦៧ លោកនិយាយអំពីវត្តមានរបស់សម្តេច សីហនុ ដែលជាប្រធានចលនាតស៊ូ ហើយ ខៀវ សំផន ដែលត្រូវបានទទួលស្គាល់យ៉ាងទូលំទូលាយថា ជាមនុស្សម្នាក់ដែលមានភាព

ស្មោះត្រង់ ហើយមនុស្សម្នាក់ដែលមានភាពលេចធ្លោ។ តើលោកអាចនិយាយអំពីចំណុចនេះបានទេ? ខ្ញុំនឹងនិយាយអំពី ខៀវ សំផន និងហេតុផលថាអ្វីបានជាត្រូវបានគេគោរពយ៉ាងទូលំទូលាយ។ ត្រូវបានគេគោរព និងទទួលស្គាល់យ៉ាងទូលំទូលាយនោះ?

**ឆ៖** សូមអនុគ្រោះខ្ញុំផងចំពោះខួរក្បាលខ្ញុំច្របូកច្របល់បន្តិច។ បញ្ហានេះសំខាន់ណាស់ សម្ដេចសីហនុ គាំទ្រខ្មែរក្រហម និងភាពដឹកនាំនៃចលនាតស៊ូប្រឆាំងនឹងរបប លន់ នល់។ គាត់បានផ្សះផ្សាថ្នាក់ដឹកនាំកម្ពុជាជាច្រើន។ កិត្តិយស ខៀវ សំផន ជារឿងមួយដ៏សំខាន់។ បើលោកស្រីចៅក្រមអនុញ្ញាតឲ្យខ្ញុំបន្ថែមចំណុចមួយដែលចេញមកពីការពិភាក្សា និយាយពីការជម្លៀសប្រជាជន ហើយនិងតួនាទី ខៀវ សំផន ក្នុងការជម្លៀសនេះ បើអនុញ្ញាត ខ្ញុំសូមនិយាយ។

[១១:១៨:៤១]

លោកស្រីបានដកស្រង់ថា គាត់មានការទាក់ទងជាមួយនឹង ប៉ុល ពត ជិតដិតដែរ ហើយខ្ញុំសង្ឃឹមថា គាត់អនុញ្ញាតឲ្យខ្ញុំ នេះបើខ្ញុំនិយាយចំណុចហ្នឹងថា បើសិនណាវាមិនត្រឹមត្រូវច្បាស់។ ខ្ញុំយល់ឃើញថាលោក ខៀវ សំផន ឬក៏អ្នកណាម្នាក់នោះ គឺមានជំហរ ហើយនិងបង្ហាញចំណុចនេះបាន។ ចំណុចមួយដែលយើងត្រូវចាំអំពីភាពដឹកនាំ ឬក៏ថ្នាក់ដឹកនាំនេះ។ យើងមិនអាចជំទាស់ចំពោះគោលនយោបាយដែលថ្នាក់ដឹកនាំបានដាក់ចុះមកទេ។ ដែលមិនអាចជំទាស់ដែលថា មិនអាចជំទាស់ដោយយល់ឃើញថា មិនអាចប្រឈមទៅនឹងគ្រោះថ្នាក់ ឬក៏អាចគ្រោះថ្នាក់ដល់ជីវិតតែម្ដងនោះ អាចប្ដូរជីវិតនោះ បើជំទាស់។

ចំណុចនៃគេការនិយាយអំពីការជម្លៀស គឺ ហ៊ូ យន់ គាត់និយាយថា "អ្វីដែលគណៈអចិន្ត្រៃយ៍ធ្វើនេះគឺខុសទាំងស្រុងហើយ"។ ហ៊ូ យន់ គឺត្រូវបានប្រហារជីវិតចោលគឺក្រោយហ្នឹងមក។ គាត់ជាថ្នាក់ដឹកនាំជាន់ខ្ពស់ដែលរៀនជាមួយ ប៉ុល ពត នៅឯប៉ារីស ហើយដែល ប៉ុល ពត ចាត់ទុកថាជាមនុស្សមួយគួរឲ្យស្រលាញ់ គួរឲ្យគោរព។ ប៉ុន្តែគាត់បែជាត្រូវយកទៅសម្លាប់ចោលប៉ុន្មានខែក្រោយយា ក្នុងកាលៈទេសៈគួរឲ្យចម្លែកមែនទែន។ ហើយនៅពេលដែលយើងនិយាយអំពីការជម្លៀសប្រជាជននេះ វាជាគោលនយោបាយខ្មែរក្រហមនេះមិនមែនបិទមាត់ប្រជាជនបាននោះទេ ប៉ុន្តែបើ -- តុលាការត្រូវតែយល់គឺយើងមិននិយាយអំពីដំណាក់កាលនៃរបបកម្ពុជាប្រជាធិបតេយ្យដែលប្រជាជនអាចងើបជំទាស់បាន

នោះទេ។ យើងនិយាយអំពីរបបដ៏ឆ្កួតឆ្កៅនេះ ដែលលោក ខៀវ សំផន ថាបើខ្ញុំជំទាស់ បើអាចនឹងមានបញ្ហាហើយ។

[១១:២០:៣៦]

**ស៖** និយាយអំពី ខៀវ សំផន ឡើងវិញ និយាយអំពីឥទ្ធិពលរបស់គាត់ ឬក៏ចំណុចដែលលោកបានរៀបរាប់អំពីរឿងរបស់គាត់នេះ។ នៅក្នុងប្រវត្តិរបស់គាត់និយាយអំពីប្រវត្តិសាស្ត្រកម្ពុជានាពេលថ្មីៗ គាត់និយាយថា តើគាត់ចូលរួមបក្សកុម្មុយនីស្តកម្ពុជាដោយរបៀបណា? គាត់បានរត់ចូលទៅក្នុងព្រៃ ហើយក្រោយមកសម្តេច សីហនុ គោរពគាត់ដោយសារគាត់បានបោះពុម្ពកាសែតជាភាសាបារាំង ហើយគាត់ជាអ្នកមេដឹកនាំមួយនៃជម្លោះនាពេលនោះ។ ហើយជាពិសេសនៅក្នុងរឿងនៅសំឡូតនេះដែរ នៅក្នុងឆ្នាំ១៩៦៦ គឺ ខៀវ សំផន ខ្ញុំសូមដកស្រង់ 001--

[១១:២១:២៦]

**អ្នកបកប្រែ៖**

សូមអធ្យាស្រ័យលោកប្រធាន ខ្ញុំតាមអត់ទាន់។ សូម--

**ស៖** 00595403 ខៀវ សំផន បានរៀបរាប់ដូចតទៅនេះ "គាត់បានទទួលយកសំណើសុំរបស់បក្សកុម្មុយនីស្តកម្ពុជា ដើម្បីឲ្យគាត់អាចជ្រកកោននៅជនបទជាមួយខ្មែរក្រហម" តើនេះវាបញ្ជាក់អត្ថន័យទៅលើជំហរណាមួយដែលថា ខុសពីបក្សកុម្មុយនីស្តកម្ពុជាដោយសារបក្សកុម្មុយនីស្តកម្ពុជាបានអញ្ជើញឲ្យគាត់ចូលរួមជ្រកកោនក្រោមស្លាកបក្សកុម្មុយនីស្តកម្ពុជាក្នុងព្រៃ។ លោកអាចរៀបរាប់រឿងនេះបន្តិចបានទេ?

**ឆ៖** នេះវាស៊ីសង្វាក់គ្នាតិច ឬក៏ច្រើនក្តីនូវអ្វីដែលលោក ខៀវ សំផន ប្រាប់មកខ្ញុំ។ គាត់បាននិយាយថា "គាត់មិនមែនជាសមាជិកនៃបក្សកុម្មុយនីស្តកម្ពុជាទេនាពេលនោះ។ គាត់ជាសមាជិកនៃបក្សកុម្មុយនីស្តបារាំងកាលគាត់នៅជានិស្សិតនៅទីនោះ" ប៉ុន្តែនៅក្នុងទំនាក់ទំនងជិតដិតជាមួយនឹងអង្គការចាត់តាំងនៅភ្នំពេញ គាត់មានទំនាក់ទំនងជិតដិត។ គាត់ហើយនិង ហ៊ូ យន់ ដែលខ្ញុំរៀបរាប់ខាងដើមនោះ អ្នកទាំងពីរនេះគឺគេបានចាកចេញក្នុងពេលជាមួយគ្នា។ ហើយចំណាយពេលនៅឯកោនៅភូមិដាច់ស្រយាលមួយ។ ហើយកន្លែងនេះ គឺវាចំណុចមួយដែលជះឥទ្ធិ -- នាំឲ្យឥទ្ធិពល ខៀវ សំផន មានឡើង។ ចំណុចមួយគាត់លើកឡើង គឺថា ហ៊ូ យន់ យល់ឃើញថា ពិបាកនឹងទទួលយកការរស់នៅបែបឯកោ

បែបនេះបានណាស់ ហើយគាត់ចង់បន្តដំណើរចេញតទៅទៀត។ លោក ខៀវ សំផន នេះគាត់មានវិន័យត្រឹមត្រូវ គាត់ធ្វើអ្វីដែលគេប្រាប់ឲ្យគាត់ធ្វើ ហើយអនុវត្តតាមវិន័យ តាមបញ្ជារបស់គេ ដោយសារតែអត្តចរិតស្មោះត្រង់ហ្នឹងនៃនិយាយពីចរិតលក្ខណៈគាត់ គឺថាទាំងពីការជម្លៀសប្រជាជន អ្វីៗទាំងអស់គឺគាត់ធ្វើអ្វីតាមតែគេប្រាប់គាត់ឲ្យធ្វើទេ។

**ស៖** នៅក្នុងសៀវភៅដដែលត្រង់ទំព័រ៦០នេះ ERN អង់គ្លេស 00103528, និងបារាំង 00595433 គាត់បាននិយាយថា "គឺថានៅក្នុងឆ្នាំ៧០ និង ៧៥ គឺថាគាត់មិនអាចដើរទៅណាបានទេនៅពេលរស់នៅក្នុងព្រៃដោយសារតែតួនាទីរបស់គាត់នៅពេលនោះ ជាពិសេសដោយសារបញ្ហាសន្តិសុខនិងបញ្ហាប្រត្រកូលសម្រាប់គឺវាមានបញ្ហា។ លោកអាចពន្យល់បន្តិចបានទេត្រង់ចំណុចហ្នឹង?

[១១:២៤:៣៩]

**ឆ៖** បាទ មិនអាចបានទេ។ លោក ខៀវ សំផន នាពេលនោះ ពេលនោះគឺថាគាត់គ្រាន់តែជាមេដឹកនាំដែលមានតែឈ្មោះទេសម្រាប់បក្សកុម្មុយនីស្តកម្ពុជានោះ ដោយមានឋានៈអីឯណា អគ្គមេបញ្ជាការ ប៉ុន្តែនៅពេលនោះនៅក្នុងឆ្នាំ៧៣-៧៤ គាត់ក្លាយទៅជាសមាជិកមជ្ឈិមបម្រុងត្រៀមពេលនុំង គឺថាខិតទៅជិតនឹងអ្នកដែលមានតួនាទីសិទ្ធិសម្រេចនៅសេចក្តីសម្រេចសម្រេចសំខាន់ៗបាន។ ប៉ុន្តែនៅពេលហ្នឹង គឺជាមនុស្សម្នាក់ដែល ប៉ុល ពត ទុកចិត្តគាត់ ដោយសារតែគាត់ធ្វើអ្វីតាមគេប្រាប់គាត់។ ប៉ុន្តែនៅពេលហ្នឹងគាត់មិនស្ថិតនៅក្នុងឋានៈមួយដែលអាចនឹងមានបញ្ហាសន្តិសុខ ដែលអាចទុកចិត្តលើបញ្ហាសន្តិសុខដែលគាត់ដើរបាននោះទេ។

**ស៖** ចម្លើយរបស់គាត់ជូនសហចៅក្រមស៊ើបអង្កេត E3/27 គឺចម្លើយនៅក្នុងឆ្នាំ២០០៧។ លោក ខៀវ សំផន បញ្ជាក់ថា គាត់ស្នាក់នៅជាអចិន្ត្រៃយ៍ជាមួយមេដឹកនាំកុម្មុយនីស្តកម្ពុជា ចន្លោះពី៧០ ទៅ៧៥ គាត់បាននិយាយថា តួនាទីរបស់គាត់រួមមាន ធ្វើការសម្របសម្រួលជាមួយសម្តេច សីហនុ។ សូមដកស្រង់ "គាត់ធ្វើជាតំណាងជាផ្លូវការនៃមេដឹកនាំចលនាតស៊ូ មុខងារផ្លូវការរបស់ខ្ញុំ គឺជាអនុប្រធានរណសិរ្សរួបរួមជាតិកម្ពុជា និងជាអគ្គមេបញ្ជាការនៃកងទ័ពរំដោះជាតិកម្ពុជា។ ខ្ញុំត្រូវបានពិចារណាថា ជាមេដឹកនាំខ្មែរក្រហមតាំងពីពេលនោះមក ប៉ុន្តែមិនមែនជាស្ថានភាពឆ្លើយតបទៅនឹងឋានៈពិតរបស់ខ្ញុំទេ។ ឋានៈពិត គឺ ប៉ុល ពត ដែលជាមេដឹកនាំនយោបាយមនោគមន៍វិជ្ជា ប៉ុន្តែមិនមែនជាមេដឹកនាំកងទ័ពនោះទេ"។ បញ្ចប់ការដកស្រង់។

ប្រតិចារឹកដែលត្រូវបានកែតម្រូវ។ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។

[១១:២៦:៤០]

នៅពេលខ្ញុំអាចចំណុចនេះ ទៅលើកិច្ចសម្ភាសន៍របស់គាត់ហ្នឹង គឺជាអ្វីដែលគាត់រៀបរាប់ជូន គឺនៅមុនពេលគាត់ក្លាយទៅជាសមាជិកនៃបក្សកុម្មុយនីស្តកម្ពុជា។ ជំហររបស់គាត់ ឬឋានៈរបស់គាត់ គាត់ជាប្រធានរដ្ឋ និងជាមេបញ្ជាការកងទ័ព ប៉ុន្តែមិនមែនឋានៈពិតៗដូចដែលនាយករដ្ឋមន្ត្រីធ្វើនៅក្នុងបស្ចិមប្រទេស បណ្តាលបស្ចិមប្រទេសនោះទេ។ តើនេះជាការវាយតម្លៃមួយសមស្របដែរទេ លោក?

**ឆ៖** ខ្ញុំគិតថា លោកស្រីកំពុងតែឲ្យការលើកសរសើរទៅដល់គាត់ជាកាន់តែច្រើនហើយ។ មេដឹកនាំខ្មែរក្រហម ឬក៏មេដឹកនាំចលនាកម្ពុជា គឺសម្តេចសីហនុ បាទ។ លោក ខៀវ សំផន ទទួលបានតួនាទីអគ្គមេបញ្ជាការ អនុប្រធានហ្នុង ដែលគាត់គឺថាទទួលតួនាទី មានឋានៈចេញមកដោយសារតែគាត់ធ្វើជាអ្នកបោះពុម្ពកាសែត ចាងហ្វាងកាសែត ហើយគាត់មាន គឺថាមនោគមន៍វិជ្ជាដូចគ្នា ហើយមានលក្ខណៈស្រដៀងទៅ ប៉ុល ពត គាត់ក៏ចេះតែលើបឡើងៗ ក៏ប៉ុន្តែមិនជាលឿនណាស់ណាទេ។

[១១:២៨:១៨]

ប្រសិនណាយើងនិយាយអំពី -- ហើយនិយាយអំពីបញ្ហាអ្នកអមដំណើរ ប៉ុល ពត គឺ ប៉ុល ពត ចង់ឃើញគាត់ក្លាយទៅជា *សាក់សេសស៊័រ* – អ្នកទទួលស្នងនៅ អ្នកទទួលតំណែងហ្នឹង។ ផ្នែកមួយប្រហែលដោយសារតែគាត់ជាអ្នកដើរតាមដោយស្មោះត្រង់ ដែលបានទទួលតួនាទីហ្នឹង។ ប៉ុន្តែមកដល់ឆ្នាំ៧៥ ដល់ ៧៦ ពេលគាត់ក្លាយទៅជាប្រមុខរដ្ឋនេះ គឺថាតួនាទីរបស់គាត់នេះ គឺថាមិនអាចបំផ្លើសគឺថាលែងបំផ្លើសបានហើយពេលនុ៎ង។

**ស៖** ខៀវ សំផន មិនបាននិយាយអ្វីនៅក្នុងសៀវភៅរបស់គាត់ នៅអ្វីដែលគាត់បានធ្វើពិតប្រាកដនៅក្នុងព្រៃចន្លោះពីឆ្នាំ១៩៦៦ ទៅដល់៧៥ នៅពេលភ្នំពេញដួលរលំនោះទេ។ តើលោកអាចលើកឡើងអំពីរយៈពេលដ៏វែងនេះបានទេ ទាក់ទងទៅនឹងសកម្មភាពរបស់លោក ខៀវ សំផន នេះ?

**ឆ៖** គាត់ចំណាយពេលយ៉ាងហោចណាស់ក៏១ឆ្នាំដែរ នៅតំបន់ដាច់ស្រយាលក្នុងភូមិតូចមួយ។ ហើយខ្ញុំចាំនៅពេលដែលគាត់និយាយថា ថ្ងៃមួយមានការងារច្រើនណាស់ គេត្រូវតែយកគាត់ចេញនៅក្នុងឆ្នាំ១៩៦៧ ក្រោយពីមានការបោះបង់នៅសំឡូត គេក៏ទៅឱរ៉ាល់ ពេលហ្នឹងយកគាត់ទៅឱរ៉ាល់ គឺថាដែលបញ្ជូនបន្តពេលហ្នឹង គឺថាជួបជុំគ្នានៅទីហ្នឹង នៅប៉ុន្មានឆ្នាំក្រោយមកហ្នឹង។ ហើយក្រោយមកទៀតក៏យកគាត់ទៅ -- បាទក៏យកគាត់ទៅក្បែរសាន ជិតទីបញ្ជាការរបស់ ប៉ុល ពត។ ក្រោយពី ប៉ុល ពត

ចុះមកពីរតនគីរិមក។ អ្វីដែលគាត់ធ្វើពិតប្រាកដ គឺគាត់រស់នៅ នៅក្នុងបរិវេណទីបញ្ជាការតែមួយជាមួយ ប៉ុល ពត ប៉ុន្តែការរៀបរាប់ខ្ញុំ គឺថាគឺគាត់បានចេះតែឈានឡើងរហូតឲ្យមេដឹកនាំនោះ ទទួលការទុកចិត្ត ហើយគាត់ស្នាក់នៅជិតជាមួយ ប៉ុល ពត មែនទែន នៅក្នុងដំណាក់កាលនោះរហូតទៅដល់ពេលវាយប្រយុទ្ធយកទីក្រុងភ្នំពេញចុងក្រោយ។

[១១:៣០:៥៥]

**ស៖** អ៊ីចឹងយើងឃើញថា អ្វីដែលគាត់សរសេរ -- គាត់ដែលឆ្លើយនៅក្នុងបទសម្ភាសន៍ទៅការិយាល័យចៅក្រមស៊ើបអង្កេត ហើយនិងអ្វីដែលគាត់សរសេរនៅក្នុងសៀវភៅរបស់គាត់ នៅពេលនៅក្នុងពេលដែលគាត់នៅក្នុងព្រៃនោះ គឺថាឃើញថាគាត់បានចូលរួមសកម្មនៅក្នុងចលនានៅពេលនោះ។ ហើយនៅក្នុងសៀវភៅរបស់គាត់ គាត់បានកត់សម្គាល់ថា គាត់បានដឹងអំពីការតស៊ូប្រដាប់អាវុធនៅក្នុងឆ្នាំ១៩៦៨ ហើយថាមានយុវជន យុវនារី រាប់ពាន់នាក់ចូលក្នុងចលនាយុវជន។ នៅពេលនោះ ក្នុងព្រៃហើយនៅពេលនោះ ឃើញថា ភូមិទាំងមូលត្រូវបានរំដោះម្ដងៗមួយ។ តើលោកគិតថា តើបទពិសោធន៍ទាំងអស់នេះ មានការផលប៉ះពាល់អីដល់គាត់ដែរឬទេ?

**ឆ៖** ខ្ញុំមានការពិបាកណាស់ ដើម្បីយល់ពីចិត្តគំនិតរបស់គាត់។ នេះហើយគឺជាវិធីដែលលោក ខៀវ សំផន រៀបរាប់ពីការងាររបស់គាត់។ យើងត្រូវតែមើលត្រឡប់ក្រោយ ទាក់ទងទៅនឹងជានិក្ខេបបទសេដ្ឋកិច្ចរបស់គាត់ នៅពេលដែលគាត់បានកម្រិត ដុកទ័រ នៅបារីសនោះ គឺថាមួយផ្នែកច្រើន គឺថាជានយោបាយសេដ្ឋកិច្ចសង្គម ដែលខ្មែរក្រហមបានប្រើនៅរបប អូថាគី ដែលថាជារឹងប៉ឹងតាមគំនិតរបស់គេ ស្វ័យភាព គឺខ្លួនទីពឹងខ្លួន។ គឺមិនមានអ្វីដែល ខៀវ សំផន បានប្រាប់ខ្ញុំ ដែលថាការចាប់អារម្មណ៍ខ្លាំងទៅនឹងយោធាទេ ព្រោះគាត់ជាតួអង្គមួយ ប៉ុន្តែភាគច្រើន គាត់ចាប់អារម្មណ៍ទាក់ទងទៅនឹងកិច្ចការសង្គម ហើយជាបញ្ញវន្ត ហើយនិងដែលចាប់អារម្មណ៍ទៅនឹងមនោគមន៍វិជ្ជា ហើយចាប់អារម្មណ៍ទៅលើទស្សនៈដ៏រឹងមាំងមួយ ដើម្បីធ្វើឲ្យមានសមភាពរវាងមនុស្សគ្រប់រូបទាំងអស់។

[១១:៣៣:១៤]

មានរឿងរ៉ាវជាច្រើនក្រោយមក ដែលថានិស្សិតបានចូលរួមគាត់ធ្វើនិក្ខេបបទនោះ គាត់បាននិយាយអំពីលទ្ធិកុម្មុយនីស្ត ហើយនិង -- មើលពាក្យដើមមើល *ខំ-អ៊ុ-ហ្សៀម* គឺថាដូចសហគមន៍មួយ

និយម គឺថាម្នាក់ៗត្រូវតែស្មើភាពគ្នា។ នេះហើយ ខ្ញុំគិតថានេះជាគោលការណ៍គ្រឹះដែលជាការប្ដេជ្ញារបស់គាត់។

**ស៖** អ៊ីចឹងហើយ គឺថាខ្ញុំមិនទាន់ចូលជ្រៅ ហើយខ្ញុំនៅតែឆ្ងល់ថា ហេតុអ្វីដែលថាភាពលេចធ្លោដែលគេផ្ដល់ទៅឱ្យ ខៀវ សំផន នោះ ដែលគេមើលឃើញថាជាកត្តារុញឱ្យគាត់មានតួនាទីជាអ្នកដឹកនាំ ដោយហេតុថា គាត់មិនមែនជាប្រមុខនៃចលនា ហើយមិនទាន់មានឥទ្ធិពលនៅក្នុងចលនាហ្នឹង ក្នុងឆ្នាំ ១៩៧៥។ ប៉ុន្តែតើមូលដ្ឋាននោះ វាមិនទាន់រឹងមាំ មិនទាន់ជ្រៅទេឬ ក្នុងតួនាទីរបស់គាត់កាលនោះ?

[១១:៣៤:១៨]

**ឆ៖** គឺថាមូលដ្ឋាននៃកិត្តិយសរបស់គាត់នោះ គឺពីមុនទេ។ គឺមិនមែនក្នុងសម័យដែលគាត់ចូលរួមក្នុងខ្មែរក្រហមទេ។ នៅពេលដែលគាត់មានរូបភាព នៅពេលដែលគាត់ត្រឡប់មកពីបារីសមកកម្ពុជាវិញ ប្រហែលជានៅក្នុងឆ្នាំ១៩៦០ ប្រហែលក្នុងសម័យកាលហ្នឹង។ សមាជិកគ្រួសាររបស់គាត់ ចង់ឱ្យគាត់ក្លាយទៅជាកាន់តំណែងជាមន្ត្រីនិយមនោះ។ ហើយគាត់ចង់ធ្វើជានាយកកាសែត គាត់បានជាធ្វើធ្វើជាអ្នកនិពន្ធប្រធាន *ឡុបស៊ែរវ៉ាទ័រ* ហើយគាត់សរសេររិះគន់របប សីហនុ គឺថាអាចនឹងការរិះគន់ទន់ភ្លន់។ ប៉ុន្តែទោះជាយ៉ាងណាក្ដី ដែលអាចធ្វើឱ្យមានការចាប់អារម្មណ៍ខ្លាំងទាក់ទងទៅនឹងបញ្ញវន្តដែលនៅក្នុងទីក្រុងភ្នំពេញ។ សម្ដេច សីហនុ គឺថាក្រសួងមហាផ្ទៃរបស់ព្រះអង្គកាល នោះគឺមានប៉ូលិសបានសម្រាតខោអាវ ខៀវ សំផន នៅតាមផ្លូវដើម្បីឱ្យគាត់មានអាម៉ាស់ ក៏ប៉ុន្តែគាត់នៅបន្តកាសែតរបស់គាត់ គឺធ្វើឱ្យគាត់ជាមនុស្សពិសេសគឺថាជាមនុស្សដែលមានកិត្តិយស មានលទ្ធភាព គឺថាមិនអាចងាយឱ្យគាត់ភិតភ័យបានទេ។ ហើយគាត់ជឿជាក់នៅក្នុងយុត្តិធម៌ ប្រព័ន្ធយុត្តិធម៌ នៅក្នុងប្រទេស។ ប្រសិនបើរបប សីហនុ ទុកឱកាសឱ្យ ខៀវ សំផន ធ្វើការហ្នឹងគឺថាអាចនឹងមានអ្វីកើតឡើងល្អ។ ប៉ុន្តែគាត់មិនមានឱកាសទេ។ នេះហើយដែលថាគាត់ទទួលបានកិត្តិយស ហើយនិងកិត្តិសព្ទដែលធ្វើឱ្យគេស្គាល់គាត់ដែលថារហូតមកដល់ឆ្នាំ១៩៧៥។ នេះហើយជាអ្វីដែលគេទទួល ស្គាល់ថាជាវរជនសម្រាប់គាត់នោះ។

[១១:៣៦:១៨]

**ស៖** យោបល់មួយ អ្វីដែលគាត់បញ្ជាក់នៅក្នុងសៀវភៅផ្ទាល់ខ្លួនរបស់គាត់នោះគឺថា គាត់ដឹងក្រោយពីរដ្ឋប្រហារឆ្នាំ១៩៧០ ដែលថា សាឡុត ស មិនមែន អៀង សារី ទេដែលជាលេខាបក្សកុម្មុយនីស្តកម្ពុជា។ តើលោកមានបំណងចង់ពន្យល់បន្ថែមទេពីគំនិតរបស់គាត់នេះ?

**ឆ៖** អ្វីដែលខ្ញុំអាចនិយាយបាននេះ គឺថាវាទំនងជាពិតហើយ សឹងតែជាការពិត។ គឺថាមានមនុស្សភាគច្រើនមិនស្ថិតនៅថ្នាក់ខ្ពស់ ដូចដែលលោក ខៀវ សំផន ទេ។ ប៉ុន្តែដែលថាមានឋានៈខ្ពស់គួរសមហ្នឹង គឺមិនបានដឹងទេរហូតទាល់តែឆ្នាំ១៩៧៥ រហូតដល់ដើមឆ្នាំ៧៦ ទើបគេដឹងថា ប៉ុល ពត ជាមេដឹកនាំចលនា។

**ស៖** ដែលគាត់ឆ្លើយទៅសហចៅក្រមស៊ើបអង្កេតនោះ គឺថាគាត់និយាយថាគាត់បានមកភ្នំពេញពីរបីថ្ងៃក្រោយពីការជម្លៀសនៅថ្ងៃទី១៧ ខែមេសា ហើយជាពិសេសទៅទៀតគាត់បានមកជាមួយ នួន ជា ហើយនិង ប៉ុល ពត ដែលបាននាំគាត់ទៅស្ថានីយរថភ្លើង។ បានស្នាក់នៅទីនោះប្រហែលជាមួយខែបន្ទាប់មកត្រូវបានផ្លាស់ទៅនៅវិហារព្រះកែវមរកតវិញ។ នៅពេលនេះគាត់ជាសមាជិកនៅក្នុងក្រុមហៅថាក្នុងវង់បដិវត្តន៍នោះហើយ។ តើលោកអាចបន្ថែមអ្វីបានទៀតទេ?

[១១:៣៨:០៨]

**ឆ៖** គឺត្រឹមត្រូវមួយផ្នែកហើយ។ អ្វីដែលខ្ញុំព្រួយបារម្ភហ្នឹងគឺថាជាសមាជិក គាត់ជាសមាជិកត្រៀមនៅក្នុងវង់ចលនានោះ។ ខ្ញុំមិនទាន់ជឿថាគាត់ជាសមាជិកពេញសិទ្ធិនៅឡើយទេ ហើយនៅក្នុងវង់ចលនាហ្នឹង គេត្រូវតែជឿជាក់ទុកចិត្តគ្នា ដែលស្ថិតនៅជាមួយគ្នា។ ប៉ុន្តែមិនមែនអ្នកនៅពីខាងក្រៅទេ។ ខ្ញុំនិយាយថាលោក ខៀវ សំផន គឺមិនទាន់ចូលស្និទ្ធនៅឡើយនៅកាលហ្នឹង។

**ស៖** នៅក្នុងសៀវភៅ២៧៦ គឺថា ERN ហ្នឹងខ្ញុំបានឲ្យខាងដើមហើយ។ លោកបាននិយាយថាលោក នួន ជា ហើយនិង ខៀវ សំផន ត្រូវបានបញ្ជូនទៅពិនិត្យកុងត្រូលនៅតាមផ្លូវជាតិលេខ៥ នៅខាងជើងទីក្រុងភ្នំពេញ។ តើលោកយល់ថា តើពួកគាត់ទៅធ្វើពេលហ្នឹងគឺដើម្បីសង្កេតមើលការជម្លៀសដែរឬទេ? តើលោកបានសួរ ឬក៏ពិភាក្សាបញ្ហានេះជាមួយលោក ខៀវ សំផន ទេ?

**ឆ៖** អត់ទេ។ ខ្ញុំសូមជម្រាបថានៅពេលនោះ លោក ខៀវ សំផន ហ្នឹងបានពិភាក្សាពេលនោះមែន។ ខ្ញុំគិតថាគាត់ដូចជាការចងចាំហ្នឹងដូចថា មិនចងចាំច្បាស់ទេ អ្វីដែលគាត់ចាំ គឺចាំតែគាត់មកភ្នំពេញក្រោយរំដោះពីរបីថ្ងៃ។

[១១:៣៩:៤០]

**ស៖** លោកបាននិយាយបន្តិចហើយអំពីឥទ្ធិពលរបស់គាត់នៅក្នុងនយោបាយសេដ្ឋកិច្ច ហើយពិភាក្សាអំពីការងារពីដើមរបស់លោក ខៀវ សំផន អំពីការសិក្សា អំពីនយោបាយសេដ្ឋកិច្ច ហើយនិងសង្គមដែលត្រូវបានអនុម័តយកដោយរបបខ្មែរក្រហមនោះ។ ចុះនយោបាយនិយាយអំពីកម្មសិទ្ធិឯកជនហើយនិងសម្ភារនិយមវិញ តើជាផ្នែកនៃសេដ្ឋកិច្ចរបស់លោក ខៀវ សំផន ដែរទេ? ជាទ្រឹស្តីសេដ្ឋកិច្ចរបស់គាត់ដែរឬទេ?

**ឆ៖** អ្វីដែលចងចាំបានច្បាស់នោះ គឺថាមិនមែនស្ថិតនៅក្នុងនិក្ខេបបទរបស់គាត់ ដែលទទួលបានថ្នាក់បណ្ឌិត ជាដុកទ័រនៅបារីសនោះទេ។ គឺផ្អែក គឺថាផ្អែកទៅលើតែលទ្ធិ គេហៅ "អូថាគី" ដែលថា "ខ្លួនទីពឹងខ្លួន"។ បើយើងនិយាយកម្មសិទ្ធិឯកជនវិញ គឺថាជាគំនិតកើតឡើងក្រោយ ប៉ុន្តែមិនបាននិយាយអំពីរឿងហ្នឹង នៅក្នុងនិក្ខេបបទរបស់គាត់ទេ។

[១១:៤០:៥៦]

**ស៖** នៅក្នុងទស្សនាវដ្តីទង់បដិវត្ត ខែធ្នូ ឆ្នាំ១៩៧៦ ដល់ខែមករា ឆ្នាំ១៩៧៧ ឯកសារ E3/25 នៅចំណុចចាប់ផ្តើមនៅក្នុងសុន្ទរកថា ដែលមានចំណងជើងថា "ការជោគជ័យដ៏ត្រចះត្រចង់នៅក្នុងឆ្នាំ១៩៧៦ ហើយនិងអនាគតដ៏ភ្លឺស្វាងសម្រាប់ឆ្នាំ១៩៧៧"។ គាត់បានមានយោបល់ថា និយាយអំពីកម្មាភិបាល -- ពួកអ្នកដែលជិះជាន់ យើងបានកម្ទេចនៅក្នុងឆ្នាំ១៩៧៦ ហើយនិងលុបបំបាត់ទាំងអស់។ ពួកគេមិនអាចងើបក្បាលបានទេ នៅជនបទ នៅទីក្រុង នៅក្រសួង ឬនៅក្នុងមន្ទីរផ្សេងៗ ឬក៏នៅក្នុងជួរបក្សនោះបានទៀតទេ។ ការវាយប្រហារ ហើយនិងការបបោសសម្អាតនេះ មិនមែនជាការងារងាយស្រួលទេ ដែលអាចធ្វើនៅក្នុងវិស័យមួយ ពីរទេ។ ជាការវាយប្រហារជាប្រព័ន្ធគ្រប់វិស័យ ដើម្បីបំបាត់ឲ្យអស់ជាចំនួនច្រើន និងចំនួនក្រុមតូច ក្រុមធំផងដែរ។

[១១:៤២:០៩]

ខ្ញុំមិនប្រាកដថា នេះជាសេចក្តីយោងដែលទាក់ទងឆ្លើយតបទៅនឹងរបបកម្មសិទ្ធ ឬក៏ដីរបស់សក្តិភូមិនោះទេ។ ប៉ុន្តែអានេះជាគំនិតអំពីការវិធានការចំពោះខ្មាំងដែលពួកគេកំណត់នោះ គឺជាការវាយប្រហារអំពីវណ្ណៈជិះជាន់ ហើយនិងគំនិតនៃទ្រឹស្តីសេដ្ឋកិច្ច។ តើលោកអាចនឹងជម្រាបអ្វីបន្ថែមពីគំនិតនេះបានទេ?

**ឆ៖** ខ្ញុំគិតថា ចំណុចពីរនេះ វាទាក់ទងគ្នា ប៉ុន្តែជាសំខាន់ អ្វីដែលខ្ញុំពិនិត្យមើលនោះគឺថានេះជាចំណុចចាប់ផ្ដើមដែលថាមនុស្សលោកគ្រប់រូប គឺថាគប្បីតែនៅជាមួយគាត់ មានចេតនាអំពីកម្មសិទ្ធិឯកជន គឺថាត្រូវដាច់នៅពីគេ។ អានេះហើយជាគំនិតមួយសម្រាប់គាត់ គឺថាគាត់មើលឃើញថាជាគំនិតបុគ្គលនិយម ប៉ុន្តែខ្មែរក្រហមគេចង់បំបាត់អាគំនិតបុគ្គលនិយមនេះ។ គឺថាម្នាក់ៗ គឺមិន--លែងជាបុគ្គលទៀតហើយ គឺស្ថិតនៅក្នុងមហាជនទៅវិញ។ ដូច្នេះ ឫសគល់នៃបុគ្គលនិយមដែលមានកម្មសិទ្ធឯកជន ចេតនាចង់បានរបស់ល្អ ដែលរីកដុះដាលនៅក្នុងបុគ្គលណាម្នាក់នោះ បន្ទាប់មកអ្នកហ្នឹង គឺត្រូវទទួលខុសត្រូវ ថានឹងក្លាយទៅជាខ្មាំងរបបហើយ។ ដូច្នេះហើយ ចំណុចនេះជាផ្នែកមួយទៀត បើយើងមើលរឿងមួយវាទាក់ទង។ អ៊ីចឹងបើសិនជាលោកស្រីយោងទង់បដិវត្តនោះ គឺជាគំនិតនេះឯងវាសងខាង។

[១១:៤៤:០២]

**ឆ៖** សូមអភ័យទោស ខ្ញុំស្ដាប់មិនឮ។

**ស៖** សូមអភ័យទោសលោកប្រធាន ទំព័របន្ទាប់នេះគឺថា ២៨៩ នោះ ទំព័រ២៨៩ លោកបាននិយាយថា "ករណីនៃខ្លួនទីពឹងខ្លួន" ហើយនិងនិក្ខេបបទរបស់គាត់ ដែលសម្រេចបាននៅក្នុងឆ្នាំ១៩៥៩ នោះ គឺគំនិត ឬក៏លទ្ធិស្វ័យភាព ឬក៏ហៅថា ខ្លួនទីពឹងខ្លួន គឺថា -- សូមអភ័យទោសចំពោះអ្នកបកប្រែ គឺថាទស្សនៈនេះ វាលំបាកបន្តិច។ យ៉ាងហោចណាស់ទស្សនៈរបស់គាត់ គឺថា ដើម្បីពិនិត្យមើលភាពចាំបាច់ ដើម្បីធ្វើឲ្យមាន ដើម្បីកម្រិតនូវពាណិជ្ជកម្មដោយសេរី ហើយកំណត់ទំនាក់ទំនងរវាងបុគ្គល ហើយនិងរដ្ឋ។ ដូច្នេះ ចំពោះខ្ញុំគឺថា ឃើញថាជាការបញ្ចូលទ្រឹស្ដីពីរ ដើម្បីយើងអាចត្រួតត្រាប្រជាជន ហើយនិងនយោបាយ សេដ្ឋកិច្ច ពាណិជ្ជកម្មផងដែរ។ ថាតើលោកយល់ស្របជាមួយគំនិតនេះដែរឬទេ ចំពោះស្ថានភាពបែបនេះ?

**ឆ៖** ខ្ញុំថាយើង បើយើងអានទៅគឺថា -- បើយើងទំនាក់ទំនងរវាងបុគ្គល ហើយនិងរដ្ឋនោះ ដូចដែលលោក ខៀវ សំផន និយាយនោះវាអាចគ្របដណ្ដប់ទៅលើគំនិតនិយាយអំពីសមូហភាពនិយមនោះហើយ។ អ៊ីចឹងយើងត្រូវតែមានការប្រុងប្រយ័ត្នក្នុងការអានពីឯកសារខាងដើមនោះ តើអ្វីដែលអាចក្លាយទៅជាឯកសារ ជាទ្រឹស្ដី ពី១០ឆ្នាំ ឬ២០ឆ្នាំក្រោយមកនោះ។ ខ្ញុំគិតថា ទ្រឹស្ដីនោះវាមានការវិវត្តទៅតាមសម័យកាល។

[១១:៤៥:៥៧]

**ស៖** ប៉ុន្តែមាននយោបាយផ្សេងៗទៀតផងជាឧទាហរណ៍ និយាយអំពីការលុបបំបាត់ខ្លាំងជាភាសាអំពីដូចជាគាស់ឲ្យអស់ឫស រំលើងឲ្យអស់ឫសពួកខ្លាំងនោះ ហើយសៀវភៅរបស់លោកក៏បាននិយាយអំពីចំណុចនេះខ្លះដែរ។ លោកបានសិក្សាអំពីបក្សកុម្មុយនីស្តកម្ពុជា ហើយលោកបានមើលលម្អិតអំពីនយោបាយបក្សកុម្មុនីស្តកម្ពុជា ហើយអំពីទំនាក់ទំនង ហើយនិងភាពស្រដៀងគ្នារវាងបក្សកុម្មុយនីស្តកម្ពុជា ហើយនិងបក្សកុម្មុយនីស្តចិន អំពីវិធីសាស្ត្ររបស់គេ។ តើនយោបាយសេដ្ឋកិច្ច ហើយនិងនយោបាយចំពោះខ្មាំង វាអាចមានជាការប្រៀបធៀបទៅនឹងលទ្ធិកុម្មុយនីស្តផ្សេងៗទៀតទេនៅក្នុងសម័យកាលពេលនោះ?

**ឆ៖** អត់ទេ ដើម្បីស្រង់យកចំណុចដែលលោកស្រីនិយាយថា ជីករំលើងឫសនេះគឺថា ពីឯកសារដែលនិយាយនៅក្នុងឆ្នាំមួយពាន់ -- ទសវត្សរ៍ឆ្នាំ១៩៧០ អ៊ីចឹងគឺថាយើងត្រូវតែមើលរហូតដល់ឆ្នាំ១៩៥៩ ដើម្បីមើលថា តើអ្វីជាគម្រូដែលគេត្រូវយកមកធ្វើនៅពេលក្រោយនោះ។ ចម្លើយគឺអត់ទេ របបកុម្មុយនីស្តផ្សេងៗទៀត ជាអន្តរជាតិនោះអ្វីដែលគេធ្វើនោះ ខ្មែរក្រហមបានធ្វើនោះគឺថាវាមានលក្ខណៈស្រដៀងទៅនឹងកុម្មុយនីស្តនៅអាស៊ី ដូចជានៅវៀតណាម ហើយនិងនៅចិន ដែលគេបានធ្វើនៅពេលដែលស្ថិតនៅក្នុងសម្ពាធធ្ងន់នៅពេល -- ក្នុងការវិវត្តទៅមុខ ប៉ុន្តែដែលគំរូជិតបំផុតនោះ គឺថាបក្សកុម្មុយនីស្តចិន ប៉ុន្តែវាតូចទេ ប៉ុន្តែវាមានសម្ពាធខ្លាំងណាស់។

[១១:៤៨:០៩]

នៅក្នុងតំបន់មួយតូចនៅក្នុងប្រទេសចិននៅដើមឆ្នាំ១៩៣០ គឺថាវាមាន ស៊ូហ្វេន *(តាមសូរស័ព្ទ)* នោះគឺជាចលនាប្រឆាំងនឹងបក្សកុម្មុយនីស្ត និងបដិវត្តន៍ គឺថាស្រដៀងនូវអ្វីដែលកើតឡើងនៅកម្ពុជានៅក្រោយដែរនៅសម័យខ្មែរក្រហមនោះ។ អ្វីដែលគេមើលនោះគឺថា គេនិយាយថា វាជាការល្អអាចសម្លាប់ខ្មាំង សម្លាប់ខុស១០ ល្អជាងទុកសត្រូវមួយឲ្យនៅ។ ដូច្នេះហើយ នេះហើយជាសម័យកាលជាក់លាក់នៅក្នុងការវិវត្តរបស់បក្សទាំងពីរនេះ ប៉ុន្តែខ្មែរក្រហមគេមិនដែលទៅហួសហ្នឹងទេ ឡេនីន និយាយជាដំណាក់កាលកុម្មុយនីស្តវ័យក្មេង គាត់និយាយអ៊ីចឹង។ គេចាប់ផ្តើមនៅក្នុងប្រទេសចិន ប៉ុន្តែគេបញ្ឈប់គេដាក់គំនិតថា កំណែទម្រង់ខ្លី ប៉ុន្តែ ម៉ៅ សេទុង និយាយថា គឺថាបើសិនថាដូចកុមារអ៊ីចឹងដែរ បើយើងសម្លាប់ ហើយគេបង្អត់គឺថាវាមិនដុះដាល វាមិនរីកចម្រើនទេ។ ដូច្នេះហើយអានេះជាភាពខុសគ្នា។

**សះ** នៅទំព័រ២៨១ នៅក្នុងសៀវភៅរបស់លោក គឺថា ERN 00396498 ហើយបារាំង ERN 00639830 លោកបានសង្ខេបអំពីអង្គហេតុមួយតាមដែលខ្ញុំជឿថា អ្វីដែលលោកបាន ទើបតែបាននិយាយអម្បាញ់មិញនេះឯង។ យុត្តិសាស្ត្រដែលធ្វើឡើងដោយគណៈអចិន្ត្រៃយ៍កម្ពុជាប្រជាធិបតេយ្យ នៅក្នុងឆ្នាំ១៩៧៥ ហ្នឹង គឺថាបង្កើតនៅបញ្ហាជាច្រើនទោះបីជាអ្នកសង្កេតនៅបស្ចិមប្រទេសក៏ដោយ គឺថាមិនមែនត្រឹមខ្លឹមសារនោះទេ ទោះបីជាវាមានលក្ខណៈដាច់ខាត ហើយធ្ងន់ធ្ងរគឺអ្វីៗដែល ខៀវ សំផន ហើយ ហ៊ូ យន់ បានគ្រោងទុកជាមុននោះ គឺថាបញ្ហានោះវាកើតឡើងដោយសារវាស្ថិតនៅក្នុងការអនុវត្តទេ។ សូមដកស្រង់ "គឺជារបបសេរី ឬក៏កសិកម្មនិយម ឬក៏សង្គមធូរធង់នោះទេ" ហើយលោកបានបន្តទៅទៀតថា "គឺជារដ្ឋដែលប្រកបដោយទាសករដ៏ធំធេងមួយនៅក្នុងសម័យទំនើប"។ តើអ្វីដែលលោកអាចបំភ្លឺបន្ថែមធ្វើឱ្យយើងយល់ច្បាស់ជាងហ្នឹងទៅលើយោបល់ដែលលោកបានបញ្ជាក់អម្បាញ់មិញនេះដែរឬទេ?

[១១:៥១:០៤]

**ឆះ** ចម្លើយអត់ទេ។ នេះហើយ គឺថាមិនមែនជាការពង្រីកទេ នេះជាចំណុចសំខាន់នៅក្នុងនយោបាយរបស់ ប៉ុល ពត នាកាលនុ៎ង។ ជារដ្ឋរបស់ទាសករដែលថា ប្រជាជនគ្មានមនុស្សមិនមានការជ្រើសរើស មិនមានលុយចាយអ្វីនោះទេ។ ហើយគេមិនអាចសម្រេចថា ធ្វើការម៉េច ហូបចុកម៉េចទេ គឺគេកំណត់ឱ្យអ្នកទាំងអស់នោះទាំងអស់។ ចំណុចជម្រើសតូចៗដែលធ្វើឱ្យមនុស្សលោកដែលយើងធ្វើសម័យថ្ងៃហ្នឹងត្រូវបានដកហូតទាំងអស់ គឺត្រូវបានហាមឃាត់មិនឱ្យបុគ្គលមានសិទ្ធិបែបនោះទេ។ នេះគឺជាសោកនាដកម្មរបស់របបខ្មែរក្រហម ពួកគេបានធ្វើដើម្បីមូលហេតុដ៏បរិសុទ្ធដើម្បីបង្កើនជីវភាពប្រជាជននៅជនបទ ប៉ុន្តែគាត់លុបបំបាត់ជីភាពជាអ្នកក្រុង។ ប៉ុន្តែចំពោះនយោបាយ ឬក៏លទ្ធិខ្លួនទីពឹងខ្លួននេះ គឺមិនមែនអ្វីអាក្រក់ទេ ប៉ុន្តែអ្វីដែលគេធ្វើទេដែលថា ធ្វើឱ្យរបបទាំងមូល រដ្ឋទាំងមូលក្លាយទៅជានរកលោកិយទាំងមូល ហើយអ៊ីចឹង គឺថាចំពោះដែលយើងនិយាយថា បើយើងប្រើពាក្យថា ប្រល័យពូជសាសន៍ប្រហែលជាអាចនឹងប្រើខុស។

[១១:៥២:៣៨]

**សះ** ប៉ុន្តែខ្ញុំសូមកាត់លោកបន្តិច ប៉ុន្តែយើងប្រើពាក្យទូលំទូលាយនៅក្នុងសហគមន៍ ប៉ុន្តែនៅក្នុងផ្នែកសវនាការពេលនេះ យើងមិនទាន់ចូលទៅដល់រឿងប្រល័យពូជសាសន៍ទេ អាហ្នឹងគឺថាជាគំនិត

ដែលចៅក្រមត្រូវពិចារណា។ ខ្ញុំចង់សួរចំណុចមួយទៀត មុននឹងពេលសម្រាកអាហារថ្ងៃត្រង់ គឺថា តួនាទីរបស់លោក ខៀវ សំផន ហើយលោក នួន ជា នៅក្នុងឆ្នាំ១៩៧៥ រហូតដល់ការដួលរំលំនៃរបប នេះក្នុងឆ្នាំ១៩៧៩។ ខ្ញុំចង់ដាក់បរិបទនេះនៅក្នុងលក្ខន្តិកៈបក្សកុម្មុយនីស្តកម្ពុជា តើលោកបានអានយល់ ដឹងអ្វីខ្លះនៅពេលដែលអនុម័តនៅក្នុងឆ្នាំ១៩៧៥? ឯកសារ E3/130 តើលោកធ្លាប់បានឃើញ បានអាន ដែរឬទេ?

**ផ៖** ខ្ញុំមើលមិនឃើញនៅក្នុងអេក្រង់នេះទេ ប៉ុន្តែខ្ញុំពិតជាបានអាន បានឃើញ។

**ស៖** ឥឡូវនេះ ខ្ញុំនឹងមើលនៅក្នុងរចនាសម្ព័ន្ធលក្ខន្តិកៈនេះដែលគេនិយាយអ្វីខ្លះ។ មហាសន្និបាត នោះ "គឺត្រូវ -- គឺជាអង្គការមួយរបស់បក្សដែលមានអំណាចខ្ពស់បំផុតទូទាំងប្រទេស តំណាងប្រទេស ទាំងមូល។ គណៈអចិន្ត្រៃយ៍របស់បក្សត្រូវកោះប្រជុំមហាសន្និបាតរៀងរាល់ឆ្នាំ ប៉ុន្តែគេអាចជួបប្រជុំ ញាប់ជាងនេះបាន"។ តើលោកដឹងដែរឬទេអំពីមហាសន្និបាតញឹកញាប់ជាងម្តង ដែលគេបានប្រជុំលើក ទី១ ពេលឆ្នាំដែលគេប្រតិបត្តិការដែរឬទេ?

[១១:៥៤:៣៦]

**ផ៖** បាទ។ លោកស្រីចង់ប្រើពាក្យគឺថា "មហាសន្និបាត" ប៉ុន្តែខ្ញុំចង់ប្រើពាក្យថា "ប្រជុំសមាជ របស់បក្ស" ប៉ុន្តែតាមខ្ញុំគិត គឺថាមានប្រជុំធំៗបែបនេះបី។ ខ្ញុំសូមមើលឯកសារខ្ញុំ បាទទី -- ឆ្នាំ៧៦ ទី៥ ហើយនិងឆ្នាំ៧៨ គឺក្នុងឆ្នាំ៧៨ បាទ អ៊ីចឹងមានបីដង។ អ៊ីចឹង គឺថាអំពីមហាសន្និបាត គឺថាគណៈ អចិន្ត្រៃយ៍នោះ គឺថាជាអង្គការខ្ពស់បំផុតទូទាំងប្រទេស ហើយខ្លួនមានអង្គការចាត់តាំង ហើយនិងការ អនុវត្តមាគ៌ាបក្ស ហើយនិងលក្ខន្តិកៈបក្សទូទាំងប្រទេស។ ខ្លួនមានកាតព្វកិច្ចក្នុងការណែនាំទៅភូមិភាគ ទៅតំបន់ ហើយនិងអង្គការបក្ស ហើយនិងគោលការណ៍បក្ស ហើយនិងជំហរ គោលជំហរការពារបក្ស ហើយនិងការពារបដិវត្តន៍របស់ប្រទេស ដើម្បីគ្រប់គ្រងកម្មាភិបាល ហើយនិងសមាជិកបក្ស ទូទាំងបក្ស។ ហើយមាត្រា៨ សូមដកស្រង់ "ផ្នែកនៅអង្គភាពដែលមានចរិតលក្ខណៈពិសេស ជានយោបាយ ជាយោធា សេដ្ឋកិច្ច ឬក៏វប្បធម៌ កិច្ចការសង្គមនោះ អាចនឹងត្រូវបានរៀបចំ ដាច់ដោយឡែកនៅក្នុង គណៈមជ្ឈិម ដោយផ្ទាល់ ឬដោយប្រយោល ទៅតាមមាគ៌ាចាត់តាំងជាក់លាក់"។ សូមចងចាំថា វិធីសាស្ត្រខុសគ្នាៗ ដែលគណៈអចិន្ត្រៃយ៍ -- គណៈមជ្ឈិមគេបានធ្វើនោះ គឺថាតើលោកដឹងអំពីបណ្តាញ ទំនាក់ទំនង និងរចនាសម្ព័ន្ធរវាងថ្នាក់មជ្ឈិម ទៅមន្ទីរស-២១ តើលោកបានដឹងអ្វីខ្លះ?

ប្រតិចារឹកដែលត្រូវបានកែតម្រូវ។ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។

[១១:៥៦:៥២]

**ឆ៖** អ្វីដែលលោកស្រីទើបតែបានអាននេះ អំពីលក្ខន្តិកៈនោះ គឺជាទ្រឹស្តីតាក់តែងជាទ្រឹស្តី ប៉ុន្តែមិនមាននៅក្នុងការពិតទេ។ ដូចជានិយាយអំពីរដ្ឋសភារបស់គេអ៊ីចឹងដែរ គឺថាមានអង្គភាពដែលធ្វើការងារជារៀងរាល់ថ្ងៃនោះ មានតែគណៈអចិន្ត្រៃយ៍ទេ។ លោកស្រីនិយាយថា អំពីស-២១ គឺថាគណៈកម្មាធិការខាងសន្តិសុខ គឺថាជាក្រុមមនុស្សមួយក្រុមតូច ដែលមានសមាជិកមួយចំនួនតូច។ បើយើង -- យើងឃើញថា វាមានការកើនសមាជិក កាលណាពេលហ្នឹង វាវិវត្តន៍ទៅមុខ នៅពេលដែល នួន ជា និង ប៉ុល ពត ជាអ្នកសម្រេច មិនមែនគណៈអចិន្ត្រៃយ៍ទេ។ ប៉ុន្តែគណៈមជ្ឈិមគឺថាអាចប្រជុំបីដងក្នុងចន្លោះ១៩៧៥ ដល់ ១៩៧៩ ហើយមួយផ្នែកនោះ គឺគេធ្វើការនៅក្នុងកិច្ចប្រជុំ។ មួយផ្នែកនោះ គឺធ្វើការប្រជុំដើម្បីពិនិត្យមើលសេចក្តីសម្រេចដែលគណៈមជ្ឈិមបានសម្រេចហើយនោះ។ ប៉ុន្តែស-២១ គឺថាមិនស្ថិតនៅក្រោមគណៈអចិន្ត្រៃយ៍ គណៈមជ្ឈិមទេ គឺស្ថិតនៅក្នុងគណៈសន្តិសុខ ដែលស្ថិតនៅក្រោម សុន សេន, ប៉ុល ពត និង នួន ជា។

**ស៖** ខៀវ សំផន ក៏បានស្ថិតនៅក្នុងគណៈអចិន្ត្រៃយ៍នៃកម្ពុជាប្រជាធិបតេយ្យ គឺថាក្នុងប៉ុន្មានឆ្នាំមុនពេលឆ្នាំ១៩៧៥ ចុះ ខៀវ សំផន ដូចម្តេចដែរ?

[១១:៥៨:៤០]

**ឆ៖** នួន ជា ជាសមាជិកគណៈអចិន្ត្រៃយ៍ តាំងពីឆ្នាំ១៩៦០។

**ស៖** ខ្ញុំនិយាយអំពីគណៈមជ្ឈិម តើធ្វើឱ្យលោកច្រឡំដែរឬទេ?

**ឆ៖** ខៀវ សំផន បានក្លាយជាសមាជិកត្រៀម ឬក៏ជាសមាជិកគ្មានសិទ្ធិបោះឆ្នោតនៃគណៈមជ្ឈិមឆ្នាំ១៩៧៣ បើសិនជាខ្ញុំចាំមិនខុសទេ។ គាត់ក្លាយជាសមាជិកពេញសិទ្ធិបន្ទាប់ពីឆ្នាំ១៩៧៥ នៅពេលដែលគាត់មានសិទ្ធិបោះឆ្នោតនៅក្នុងគណៈមជ្ឈិមនោះ។ នេះជាគណៈមួយ ជាក្រុម ជាអង្គការដែលផ្តល់អ្វីដែលជាការអនុវត្តដែលសម្រេចនៅក្នុងគណៈអចិន្ត្រៃយ៍រួចហើយនោះ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណលោកស្រីចៅក្រម។ អរគុណអ្នកជំនាញ។

បាទ ឥឡូវដល់ពេលសម្រាកថ្ងៃត្រង់ហើយ អង្គជំនុំជម្រះប្រកាសចាប់ពីពេលនេះទៅ រហូតដល់ម៉ោងមួយសាមសិបនាទីរសៀលនេះ សូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការ។

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលផ្តល់កន្លែងសម្រាកនៅបន្ទប់រង់ចាំសម្រាប់សាក្សី និងអ្នកជំនាញ ឬកន្លែងសមស្របនៅក្នុងបរិវេណនៃ អ.វ.ត.ក នេះ ដល់អ្នកជំនាញនៅក្នុងអំឡុងពេលឈប់សម្រាក និងឲ្យអញ្ជើញគាត់ត្រឡប់មកកាន់កន្លែងផ្តល់សក្ខីកម្មនេះវិញ នៅវេលាម៉ោងមួយសាមសិបនាទី។

បង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនលោក ខៀវ សំផន ទៅបន្ទប់រង់ចាំខាងក្រោមសាលសវនាការនេះ ហើយនិងឲ្យនាំគាត់ត្រឡប់មកកាន់កន្លែងផ្តល់សក្ខីកម្ម អ៎! មកចូលរួមនៅក្នុងសវនាការនៅក្នុងបន្ទប់សវនាការនេះវិញនៅរសៀលឲ្យបានមុនម៉ោងមួយសាមសិបនាទី។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១២:០០ នាទី ដល់ម៉ោង ១៣:៣០ នាទី)*

[១៣:៣០:៤២]

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ និងផ្តល់វេទិកាជូនទៅលោកស្រីចៅក្រម ស៊ីលវៀ ខាតវ៉ាយថ៍ ដើម្បីបន្តការតាំងសំណួរដេញដោលចំពោះអ្នកជំនាញ។ សូមអញ្ជើញ!

**ចៅក្រម ស៊ីលវៀ ខាតវ៉ាយថ៍៖**

សូមអរគុណលោកប្រធាន។

**សួរដោយចៅក្រម ស៊ីលវៀ ខាតវ៉ាយថ៍៖**

**ស៖** ក្នុងពេលដែលគណៈអចិន្ត្រៃយ៍ត្រូវបានបង្កើតតាមលក្ខន្តិកៈ គណៈអចិន្ត្រៃយ៍មិនត្រូវបានបង្កើតដោយលក្ខន្តិកៈនោះទេ តើនេះជាការយល់ដឹង ហើយនិងអ្វីដែលលោករកឃើញអ៊ីចឹងដែរឬទេ?

**លោក ហ្វីលីព ស្សូត៖**

**ឆ៖** គណៈអចិន្ត្រៃយ៍ ខ្ញុំយល់ថាត្រូវបានបង្កើតដោយលក្ខន្តិកៈទោះបីជាយោងទៅក្នុងលក្ខន្តិកៈដែលលោកស្រីទើបលើកឡើងក្នុងឆ្នាំ១៩៧៥នោះ ខ្ញុំមិនប្រាកដទេ ប៉ុន្តែគណៈអចិន្ត្រៃយ៍ត្រូវបានបង្កើតឡើងតាំងពីដំណាក់កាលដំបូងនៃបក្សកុម្មុយនីស្តកម្ពុជា។ បន្ទាប់ពីសន្និបាតឆ្នាំ១៩៦៣ គឺពីក្រោយឆ្នាំ១៩៦០ មកគឺចាប់តាំងពីពេលហ្នឹងគឺថាត្រូវមានគណៈអចិន្ត្រៃយ៍ជាស្ថាប័នតូចមួយរបស់បក្សកាលនោះ។

[១៣:៣២:០២]

**ស៖** ហើយបន្ទាប់ពីខែមេសា ឆ្នាំ១៩៧៥ និយាយពីការបង្កើតនូវគណៈអចិន្ត្រៃយ៍ថ្មីនោះ តើអ្នកណាជាប្រធាននៃគណៈអចិន្ត្រៃយ៍នេះ?

**ឆ៖** លេខានៃគណៈអចិន្ត្រៃយ៍គឺ ប៉ុល ពត ចាប់តាំងពីឆ្នាំ១៩៦៣មក។ ក្រោយមកគាត់ក្លាយទៅជាលេខាបក្ស គឺថាមានភាពខុសគ្នារវាងប្រធានគណៈអចិន្ត្រៃយ៍ ហើយនិងលេខបក្ស។ នួន ជា ចាប់ពីឆ្នាំ១៩៦៣ គឺថា ក្រោយមកគាត់ក្លាយទៅជាអនុលេខា។

**ស៖** ហើយអ្នកទាំងពីរនាក់នេះ គឺជាសមាជិកនៃគណៈអចិន្ត្រៃយ៍ ខ្ញុំនិយាយពីសម័យកាលមុនឆ្នាំ១៩៧៥?

**ឆ៖** អ្នកទាំងពីរ ទាំងមុន ហើយនិងទាំងក្រោយឆ្នាំ១៩៧៥ ពួកគាត់មានសមាជិកភាពនៅក្នុងគណៈអចិន្ត្រៃយ៍។

**ស៖** នៅក្នុងឯកសារដែលបានដាក់ដេញដោលនៅចំពោះមុខអង្គជំនុំជម្រះដោយ ក្រេក អេតឆេសាន់ នោះមានចំណងជើងថា "ទស្សនៈអំពីឋានានុក្រមនៃបក្សកុម្មុយនីស្តកម្ពុជា" គឺE3/494 គឺថាគណៈអចិន្ត្រៃយ៍ក៏ជាគណៈដែលមានមន្ទីរមួយ៨៧០ដែលដំណើរការជាស្ថាប័នកំពូលមួយនៃបក្សកុម្មុយនីស្តកម្ពុជា។ តើលោកយល់ស្របដូចគាត់នោះដែរឬទេ?

[១៣:៣៣:៥៥]

**ឆ៖** ខ្ញុំយល់ស្របមួយផ្នែក គឺថាអង្គការគឺជាពាក្យមួយដែលគេប្រើដោយបក្សកុម្មុយនីស្តខ្មែរជារួម ដោយសមាជិករបស់ខ្លួនជាពិសេសនៅសម័យកាលពីដំបូងដែលគេដំណើរការជាសម្ងាត់នោះ។ ក្រោយមក គឺគេប្រើក្នុងជាទូទៅដែលប្រជាជនគេដឹង។ មន្ទីរ៨៧០ ជាលេខកូដរបស់គណៈអចិន្ត្រៃយ៍នោះឯង ជាមន្ទីររបស់គេ។

**ស៖** ចម្លើយរបស់គាត់ទៅសហចៅក្រមស៊ើបអង្កេត។ ខៀវ សំផន និយាយថាជាគោលការណ៍គណៈមជ្ឈិម គឺជាស្ថាប័នដ៏សំខាន់បំផុត។ ប៉ុន្តែតាមពិតគណៈអចិន្ត្រៃយ៍ទេដែលខ្លាំង។ យើងអាចប្រៀបធៀបទៅនឹងរដ្ឋសភា ហើយនិងរដ្ឋាភិបាលដែលនៅក្នុងរបបរដ្ឋសភានិយមនោះ ដែលថាគេធ្វើការងារប្រចាំថ្ងៃរបស់រដ្ឋ។ ដូច្នេះគណៈអចិន្ត្រៃយ៍ -- គណៈមជ្ឈិមមិនមានអំណាចដូចគណៈអចិន្ត្រៃយ៍នោះទេ។ តើលោកយល់ស្របជាមួយចម្លើយរបស់ ខៀវ សំផន បែបនេះដែរឬទេ?

[១៣:៣៥:១០]

**ផ៖** បាទ លើកលែងតែចំណុចមួយនៅក្នុងរបបសភានិយមគឺថា សភាជាអ្នកត្រួតត្រាលើរដ្ឋាភិបាល ប៉ុន្តែក្នុងរបបខ្មែរក្រហម គណៈមជ្ឈិមមិនប្រើសិទ្ធិត្រួតត្រាលើគណៈអចិន្ត្រៃយ៍ទេ។

**ស៖** តើលោកដឹងអំពីតួនាទី និងមុខងាររបស់គណៈអចិន្ត្រៃយ៍ដែរឬទេ? ហើយខ្ញុំនឹងសួរសំណួរមួយចំនួន ហើយថាតើលោកយល់ស្របឬអត់? ទី១ គណៈអចិន្ត្រៃយ៍មានអំណាចចាត់តាំងមន្ត្រីខ្ពស់ៗឲ្យចូលបក្ស រដ្ឋាភិបាល ហើយនិងយោធា ហើយមានអំណាចតាមដាន ហើយនិងការអនុវត្តនូវមាគ៌ា ឬនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជា?

**ផ៖** គណៈអចិន្ត្រៃយ៍មានអំណាចនោះ ប៉ុន្តែការអនុវត្តជាប្រព័ន្ធនោះក្នុងការតាមដានពិនិត្យសកម្មភាពនោះគឺជាបញ្ហាមួយផ្សេងទៀត។

[១៣:៣៦:២១]

**ស៖** នៅក្នុងកំណត់ហេតុថ្ងៃទី០៩ តុលា ឆ្នាំ១៩៧៥ របស់គណៈអចិន្ត្រៃយ៍ E3/182 ការប្រជុំដែលលោក ខៀវ សំផន ហើយនិងលោក នួន ជា បានគេកត់ត្រាថាគាត់មានវត្តមាននោះ គឺគេបានសម្រេច ដើម្បីដាក់នូវផែនការ យើងត្រូវសុំយោបល់ពីគណៈអចិន្ត្រៃយ៍ដើម្បីសម្រេច ហើយនិងផ្តល់ការឯកភាព។ កំណត់ហេតុនោះក៏បានកត់ត្រាថា កាលណាការងារមិនត្រូវផ្តោតតែលើគណៈអចិន្ត្រៃយ៍ទេ គឺ -- ខ្លួននឹងតាមដានផ្នែកនៅតាមមាគ៌ានីមួយៗ ហើយទទួលរបាយការណ៍អំពីស្ថាប័នដែលអនុវត្តគ្រប់មជ្ឈដ្ឋានទាំងអស់ ហើយនិងយោធាផងដែរ តើនេះជាអ្វីដែលឆ្លុះបញ្ចាំងសមស្របទៅនឹងអ្វីដែលលោកបានឆ្លើយដែរទេ? និយាយអំពីមុខងាររបស់គណៈអចិន្ត្រៃយ៍ ហើយនិងតួនាទីទាក់ទងទៅនឹងស្ថាប័នផ្សេងៗទៀតដូចជាតំបន់ ភូមិភាគផ្សេងៗដែលនៅក្រោមខ្លួននោះដែរឬទេ?

**ផ៖** បាទ។

**ស៖** គណៈអចិន្ត្រៃយ៍ក៏បានបញ្ជាក់នៅក្នុងកំណត់ហេតុនេះដែរថា អ្នកដែលទទួលការទទួលខុសត្រូវការងារ ហើយនិងការអនុវត្តការងារសកម្មភាពដូចជា នួន ជា កិច្ចបក្ស ហើយនិងកិច្ចរដ្ឋ ហើយលោក ខៀវ សំផន ចលនារណសិរ្ស ហើយនិងរដ្ឋាភិបាលត្រូវតែរាយការណ៍ទៅឲ្យគណៈអចិន្ត្រៃយ៍ តើនេះជាអ្វីដែលលោកបានដឹងអំពីទំនាក់ទំនងរវាងគណៈអចិន្ត្រៃយ៍ ហើយនិងសមាជិកនីមួយៗដែរឬទេ?

[១៣:៣៨:២៩]

**ឆ៖** នេះជាសំណួរពិបាកណាស់ ខ្ញុំមិនព្យាយាមជៀសវាងមិនផ្តល់ចម្លើយច្បាស់លាស់នោះទេ ខ្ញុំមិនគិតថាមាននរណាម្នាក់ទេ លើកលែងតែសមាជិកនៅក្នុងគណៈអចិន្ត្រៃយ៍ទេដែលអាចមានសិទ្ធិប្រាស្រ័យទាក់ទងក្នុងតួនាទីរបស់គេ។ ខ្ញុំអាចឃើញថា នួន ជា អាចរាយការណ៍ទៅកម្មាភិបាលរួមទេ ពីព្រោះថាគាត់នៅក្នុងកម្មាភិបាលមួយដែលកម្រិតខ្ពស់ជាអនុលេខា។ គាត់និង ប៉ុល ពត គឺបែងចែកតួនាទីរវាងគាត់ទាំងពីរគឺថាចំពោះទិដ្ឋភាពផ្សេងៗ ការងារផ្សេងៗ។ សមាជិកផ្សេងៗទៀតក៏តែងតែរាយការណ៍ ជាពិសេស ជាសំខាន់នោះគឺថាមានការប្រជុំគណៈអចិន្ត្រៃយ៍ ខៀវ សំផន ឬក៏សមាជិកផ្សេងទៀតអាចនឹងរាយការណ៍នៅក្នុងគណៈអចិន្ត្រៃយ៍ ប៉ុន្តែ ប៉ុល ពត ហើយនិង នួន ជា ក្នុងកម្រិតមួយនោះគឺគាត់មិនរាយការណ៍ទៅអ្នកផ្សេងទេ។ ដូច្នេះ គឺថាអាចនឹងរចនាសម្ព័ន្ធ ឋានានុក្រមនោះក្នុងកម្រិតដូចខ្ញុំនិយាយ។

**ស៖** ត្រឡប់ទៅនឹងលក្ខន្តិកៈបក្សវិញ កងទ័ពបដិវត្តន៍កម្ពុជាគឺមានតួនាទី ជាពិសេសគេបានចែងយោងនៅក្នុងលក្ខន្តិកៈដែលនិយាយថា ស្ថិតនៅក្រោមៗអំណាចផ្តាច់មុខរបស់បក្សកុម្មុយនីស្តកម្ពុជា ហើយក៏ត្រូវរាយការណ៍ទៅឲ្យគណៈអចិន្ត្រៃយ៍នោះផងដែរ។ តើអ៊ីចឹងដែរឬទេ?

**ឆ៖** បាទ មេបញ្ជាការ ហើយនិងមេដឹកនាំតំបន់ ភូមិភាគ បញ្ជូនតួលេខទៅមន្ទីរ៨៧០។ នេះហើយជាខ្សែនៃការរាយការណ៍។

[១៣:៤០:២៧]

**ស៖** ហើយសាខាផ្សេងទៀត ស្ថាប័នផ្សេងទៀតរបស់រដ្ឋាភិបាលនោះ នៅក្នុងកម្ពុជាប្រជាធិបតេយ្យគឺដូចជាមាន -- ដែលគេនិយាយអំពីអំណាចតុលាការនោះ ប៉ុន្តែនៅក្នុងការបង្កើត យើងមិនឃើញមានទេ ប៉ុន្តែប្រកាសព័ត៌មានដែលគេចេញដោយ ប្រកាសដោយសភានៅថ្ងៃទី១៤ ខែមេសា ឆ្នាំ១៩៧៤ នៅក្នុងឯកសារ E3/262 គឺមានការបញ្ជាក់យ៉ាងទូលំទូលាយអំពីអំណាចតុលាការនោះ។ នៅក្នុងចំណុចមួយដែលគេនិយាយថា “សភាតែងតាំងគណៈកម្មាធិការយុត្តិធម៌ គឺប្រធានឈ្មោះ កង ចាប”។ តើលោកបានពិភាក្សាអំពីការបង្កើតគណៈយុត្តិធម៌ ឬក៏តុលាការដែលមានប្រព័ន្ធតុលាការរបស់កម្ពុជាប្រជាធិបតេយ្យ ក្នុងកម្រិតណាមួយដែលលោកបានសម្ភាសជាមួយអ្នកផ្តល់សម្ភាសនោះដែរឬទេ?

[១៣:៤១:៣២]

**ផ៖** តាមអ្វីដែលខ្ញុំចាំបំផុត គឺអត់បានឮទេ ដោយមានមូលហេតុមួយគឺមិនមានអំណាចតុលាការ មិនមានប្រព័ន្ធតុលាការទេនៅក្នុងសម័យកាលនោះ។ ហើយខ្ញុំមិនបានចាប់អារម្មណ៍ដើម្បីលើកបញ្ហានេះ មកពិភាក្សាដែរ ដោយដឹងថាមិនមានបែបនេះ។

**ស៖** ស្ថាប័នផ្សេងៗទៀតដែលខ្ញុំបានបញ្ជាក់ដោយសង្ខេបជាពិសេសដោយហៅថាមហាសន្និបាត របស់គណៈមជ្ឈិម ហើយនិងការបង្កើតស្ថាប័នផ្សេងទៀត។ ថាតើការរៀបចំចាត់ចែងការងាររបស់ របបកម្ពុជាប្រជាធិបតេយ្យ ថាតើស្ថាប័នទាំងអស់នោះ ត្រូវរៀបចំធ្វើកិច្ចការ មានដំណើរការដូចម្ដេច លើកលែងតែស្ថាប័នតុលាការមួយដែលលោកថាមិនមានបង្កើតនោះ?

**ផ៖** កងទ័ព ឬក៏យោធាហ្នឹង គឺថាក្រោមក្រសួងការពារប្រទេស គឺលោក សុន សេន ជារដ្ឋមន្ត្រី។ ពួកគេជាមេបញ្ជាការ ទាំងអស់នោះ គេមិនមែនជាសមាជិកពេញសិទ្ធិ ប៉ុន្តែជាសមាជិកត្រៀម។ ក៏ប៉ុន្តែវាមានបញ្ហាមួយដែលថា ទាក់ទងថាតើមានភាពឯករាជ្យភាពក្នុងការធ្វើសេចក្ដីសម្រេចនៅក្នុង ស្ថាប័ននីមួយៗនៅក្នុងគណៈរដ្ឋមន្ត្រីរបស់គេហ្នឹងដែរឬអត់។ គេនិយាយថាមានគណៈរដ្ឋមន្ត្រី គេចាត់ តាំងមនុស្សរដ្ឋមន្ត្រីនេះរដ្ឋមន្ត្រីនោះជាដើម ប៉ុន្តែអ្វីដែលខ្ញុំយល់គឺសេចក្ដីសម្រេចទាំងអស់ គឺថាត្រូវធ្វើ ឡើងនៅក្នុងរចនាសម្ព័ន្ធរបស់បក្ស គឺគណៈអចិន្ត្រៃយ៍ ហើយរដ្ឋាភិបាលទោះបីជាមានក្រសួងក្ដីក្នុង កម្រិតក្រសួងខ្លះខ្លាំងជាងក្រសួងខ្លះក៏ដោយ គឺថាគេធ្វើតួនាទីគ្រាន់តែបញ្ជូនអំណាចភារកិច្ចប៉ុណ្ណោះ គឺ មិនមែនតួនាទីជាក្រសួងពិតប្រាកដនោះទេ។

[១៣:៤៣:៣៧]

**ស៖** ឥឡូវនេះ យើងយោងទៅរក ខៀវ សំផន និង នួន ជា ទាក់ទងទៅនឹងតួនាទី ហើយនិងមុខ ងាររបស់គាត់នៅក្នុងរចនាសម្ព័ន្ធ។ នៅឆ្នាំ១៩៧៥ -- សូមកែតម្រូវ ឆ្នាំ១៩៧៦ ទេ, គាត់ត្រូវបានគេតាំង ឲ្យមានតួនាទីជាផ្លូវការរួចទៅហើយនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។ ជាឧទាហរណ៍ នៅក្នុងកំណត់ ហេតុថ្ងៃទី៣០ មីនា ឆ្នាំ១៩៧៦ របស់គណៈអចិន្ត្រៃយ៍នោះ E3/12 ដែលមានចំណងជើងថា "សេចក្ដី សម្រេចរបស់គណៈអចិន្ត្រៃយ៍ និងបញ្ហាមួយចំនួន" គេបាន -- ត្រូវបានចាត់តាំងគាត់ជាប្រធានគណៈ ប្រធានរដ្ឋនៃកម្ពុជាប្រជាធិបតេយ្យ។ ឥឡូវនេះ គឺការទទួលស្គាល់ជាផ្លូវការមុខងាររបស់គាត់នោះ គឺថា ជាប្រមុខរដ្ឋ ដែលគេហៅថាគណៈប្រធាន -- ប្រធានគណៈប្រធានរដ្ឋនោះ។

**ផ៖** បាទ គឺមានអ៊ីចឹងមែនបាទ។

**ស៖** គាត់ជាសមាជិកត្រៀមនៃគណៈមជ្ឈិម ប៉ុន្តែគាត់បានក្លាយទៅជាសមាជិកពេញសិទ្ធិនៅក្នុងឆ្នាំ១៩៧៦នៃគណៈមជ្ឈិម។ តើហ្នឹងជាសេចក្តីសង្ខេបត្រឹមត្រូវអំពីតួនាទីរបស់គាត់ នៅក្នុងគណៈមជ្ឈិមដែរឬទេ?

**ឆ៖** បាទ អ្វីដែលខ្ញុំយល់នោះ គឺ ហើយគាត់ទទួលការតែងតាំងទៅជាសមាជិកពេញសិទ្ធិស្របទៅនឹងពេលដែលគេចាត់តាំងគាត់ជាប្រមុខរដ្ឋនោះឯង។

**ស៖** លោកបាននិយាយថា គាត់មិនត្រូវបានចាត់តាំង -- តែងតាំងទៅក្នុងគណៈអចិន្ត្រៃយ៍ទេ ប៉ុន្តែគ្មានៗកំណត់ហេតុណាមួយនៅក្នុងកិច្ចប្រជុំរបស់គណៈអចិន្ត្រៃយ៍ ដែលបានថែងបែងចែកខុសគ្នាអំពីតួនាទីរបស់គាត់នៅក្នុងគណៈអចិន្ត្រៃយ៍នោះទេ។ តើលោកអាចពន្យល់អ្វីបន្ថែមឲ្យច្បាស់បានដែរឬទេ?

[១៣:៤៦:០២]

**ឆ៖** ខ្ញុំមិនអាចទទួលស្គាល់ថា ខ្ញុំមិនដែលបានឃើញឯកសារណាមួយនោះទេ ហើយខ្ញុំសម្ភាសមនុស្សមួយចំនួនក៏មិនបានដឹងដែលអ្នកនោះអាចនឹងបញ្ជាក់ថា ខៀវ សំផន គឺជាសមាជិកនៃគណៈអចិន្ត្រៃយ៍នោះទេ ប៉ុន្តែវត្តមានរបស់គាត់ គឺថាពិតហើយ គាត់មានវត្តមាន។ ហើយគឺថា បាទ គឺថាបន្តជាតួនាទីដែលគ្រប់គ្រាន់ហើយដែលថា គាត់នៅជិតមេដឹកនាំថ្នាក់កំពូល ហើយបន្តការងារហ្នឹង។ ដូច្នេះការចូលរួមកិច្ចប្រជុំគណៈអចិន្ត្រៃយ៍បន្ទាប់ពីឆ្នាំ១៩៧៥ ត្រូវតែងតែមានគាត់ហើយ។ ប៉ុន្តែខ្ញុំមិនអាចនិយាយថា តួនាទីក្នុងការធ្វើសេចក្តីសម្រេចជាសមាជិកនៃគណៈអចិន្ត្រៃយ៍ពេញសិទ្ធិនោះ ខ្ញុំមិនគិតថាបែបនោះទេ។ ប៉ុន្តែគាត់មានតួនាទីមួយទៀតដែលថាជាបញ្ញវន្ត ប៉ុន្តែគាត់មិនបានក្លាយមកពីគណៈភូមិភាគអ្វីពីមុន ដើម្បីបានតួនាទីដូចជាអ្នកផ្សេងទេ។ ប៉ុន្តែដូច នួន ជា ដូចអីគឺ គាត់នៅក្នុងស្នូល ដែលជាអ្នកដឹកនាំនៅក្នុងបក្សនោះ។ គាត់មានតួនាទីមួយ ប៉ុន្តែជាតួនាទីផ្សេងដែលយើងអាចយល់បានក្នុងសមត្ថភាពរបស់គាត់នោះឯង។

[១៣:៤៧:៣៣]

**ស៖** ខ្ញុំចង់មើលអ្វីដែលគាត់និយាយអំពីតួនាទីរបស់គាត់ ដែលយើងបានពិនិត្យពេលនេះ។ ឥឡូវនេះត្រឡប់ទៅរកសៀវភៅផ្ទាល់ខ្លួនរបស់គាត់ ឯកសារ E3/18 គាត់និយាយថា -- អង់គ្លេស 00103749, ខ្មែរ 00103837 ហើយបារាំង 00595426។ គាត់ ហ៊ូ យន់ ហើយ ហ៊ូ នឹម មិនបាន

ដឹកនាំកម្លាំងទេ គាត់និយាយថា "យើងគ្រាន់តែជាតួអង្គមួយក្នុងចលនាខ្មែរក្រហមមិនមានតួនាទីអ្វីនៅក្នុងថ្នាក់ដឹកនាំចលនា ឬក៏ធ្វើសេចក្ដីសម្រេចសំខាន់អ្វីទេ"។ នៅពេលដែលលោកបានពិភាក្សា ឬពេលដែលលោកសម្ភាសគាត់ តើលោកបាននិយាយជាមួយគាត់អំពីអ្វីដែលគាត់យល់ពីតួនាទីរបស់គាត់ទេ? ក្នុងឋានៈជាការចូលរួមនៅក្នុងគណៈអចិន្ត្រៃយ៍ ហើយនិង -- ហើយការវត្តមាននៅគណៈអចិន្ត្រៃយ៍ហ្នឹង ហើយលោកបានសួរគាត់ឲ្យគាត់បំភ្លឺពីរឿងហ្នឹងដែរឬទេ?

**ឆៈ** ខ្ញុំមិនបានចាំថាបានពិភាក្សាជាមួយគាត់ អំពីថាគាត់ចូលរួមវត្តមាននៅក្នុងការប្រជុំគណៈអចិន្ត្រៃយ៍ ឬគណៈមជ្ឈិមនោះទេ។ តាមពិត គាត់និយាយថា គាត់ប្រើពាក្យថាជាសមាជិកដូចស្រដៀងដូចពាក្យលោកស្រីចៅក្រមបានលើកឡើងហ្នឹង គឺថា ទាំងបី គឺហ៊ូ នឹម, ហ៊ូ យន់ និង ខៀវ សំផន នោះគឺជាតួអង្គមួយ ជាថ្នាក់ដឹកនាំមួយ គឺថា ហើយនិងអាចនឹងជាការពិតដែលថា ពួកគាត់ទាំងបីហ្នឹង មិនមានតួនាទីជាយោធាទេ ក៏ប៉ុន្តែបើមើលក្នុងករណីដូចគ្នានេះវិញ វាមានបញ្ហាក្រោយមកដែលអាចនឹងទាក់ទងថា តើមុខងាររបស់គាត់នៅក្នុងមន្ទីរទូទៅរបស់គណៈអចិន្ត្រៃយ៍នោះវាយ៉ាងដូចម្ដេច? ប៉ុន្តែជាថ្មីម្ដងទៀត យើងមិននិយាយអំពីសេចក្ដីសម្រេច តួនាទីធ្វើសេចក្ដីសម្រេចទេ។ យើងនិយាយពីតួនាទីក្នុងនីតិប្រតិបត្តិក្នុងការអនុវត្តនោះ។

[១៣:៥០:០៩]

**សៈ** ហើយលោកយោងទៅរក គឺថាការប្រព្រឹត្តទៅនៃមន្ទីរ៨៧០ ដែលនិយាយនៅក្នុងសៀវភៅរបស់គាត់នោះគឺថា"ខ្ញុំទទួលខុសត្រូវចំពោះទំនាក់ទំនងជាមួយព្រះមហាក្សត្រ ហើយនិងព្រះជាយា" ហើយនិងពិនិត្យមើលតារាងតម្លៃដែលបញ្ជូនមកពីសហករណ៍ ហើយនិងអង្គភាពសេដ្ឋកិច្ច ហើយគាត់ក៏ទទួលខុសត្រូវក្នុងការអនុវត្តសេចក្ដីសម្រេចរបស់គណៈអចិន្ត្រៃយ៍ ដែលទាក់ទងទៅនឹងការចែកចាយផលិតផលដែលប្រមូលនៅភ្នំពេញ ចែកទៅនឹងភូមិភាគ ហើយនិងតំបន់ផ្សេងៗ ហើយធ្វើការជាមួយមន្ទីរការបរទេស ដើម្បីនាំចូលនូវទំនិញមួយចំនួន។ នេះគឺថាទំនងជាបង្ហាញថា គាត់មានការទទួលខុសត្រូវមានកម្រិតមួយ ហើយសមាជិកនៅក្នុងគណៈមជ្ឈិម មជ្ឈិមបក្សនោះ ដូចជាការចូលរួមក្នុងកិច្ចប្រជុំមួយចំនួននៅក្នុងគណៈអចិន្ត្រៃយ៍ គឺថាមិនមានសារៈសំខាន់អ្វីធំដុំទាក់ទងទៅនឹងការងាររបស់គាត់ តួនាទីរបស់គាត់។ តើលោកយលស្របអ៊ីចឹង ឬក៏យ៉ាងម៉េច?

[១៣:៥១:២៥]

**ផៈ** ខ្ញុំមិនយល់ស្របជាមួយនឹងពាក្យថា "មិនមានសារៈសំខាន់ធំដុំ" នោះទេ។ តាមពិតគឺគាត់មានវត្តមាននៅទីនោះ។ គឺគ្រាន់តែវត្តមានខ្លួនឯងហើយ គឺថាវាមានសារៈសំខាន់ហើយ ព្រោះថានៅក្នុងក្រុមនេះ ជាក្រុមមនុស្សចំនួនតូចតែប៉ុណ្ណោះ បាទ។ មិនមែនចាំបាច់ថា ដើម្បីមានឥទ្ធិពលលើសេចក្ដីសម្រេចនោះទេ យ៉ាងហោចណាស់ គឺថាអ្នកស្ថិតនៅក្នុងក្រុមមនុស្សមួយក្រុមតូចដែលមានសិទ្ធិអំណាចខ្ពស់បំផុត។ នៅពេលដែលយើងនិយាយអំពីមន្ទីរទូទៅ ខ្ញុំមិនចង់និយាយពីមន្ទីរ៨៧០ទេ គឺថាខ្ញុំនិយាយពីដូចមន្ទីរទូទៅមួយដែលដឹកនាំដោយ ខៀន ដែលក្រោយមក ខៀវ សំផន ដើរតួជំនួសនោះ។ ដូចជាសេនាធិការប្រតិបត្តិមួយរបស់មន្ទីរ៨៧០នោះឯង។ ដូចដែលខ្ញុំ គឺថាគាត់មានតួនាទីនីតិប្រតិបត្តិ បានន័យថាតួនាទីអនុវត្ត។ ការងារគាត់ រឿងៗអំណាចធ្វើសេចក្ដីសម្រេច ខ្ញុំពិបាកនឹងនិយាយណាស់ចំពោះគាត់នេះ។

[១៣:៥២:៣០]

**សៈ** ឥឡូវនេះ ខ្ញុំចង់នាំលោកទៅអំពីកំណត់ហេតុដែលនៅសេសសល់របស់គណៈអចិន្ត្រៃយ៍ ហើយគ្រាន់តែសង្ខេបខ្លីៗ ពីប្រធានបទដែលបានពិភាក្សានៅក្នុងកិច្ចប្រជុំទាំងអស់នេះ ហើយនីមួយៗនៅក្នុងនេះ កំណត់ត្រានីមួយៗនោះ ដែលលោក ខៀវ សំផន ហើយ នួន ជា បានវត្តមាននោះ បានចូលរួមនោះ។ ខ្ញុំនឹងនិយាយទី១ អំពីកំណត់ហេតុចុះថ្ងៃទី០៨ មីនា ឆ្នាំ១៩៧៦, E3/231 ហើយនិងប្រធានបទដែលនិយាយក្នុងកិច្ចប្រជុំនោះ។ មួយទៀត គឺនៅថ្ងៃដដែល គឺ E3/232 ទាក់ទងនឹងការងារមូលដ្ឋាន។ ទាក់ទងក្នុងកិច្ចប្រជុំនោះ លោក ខៀវ សំផន រាយការណ៍បញ្ហាទាក់ទងនឹងការបោះឆ្នោត ហើយនិងវិធីសាស្ត្រនៃការឃោសនា ហើយនិងការអប់រំ។

ថ្ងៃទី១១ មីនា ឆ្នាំ១៩៧៦, E3/197, ទាំង នួន ជា ទាំងលោក ខៀវ សំផន បានវត្តមាន។ នៅពេលដែលសម្ដេច សីហនុ ដាក់ពាក្យលាលែង ហើយដែលលោក ខៀវ សំផន បានរាយការណ៍ពីទស្សនៈរបស់ព្រះមហាក្សត្រ។ ពេលនោះ គឺប៉ុល ពត ជាសមមិត្តលេខា និយាយថា "មិនត្រូវឲ្យសម្ដេចសីហនុ ចេញពីប្រទេសទេ។ គឺត្រូវរក្សាទុកជាឥស្សរជន ប៉ុន្តែមិនត្រូវធ្វើឃាតព្រះអង្គទេ"។

[១៣:៥៤:១២]

ហើយនៅថ្ងៃនោះដែរ ថ្ងៃទី១១ ខែមីនា, E3/217, និងការពិភាក្សាអំពីសេចក្ដីសម្រេច អំពីជម្លោះព្រំដែនដែលថាមានការឈ្លានពានព្រំដែនពីវៀតណាមនៅភូមិភាគបូព៌ា។ ហើយយើងនិយាយអំពី

ការការពារ ហើយនិងវាយការវាយប្រហារ ហើយនិងនិយាយពីបញ្ហានយោបាយ ហើយនិងនិយាយអំពីការចរចាជាបន្តនៅតាមព្រំដែនផងដែរ។

នៅថ្ងៃទី១៣ ខែមីនា គឺថា E3/234 ដែលនិយាយអំពីបញ្ហាពាណិជ្ជកម្ម ហើយបរិបទ គឺប្រទេសចិន។ ការបង្កើតគណៈប្រតិភូទាក់ទងទៅនឹងការទិញទំនិញមកពីប្រទេសចិន។ ការប្រជុំទាំងអស់នេះ គឺថាពីអំពី ពីបញ្ហាយោធា សេដ្ឋកិច្ច យោធា ត្រូវបានពិភាក្សានៅទីនោះផងដែរ ដែលនៅក្នុងការប្រជុំទាំងនោះមាន នួន ជា, មាន ខៀវ សំផន វត្តមាន។ តើលោកអាចបន្ថែមអ្វីអំពីការកម្រិត ពីកម្រិតនៃការពាក់ព័ន្ធ ការចូលរួម ហើយការដឹងរបស់ពួកគាត់អំពីការប្រព្រឹត្តទៅ ហើយនិងការអនុវត្តការងាររបស់កម្ពុជាប្រជាធិបតេយ្យនោះ?

[១៣:៥៥:៤២]

**ឆ៖** ខ្ញុំនឹងនិយាយអ្វីដែលខ្ញុំលើកឡើងវិញ ដែលខ្ញុំនិយាយពីមុននោះគឺថា ការវត្តមានដែលគាត់នៅក្នុងគណៈអចិន្ត្រៃយ៍ គណៈមជ្ឈិមនោះគឺថា វាជាលក្ខណៈវិសេសហើយ។ វាមិនទាក់ទងទៅថាតើអ្វីដែលលោក ខៀវ សំផន ចូលរួមជាមតិយោបល់អ្វីនោះទេ ទាក់ទងជាលក្ខណៈបុគ្គលនោះ។ ប៉ុន្តែរឿងសំខាន់កំណត់ហេតុកិច្ចប្រជុំ ដូចថានៅខែមីនា ឆ្នាំ១៩៧៦នោះ និយាយថា សមមិត្តហែម ខៀវ សំផន រាយការណ៍អំពីការអប់រំ និងឃោសនា។ បាទ អំពីការបោះឆ្នោតជាដើមហ្នឹង។ ខ្ញុំគិតថានេះហើយជាផ្នែកមួយនៃការទទួលខុសត្រូវរបស់គាត់ ឃោសនា ហើយនិងការអប់រំនេះ គឺមិនទាន់ទងត្រឹមតែការបោះឆ្នោតនោះទេ។ អាចជាភស្តុតាងដែលថា អាចជាសាក្សីដែលគិតថាអាចតទល់គ្នាបាន ជាពិសេសទាក់ទងទៅនឹងការប្រកាសថ្លែងនៅក្នុងការប្រជុំរយៈពេលវែងនៅពហុកីឡដ្ឋានអូឡាំពិកជាដើមហ្នឹង ដែលគាត់បានផ្តល់ការណែនាំខាងមនោគមន៍វិជ្ជាទៅដល់មហាជនជាដើមហ្នឹង។ គឺថាតើបញ្ហាទាក់ទងនឹងកិច្ចការយោធាវិញ អំពីបញ្ហាឈ្លានពាននៅព្រំដែនជាមួយវៀតណាមអីជាដើមហ្នឹង។ ហើយខ្ញុំមិនមានភស្តុតាងអ្វីដាច់ខាតនោះទេ ថាតើគាត់មានភស្តុតាងសំខាន់ដាច់ខាតនោះទេ ប៉ុន្តែគាត់ពេលដែលគេប្រជុំគាត់នៅទីនោះ ប៉ុន្តែខ្ញុំសង្ស័យថាគាត់មិនមានអ្វីនិយាយច្រើនទេពីរឿងយោធានៅពេលនោះ។ ប៉ុន្តែខ្ញុំមានភស្តុតាងថាតើគណៈអចិន្ត្រៃយ៍ហ្នឹងវាធ្វើការដូចម្តេច។

[១៣:៥៧:៣៩]

ប៉ុល ពត នៅក្នុងកិច្ចប្រជុំនោះ គាត់ជាប្រធាន<។> គាត់<តែង>សួរអ្នកផ្សេងៗទៀតឲ្យបង្ហាញយោបល់<លើបញ្ហាសំខាន់នានា ហើយចុងក្រោយ គាត់ដាក់ចេញនូវគោលនយោបាយដែលគាត់បានគ្រោងទុក ដោយដាក់បញ្ចូលយោបល់ខ្លះដែលបានលើកឡើងនៅក្នុងអង្គប្រជុំ។ នេះជាទម្លាប់ដឹកនាំរបស់គាត់។ ហើយខ្ញុំគិតថារឿងសំខាន់នោះគឺ គាត់ពិតជាបញ្ចូលគំនិតយោបល់របស់សមាជិកដទៃដែរ ប៉ុន្តែគោលនយោបាយដែលចេញមកគឺជាគោលនបាយមួយដែលភាគច្រើនបំផុតគាត់បានសម្រេចខ្លួនឯងរួចទៅហើយ តាំងពីពេលមុនការប្រជុំចាប់ផ្តើមម្ល៉េះ។>

**ស៖** មានការប្រជុំមួយទៀត គឺថានៅពេលដែលមានកិច្ចប្រជុំគណៈប្រជុំនៅថ្ងៃទី៣០ ខែមីនា ឆ្នាំ១៩៧៧ នោះគឺថាមានកំណត់ត្រាថាគាត់បានចូលរួម គឺឯកសារ E3/12។ នៅពេលនោះគឺថាលោក ខៀវ សំផន ជាសមាជិកត្រៀមនៃគណៈមជ្ឈិម ហើយជាសមាជិកពេញសិទ្ធិដោយផ្អែកទៅតាមលោកនោះ តាមសក្ខីកម្មរបស់លោក។ ប៉ុន្តែ នួន ជា ជាសមាជិកពេញសិទ្ធិនៃគណៈមជ្ឈិមទៅហើយ។ នេះតាមពិត នេះជាឱកាសដែលយើងបានដឹង គឺថាគេមានសិទ្ធិក្នុងការកម្ទេចខ្មាំងនៅក្នុងជួរ ហើយនិងក្រៅជួរខ្មាំងនោះនៅក្នុងស្ថាប័នដែលមានអំណាចសម្រេចនោះ គឺថាគណៈអចិន្ត្រៃយ៍ភូមិភាគ ហើយនិងតំបន់គណៈអចិន្ត្រៃយ៍ដែលនៅក្នុងនោះ ដែលលោក នួន ជា និង ខៀវ សំផន ជាសមាជិក ហើយគណៈអចិន្ត្រៃយ៍ ហើយនិងសេនាធិការផងដែរ។ ឥឡូវនេះថាតើអាចទៅរួចដែរទេ លោកគិតមើលថាតើបុរសទាំងពីរណាមួយនេះដែលថាពួកគាត់ទាំងពីរហ្នឹងមិនបានដឹង មិនបានឮអំពីសេចក្តីសម្រេចឬក៏ការប្រជុំហ្នឹង ទាំងអស់ហ្នឹងបែបនេះ។ តើអាចទៅរួចទេ?

[១៣:៥៩:៤១]

**ឆ៖** ខ្ញុំប្រាកដថាពួកគាត់ដឹងអំពីសេចក្តីសម្រេចទាំងអស់ហ្នឹង។ ប៉ុន្តែ ខ្ញុំមិនយល់ទាល់តែសោះប៉ុន្តែខ្ញុំឆ្ងល់ សេចក្តីសម្រេចរបស់គណៈមជ្ឈិម។ ខ្ញុំមិនគិតថាកិច្ចប្រជុំរបស់គណៈមជ្ឈិមហ្នឹងបានប្រជុំទេ គឺថាដូច្នេះពាក្យបច្ចេកទេសគឺថាសេចក្តីសម្រេចត្រូវចេញដោយគណៈអចិន្ត្រៃយ៍ទេ។ ប៉ុន្តែខ្ញុំប្រាកដហើយដែលថា លោក ខៀវ សំផន លោក នួន ជា គឺបានដឹងច្បាស់ណាស់ពីអ្វីដែលនៅក្នុងឯកសារនេះនោះ។

**ស៖** លោក ខៀវ សំផន ហើយនិងលោក នួន ជា ហ្នឹងគាត់មានទំនាក់ទំនងបែបម៉េចដែរនៅខាងក្រៅការប្រជុំ? តើលោកអាចបញ្ជាក់បានដែរឬទេអំពីទំនាក់ទំនងរបស់ នួន ជា និង ខៀវ សំផន

នោះ? តើលោកដឹងថា តើពួកគាត់គោរពគ្នាទៅវិញទៅមក ឬមួយក៏គាត់មានទំនាក់ទំនងយ៉ាងម៉េចដែរ តើលោកអាចបញ្ជាក់បានទេ?

**ឆ៖** អ្វីដែលខ្ញុំអាចនិយាយបានគឺថាមានភស្តុតាងបង្ហាញថា ប៉ុល ពត គឺថាគោរពដល់លោក ខៀវ សំផន ខ្ពស់ ប៉ុន្តែខ្ញុំមិនមានឯកសារអ្វីឲ្យច្បាស់លាស់ទេចំពោះលោក នួន ជា គឺគេចាត់ទុកជាមនុស្សពិសេសមួយ ជាអ្នកដែលមិនធម្មតាមួយ។ ទំនាក់ទំនងរវាង នួន ជា ហើយនិង ខៀវ សំផន គឺខ្ញុំអត់មានព័ត៌មានអ្វីទាក់ទងទៅនឹងទំនាក់ទំនងរបស់គាត់ទាំងពីរទេ។

[១៤:០១:១៦]

**ស៖** ផ្អែកទៅតាមលោក អេតឆេសាន់ គឺថាមានមន្ទីរមួយដែលនៅព្រឹត្តិបត្តិក្រោមមន្ទីរ៨៧០ ដែលគេចាប់ផ្តើមដោយអក្សរ "ក"។ ហើយ ប៉ុល ពត ស្នាក់នៅ ហើយនិងធ្វើការនៅ ក-១ ចំណែក នួន ជា ហើយនិង ខៀវ សំផន គាត់ទាំងពីរនាក់ហ្នឹងស្នាក់នៅ ហើយនិងធ្វើការនៅមន្ទីរក-៣។ តើលោកដឹងអំពីបញ្ហានេះដែរឬទេ?

**ឆ៖** ខ្ញុំមិនដឹងទេ។ អ្វីដែលខ្ញុំដឹងគឺថា ប៉ុល ពត មាននិវេសនដ្ឋានបី តាមដែលខ្ញុំដឹង គឺនៅក្នុងទីក្រុងភ្នំពេញ គាត់មានកន្លែងស្នាក់នៅបី ហើយកន្លែងមួយដែលគាត់ស្នាក់នៅ គឺថា ខៀវ សំផន ក៏នៅដែរ ខៀវ សំផន, វន វេត ហើយនិង នួន ជា គឺជាកន្លែងធនាគារជាតិឥឡូវនេះ គឺនៅក្បែរមាត់ទន្លេ។ ហើយនេះក្លាយទៅជាស្នាក់ការធំអចិន្ត្រៃយ៍។ ហើយមួយកន្លែងទៀត គឺនៅប្លុកអគារផ្សារទំនើបឡាក់គីបច្ចុប្បន្នហ្នឹង គឺជាប្លុកកន្លែងស្នាក់នៅមួយដែរ។

[១៤:០២:១៦]

**ស៖** ប៉ុន្តែលោកបាននិយាយថាឈ្មោះទាំងអស់ដែលល្បីដូចជា វន វេត, នួន ជា, ខៀវ សំផន ហ្នឹងទាំងអស់ហ្នឹងគឺគាត់ធ្វើការ ហើយនិងស្នាក់នៅជាមួយគ្នា។ គឺថាគាត់នៅជាមួយគ្នាជារហូតយ៉ាងម៉េចដែរ?

**ឆ៖** បាទ។

**ស៖** ឥឡូវនេះខ្ញុំចង់និយាយអំពី នួន ជា ដែលខ្លួនគាត់បានបញ្ជាក់ថា បានចូលរួមក្នុងរយៈពេលយូរជាមួយបក្សកុម្មុយនីស្តកម្ពុជា ហើយនិងភាគីនានា។ ហើយគឺថាគាត់ចាប់ផ្តើមតាំងពីឆ្នាំ១៩៦០ គាត់

ត្រូវបានគេតែងតាំងជាអនុលេខាបក្ស គឺជាតួនាទីដែលគាត់បន្តរហូតមកដល់សម័យកម្ពុជាប្រជាធិបតេយ្យ តើលោកយល់ស្របបែបនេះដែរឬទេ?

**ឆ៖** បាទ ពិតជាអ៊ីចឹងមែនហើយ។

**ស៖** ការទទួលខុសត្រូវរបស់គាត់ក្នុងនាមជាអនុលេខាបក្សហ្នឹង គឺថាក្នុងកម្រិតមួយ តើគាត់មានការទទួលខុសត្រូវប្រហាក់ប្រហែលជាមួយនឹង ប៉ុល ពត ឬក៏បន្ទាប់ពី ប៉ុល ពត បន្តិចបន្តួច។ តើខ្ញុំនិយាយអ៊ីចឹងត្រឹមត្រូវដែរឬទេ?

[១៤:០៣:៥៦]

**ឆ៖** ខ្ញុំគិតថា លោកស្រីមានប្រសាសន៍ត្រឹមត្រូវ ប៉ុន្តែវាជាការពិបាកមួយក្នុងការសិក្សាឲ្យច្បាស់អំពីទំនាក់ទំនងរវាង ប៉ុល ពត ហើយនិង នួន ជា។ ខ្ញុំចាំថាអតីតមន្ត្រីខ្មែរក្រហមមួយចំនួន គាត់និយាយថា នួន ជា ដូចជាអ្នកគ្រប់គ្រង ហើយចំណែក ប៉ុល ពត គឺជាប្រធាន។ ប៉ុន្តែយ៉ាងណាក្តីការនិយាយនេះវាដូចជាមិនច្បាស់លាស់។ វាគួរឲ្យមានលក្ខណៈស្និទ្ធស្នាល ឬក៏ច្បាស់ជាងនេះបន្តិច គឺថាពួកគាត់ទាំងពីរគឺគ្រប់គ្រង ហើយនិងមានការទទួលខុសត្រូវរួមគ្នា ឬក៏ធ្វើការជាមួយគ្នារួមគ្នា។ ដូច្នេះខ្ញុំនិយាយថាវាពិបាកនៅក្នុងការកំណត់ថាតើអ្នកណាមានឥទ្ធិពលទៅលើអ្នកណា ឬក៏អ្នកណាជាជះឥទ្ធិពលទៅលើអ្នកណាអ៊ីចឹង។

**ស៖** ឥឡូវនេះ យើងដឹងថា គាត់គឺជាអនុរបស់ ប៉ុល ពត ប៉ុន្តែនៅតែនៅមិនទាន់ច្បាស់ថា តាមរយៈការប្រកាសរបស់ នួន ជា ខ្លួនគាត់ផ្ទាល់ថាតើ នួន ជា ហ្នឹងគាត់គឺជាឧបនាយករដ្ឋមន្ត្រីដែរឬទេ? គឺថាអនុរបស់ ប៉ុល ពត ដែរឬទេ នៅក្នុងកថាខណ្ឌ៨៨? តើលោកដឹងអំពីបញ្ហានេះដែរឬទេ?

[១៤:០៥:២១]

**ឆ៖** គឺថាខ្ញុំមិនប្រាកដថា គាត់មានលក្ខណៈបែបនេះទេ យើងមិនអាចនិយាយថាគាត់ជាឧបនាយករដ្ឋមន្ត្រីនោះទេ ប៉ុន្តែគឺជាអ្វីមួយដែលពួកគាត់ទាំងពីរឯកភាពជាមួយគ្នាប៉ុណ្ណោះ ជាពិសេសនៅពេលដែលមានការវាយប្រយុទ្ធជាមួយវៀតណាម គឺទាក់ទងទៅនឹងបញ្ហារបស់ ប៉ុល ពត និង អៀង សារី ហើយយើងរីករាយជាមួយបញ្ហានេះ។ ប៉ុន្តែតាមពិតទៅគឺអត់មានទេ គឺថាការដឹកនាំរបស់គាត់ គឺរួមគ្នា ហើយ ប៉ុល ពត ទោះបីគេប្រកាសថាគាត់លះបង់ ឬក៏លាលែងតំណែងជានាយករដ្ឋមន្ត្រីក៏ដោយក៏វាអត់មានលាលែងនេះកើតឡើងពិតប្រាកដនោះទេ។

**ស៖** ពាក់ព័ន្ធទៅនឹងតួនាទីជាអនុលេខាបក្ស ហើយជាសមាជិកនៃគណៈមជ្ឈិម ហើយជាសមាជិករបស់គណៈអចិន្ត្រៃយ៍ ហើយនិងតួនាទីជាអនុលេខារបស់គណៈកម្មាធិការទាំងអស់នោះ។ តើរចនាសម្ព័ន្ធបែបនេះ វាស្របជាមួយនឹងការដឹងរបស់លោកទាក់ទងទៅនឹងបក្សកុម្មុយនីស្តរបស់ប្រទេសដទៃ ដូចជាប្រទេសចិន ឬក៏ប្រទេសសូវៀត ដែលលោកបានសិក្សាដែរឬទេ? តើវាជាការច្របល់ ឬក៏ជាការច្របល់បញ្ចូលគ្នារវាងតួនាទី ឧទាហរណ៍ដូចជាតួនាទីខាងនីតិប្បញ្ញត្តិ នីតិប្រតិបត្តិ ឬក៏នីតិតុលាការអីដែរឬទេ? តើវាមានលក្ខណៈបែបហ្នឹងដែរឬទេ? តើលោកអាចបញ្ចេញមតិយោបល់បែបណាដែរទាក់ទងទៅនឹងការដំណើររបស់បក្សកុម្មុយនីស្តជាទូទៅនោះ?

[១៤:០៧:០៤]

**ឆ៖** ខ្ញុំអាចឆ្លើយថា ទាំងបាទ ទាំងមិនមែន។ ព្រោះថាបក្សរបបបក្សកុម្មុយនីស្តកម្ពុជាហ្នឹង គឺជាមានលក្ខណៈទូទៅ។ គឺថាវាមានលក្ខណៈពិសេសមួយផ្ទាល់ខ្លួន ដែលមិនដូចបក្សដទៃ។ ប៉ុន្តែយ៉ាងក៏ដោយ គ្រប់ប្រព័ន្ធបក្សកុម្មុយនីស្តទាំងអស់ហ្នឹង គឺមានសេចក្តីសម្រេចដែលធ្វើដោយស្វ័យប្រវត្តិដោយបក្ស។ ប៉ុន្តែសំខាន់គឺថាផ្នែក ឬក៏ភាគរបស់បក្សហ្នឹង គឺជាអ្នកធ្វើការសម្រេច គឺថាធ្វើការសម្រេចទៅតាមផ្នែក ដូចជាខាងគណៈមជ្ឈិម បន្ទាប់មកគណៈអចិន្ត្រៃយ៍ ហើយបែងចែកមករដ្ឋាភិបាល។ នេះគឺជារចនាសម្ព័ន្ធ ឬក៏ប្រព័ន្ធដែលថាបក្សជាអ្នកបញ្ជូននូវសេចក្តីសម្រេច ឬក៏ការបង្គាប់បញ្ជារនានា។

ចំពោះបក្សកុម្មុយនីស្តកម្ពុជា គឺគេមិនប្រើប្រាស់ប្រព័ន្ធបែបនេះទេ។ ហើយចំពោះការច្របល់បញ្ចូលគ្នារវាងតួនាទី ប៉ុល ពត ហើយនិង នួន ជា នេះ ខ្ញុំគិតថាវាអត់មានការដូចគ្នាជាមួយនឹងបក្សកុម្មុយនីស្តប្រទេសដទៃនោះទេ។

[១៤:០៨:២៣]

**ស៖** តើលោកគិតថានេះគឺជាអ្វីដែលបណ្តាលមកពីលោកបានពិពណ៌នាពីដើមមកថា ជាលក្ខណៈរបស់បក្សកុម្មុយនីស្តកម្ពុជា ដែលថាវាស្ថិតនៅក្នុងដំណាក់កាលក្មេងខ្ចី ឬក៏វាដោយសារតែគោលគំនិត ឬក៏សេចក្តីសម្រេចច្បាស់លាស់របស់គេ ដើម្បីចង់ឲ្យមានសកម្មភាពតិចតួច ឬមួយក៏យ៉ាងម៉េចដែរ? ថាតើផ្អែកទៅតាមការស្រាវជ្រាវរបស់លោក តើលោកអាចជួយខ្ញុំពន្យល់ទៅលើបញ្ហានេះបានដែរឬទេ?

**ឆ៖** ខ្ញុំគិតថាហេតុផលទី១ គឺថាបក្សកុម្មុយនីស្តហ្នឹងស្ថិតនៅក្នុងដំណាក់កាលក្មេងខ្ចី នៅក្នុងការវិវត្តថ្មីៗនៅឡើយ។ នេះគឺជាកត្តាមួយ។ ខ្ញុំមិនគិតថាគេធ្វើឡើងដោយសារតែមានចេតនាច្បាស់លាស់

ឬក៏ដោយសារតែភាពសម្ងាត់នោះទេ។ ប៉ុន្តែខ្ញុំគិតថាបក្សកុម្មុយនីស្តកម្ពុជា ប្រសិនបើមានជីវិតនៅយូរបន្តទៅមុខទៀត ប្រហែលជាមានការវិវត្ត ហើយប្រហែលជាមានអ្វីមួយដែលកើតឡើងថ្មី។ ហើយសូមទោស ខ្ញុំភ្លេចសំណួរទី៣ របស់លោកស្រីបាត់ទៅហើយ។

**ស៖** នួន ជា តែងតែបដិសេធថាមិនមានតួនាទីផ្លូវការ ឬក៏មានទំនាក់ទំនងណាមួយទៅនឹងការងារយោធារបស់បក្ស -- របស់កម្ពុជាប្រជាធិបតេយ្យនោះទេ។ ខ្ញុំគ្រាន់តែចង់ដឹងថា តើតាមគំនិតរបស់លោកផ្ទាល់នោះ តើលោកដឹង ឬក៏លោកមានព័ត៌មានទាក់ទងទៅនឹងការចូលរួមរបស់ នួន ជា នៅក្នុងការធ្វើសេចក្តីសម្រេចនៅក្នុងផ្នែកយោធាក្រៅពីសេចក្តីសម្រេចទៅលើកិច្ចប្រជុំគណៈអចិន្ត្រៃយ៍ ឬគណៈមជ្ឈិម ដែលយើងបានពិភាក្សាពីមុនមកនោះ? តើលោកមានព័ត៌មានផ្សេងដែរឬទេ?

[១៤:១០:១៩]

**ឆ៖** អត់ទេ ខ្ញុំមិនមានទេ។ លោក នួន ជា មានការសម្រេចមួយចំនួនទាក់ទងទៅនឹងផ្នែកយោធា ប៉ុន្តែការសម្រេចហ្នឹងគឺសម្រេចនៅពេលចុងក្រោយទេ គឺនៅពេលក្រោយមក គឺពេលក្នុងទសវត្សរ៍ឆ្នាំ៩០ នៅពេលដែលគេ -- ពួកខ្មែរក្រហមហ្នឹងនៅជាពួកឧទ្ទាម គឺនៅឆ្នាំ១៩៩០ ជាងនោះទេ គឺថាវាជាការងាររបស់ខាងពួកឧទ្ទាមទេ ប៉ុន្តែចំពោះរយៈពេល៧៥ ដល់៧៩ ខ្ញុំមិនដឹងថា គាត់មានតួនាទីយោធាអីនោះទេ។

**ស៖** មានរបាយការណ៍មួយរបស់គណៈអចិន្ត្រៃយ៍ដែលបានធ្វើនៅថ្ងៃ២៦ មីនា ឆ្នាំ៧៦, E3/218 ដែលនិយាយអំពីការការពារជាតិ ហើយប្រធានបទនៃការប្រជុំនោះ គឺបានលើកឡើងរួចមកហើយជាមួយនឹងអ្នកជំនាញមួយរូបផ្សេងទៀតនោះ។ គឺថាកិច្ចប្រជុំអចិន្ត្រៃយ៍ហ្នឹងដឹកនាំដោយលោក នួន ជា ដែលជាអនុលេខបក្ស ហើយមិនមានការបញ្ជាក់ថា ប៉ុល ពត ចូលរួមក្នុងកិច្ចប្រជុំនោះទេ។ ហើយនៅពេលនុ៎ង គឺមានរបាយការណ៍ដោយ សមមិត្តយ៉ា យ៉ាងវែងទាក់ទងទៅនឹងគោលនយោបាយយោធាស្ថានភាពយោធាជាមួយនឹងវៀតណាម ហើយនៅពេលចុង -- ហើយនៅផ្នែកចុងក្រោយ គឺនិយាយអំពីសេចក្តីណែនាំពីលោក អ៎! សមមិត្តអនុលេខាបក្ស ហើយមានការរៀបរាប់យ៉ាងលម្អិតផងដែរអំពីសេចក្តីសម្រេចនោះ។ តើលោកអាចបញ្ជាក់យ៉ាងដូចម្តេចដែរ អំពីកម្រិតនៃការចូលរួម ក៏ដូចជាការពិភាក្សា ឬក៏ជាការណែនាំពាក់ព័ន្ធទៅនឹងការងារយោធាដែលធ្វើដោយ នួន ជា នោះ?

[១៤:១២:២៥]

**ឆ៖** សមមិតយ៉ា គឺ ណី សារ៉ាន់ ហើយគាត់មិនមែនជាអ្នកដឹកនាំយោធាទេ ដូច្នេះគឺវានៅមានលក្ខណៈជាការពិភាក្សានៅក្នុងបក្ស។ ដូច្នេះវាមិនមែនជាការបង្គាប់បញ្ជា ឬក៏ណែនាំផ្ទាល់ពី នួន ជា ទៅមេបញ្ជាការយោធានោះទេ។ ខ្ញុំភ្លេចអំពីកាលបរិច្ឆេទហើយ ប៉ុន្តែ ប៉ុល ពត មិននៅចូលរួមប្រជុំទីនោះ ប្រហែលជាដោយសារ ប៉ុល ពត ទៅក្រៅប្រទេសហើយមើលទៅ។ គឺថា លោក ប៉ុល ពត គាត់ធ្លាប់ទៅប្រទេសចិនច្រើនដង ដោយសារ -- ប៉ុន្តែមិនមានការផ្សព្វផ្សាយជាសាធារណៈនោះទេ។ ហេតុដូច្នេះហើយ គឺនេះជាមូលហេតុដែលថា នួន ជា អ្នកដឹកនាំការប្រជុំ។

**ស៖** ខ្ញុំបញ្ជាក់ឡើងវិញ គឺនៅថ្ងៃទី២៦ ខែមីនា ឆ្នាំ៧៦ ដែលគេមានការប្រជុំនោះ។

**ឆ៖** សូមអភ័យទោស។ ខ្ញុំសូមមើលឯកសារបន្តិចសិន។ សូមទោសខ្ញុំអត់មានព័ត៌មានទាក់ទងទៅនឹងពេលវេលា ឬក៏ជាការធ្វើទស្សនកិច្ចនោះទេ។

[១៤:១៣:៥១]

**ស៖** លោក នួន ជា នៅពេលដែលគាត់ផ្តល់ចម្លើយដល់សហចៅក្រមស៊ើបអង្កេតនៅថ្ងៃ១៩ ខែ៩ ឆ្នាំ២០០៧, E3/54។ គាត់បានរៀបរាប់អំពីតួនាទីរបស់គាត់នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យក្រោយឆ្នាំ៧៥ថា "ចំពោះខ្លួនខ្ញុំផ្ទាល់ បន្ទាប់ពីការរំដោះ ខ្ញុំនៅក្នុងផ្នែកនីតិបញ្ញត្តិ ដូច្នេះខ្ញុំមិនចូលពាក់ព័ន្ធជាមួយផ្នែកនីតិប្រតិបត្តិទេ។ ក្រៅពីបក្ស គឺមានគណៈកម្មការយោធារបស់បក្ស ដែលប្រធានគណៈកម្មការហ្នឹង គឺ ប៉ុល ពត ហើយ សុន សេន ហើយនិងតាម៉ុក គឺជាអនុប្រធាន។ ចំណែក សោម ភឹម ហើយនិង កែ ពក ជាសមាជិក។ ដូច្នេះ ខ្ញុំមិនស្ថិតនៅក្នុងគណៈយោធានោះទេ។ ខ្ញុំជាអនុលេខាបក្ស ហើយនិងជាប្រធានគណៈប្រធានរដ្ឋ -- ប្រធានគណៈប្រធានសភាតំណាងប្រជាជនកម្ពុជា។ ហើយខ្ញុំជាសមាជិកបក្សផងដែរ។ ដូច្នេះ ខ្ញុំមិនចូលរួមពាក់ព័ន្ធជាមួយនឹងការចោទប្រកាន់ណាមួយឡើយ"។ គឺការចោទប្រកាន់ដែលសហព្រះរាជអាជ្ញាបានប្រកាសចំពោះមុខគាត់នោះ។ នៅពេលនោះ យោធាគឺជាក្រុមដែលមានឥទ្ធិពលខ្លាំង ដោយសារតែយោធាគឺជាអ្នកដែលវាយផ្តួលរំលំពួកលន់ នល់។ ចំពោះអ្នកនយោបាយ គឺថាមិនមានឥទ្ធិពលខ្លាំងក្លានោះទេ។ គឺថាគេមានកិត្តិយស ឬក៏មានឥទ្ធិពលតិចតួច"។ តើលោកយល់ដែរឬទេ ថាតើការប្រកាស ឬក៏និយាយអំពីឥទ្ធិពលរបស់លោក នួន ជា នៅក្នុងរបបកម្ពុជាហ្នឹង វាៗ គឺថា ដែលថាអំណាចរបស់គាត់គឺតិចជាងអ្នកដែលចូលរួមជាមួយនឹងយោធាហ្នឹង។ តើលោកយល់យ៉ាងម៉េចដែរអំពីការប្រកាសរបស់គាត់នេះ?

[១៤:១៥:៥៦]

**ឆ៖** មិនទេ ខ្ញុំគិតថា វាមិនត្រឹមត្រូវនោះទេ។ វាគ្រាន់តែជាការ -- ជាល្បាយនៃអ្វីដែលថាមិនពិតប្រាកដ ដែលថាគាត់មិនមែនជាសមាជិក ឬក៏ផ្នែកនៃគណៈយោធានោះ។ ដូច្នេះ ខ្ញុំមិនយល់ស្របជាមួយបញ្ហានេះទេ។ ការដែលគាត់ធ្វើពុត ថាយោធាមានអំណាចខ្លាំងជាងអ្នកនយោបាយ ឬក៏ខ្លាំងជាងអ្នកដឹកនាំបក្សនោះ វាមិនមែនជាការពិតនោះទេ។ វាជាការនិយាយប្រឌិត។ បក្សត្រូវការគាំទ្រពីយោធា ប៉ុន្តែដូចដែលលោកស្រីបានអានពីមុនកន្លងមកហើយអ៊ីចឹង គឺថាយោធាគឺស្ថិតនៅក្រោមបក្សនោះទេ។ ហើយបក្សជាអ្នកសម្រេចទៅលើសេចក្ដីសម្រេចនានា ដើម្បីឲ្យយោធាជាអ្នកអនុវត្ត។ គឺថាវាមានលក្ខណៈមួយដែលថាមេដឹកនាំយោធា ដូចជា តាម៉ុក ហើយនិង កែ ពក គឺថាគាត់ចេញមកពីក្រុមខ្មែរឥស្សរៈ។ ចំណែកមេដឹកនាំបក្ស គឺចេញមកពីអតីតនិស្សិតនៅប្រទេសបារាំង ហើយនិង នួន ជា ដែលជានិស្សិតមកពីប្រទេសថៃ។ ដូច្នេះ អានេះគឺជាអ្វីដែល ប៉ុល ពត គាត់ព្យាយាមបញ្ចូលពួកក្រុមទាំងពីរនេះ ប៉ុន្តែយ៉ាងណាក៏ដោយ សេចក្ដីសម្រេចចុងក្រោយ គឺរបស់បក្ស។

[១៤:១៧:២៥]

**ស៖** នេះគឺជាចំណុចដ៏សំខាន់មួយ ប៉ុន្តែប៉ុន្មានឆ្នាំ -- អ៎! ប៉ុន្មានខែមុន គឺថា នួន ជា គាត់និយាយនៅចំពោះមុខសាលាដំបូងថា គឺគាត់និយាយថា គេហៅគាត់ថាជាបងធំទី២នៅក្នុងរបបនោះ។ តើនេះជាតួនាទី ឬក៏ជាឋានៈដែលគេបង្កើតឡើង ចាប់តាំងពីពេលដែលរបបហ្នឹងបានរំដោះទីក្រុងភ្នំពេញ ឬមួយក៏នៅពេលបន្ទាប់មកទៀត?

**ឆ៖** ទាំង ប៉ុល ពត និង នួន ជា ត្រូវបានគេហៅថា អ៊ំ។ គឺបានន័យថា គេហៅគាត់ទាំងពីរនាក់ គឺ អ៊ំ។ ប៉ុល ពត ត្រូវបានគេហៅថា បងទី១ ឬក៏អ៊ំទី១។ នួន ជា គឺ ជាបងទី២, ហើយ អៀង សារី គឺជាបងទី៣។ ប៉ុន្តែការប្រើប្រាស់ពាក្យថា បងទី១, ទី២ គឺថាអ្វីដែលគេប្រើមកហ្នឹង ដូចជាមិនត្រូវនោះទេ។ វាហាក់ដូចជាការពន្លើស ឬក៏ជាការបន្ថែមប៉ុណ្ណោះ វាមិនមានកើតឡើងនៅពេលនោះទេ។ ឧទាហរណ៍ជាយ៉ាងណាក៏ដោយ នៅប្រទេសចិន វៀតណាម គឺគេមានការប្រើប្រាស់ពាក្យថា បងទី១, ទី២, ទី៣, ទី៤ អ៊ីចឹង។ ប៉ុន្តែដូច្នេះហើយវា អ្វីដែលនេះ វាគ្រាន់តែជាការពណ៌នា ឬក៏ការនិយាយតែប៉ុណ្ណោះ វាមិនមានន័យអ្វីធ្ងន់ធ្ងរនោះទេ។

[១៤:១៩:០០]

**ស៖** ខ្ញុំចង់បញ្ចប់សំណួររបស់ខ្ញុំជាមួយលោក ដែលពាក់ព័ន្ធទៅនឹងប្រធានបទ ដែលលោកបាននិយាយច្រើនដងនៅក្នុងសៀវភៅរបស់លោកនោះ។ ប៉ុន្តែមិននិយាយជាពិសេសចំពោះ នួន ជា និង ខៀវ សំផន ទេ។ ឥឡូវនេះ ខ្ញុំចង់និយាយអំពីបញ្ហាការសម្ងាត់ ដែលលោកនិយាយអំពីការសម្ងាត់នៅក្នុងរបបខ្មែរក្រហមនោះ។ មុនឆ្នាំ៧៥ ខែមេសា ឆ្នាំ៧៥ លោកបាននិយាយនៅទំព័រ១៦២ គឺនិយាយអំពីការផ្លាស់ប្តូរឈ្មោះបក្សពលករ ទៅជាបក្សកុម្មុយនីស្តកម្ពុជា នៅក្នុងឆ្នាំ៦៦។ ហើយលោកបាននិយាយថា គឺគេរក្សាការសម្ងាត់អំពីកម្មាភិបាល ក៏ដូចជារក្សាការសម្ងាត់ពីវៀតណាម។ ហើយលោកបានបញ្ចេញមតិមួយចំនួននៅព្រឹកហ្នឹង ហើយនៅរសៀលនេះផងដែរ ទាក់ទងទៅនឹងបញ្ហារក្សាការសម្ងាត់ពីវៀតណាម មិនឲ្យវៀតណាមដឹង។ តើឋានៈ ហើយនិងតួនាទីរបស់បក្សហ្នឹងវាមានលក្ខណៈយ៉ាងដូចម្តេចដែរ? តើលោកមានប្រភពព័ត៌មានយ៉ាងដូម្តេចដែរ? ហើយហេតុអ្វីបានជាមានការផ្លាស់ប្តូរឈ្មោះ ហើយគេរក្សាការសម្ងាត់មិនឲ្យដឹងអំពីការផ្លាស់ប្តូរឈ្មោះបក្សនេះ?

[១៤:២០:២០]

**ឆ៖** ការផ្លាស់ប្តូរឈ្មោះត្រូវបានរក្សាការសម្ងាត់មិនឲ្យវៀតណាមដឹង។ ហើយឋានៈ និងតួនាទីរបស់បក្សមិនត្រូវបានគេប្រាប់ឲ្យដឹងនោះទេ។ ហេតុដូច្នេះហើយ គឺថាដើម្បីកុំឲ្យធ្លាយចេញទៅដល់ហាណូយ។ ព្រោះថាវៀតណាម គេមានបក្សពលករវៀតណាម ហើយកម្ពុជាគឺមានបក្សពលករកុម្មុយនីស្តកម្ពុជា ហើយវាមានឋានានុក្រមនានាដែលបញ្ជាក់អំពីកម្រិតខ្ពស់ ឬក៏កម្រិតទាបនៃការវិវិត្តន៍។ ហេតុដូច្នេះហើយ គឺគេមិនចង់ឲ្យដឹងទៅដល់វៀតណាម ដោយសារតែពួកគេពឹងផ្អែក មិនចង់រំខានដល់វៀតណាម ដោយសារគេពឹងផ្អែកទៅលើវៀតណាម ទៅលើបញ្ហាមួយចំនួន។

ការពិតទៅ គឺវាជាការកំណត់លក្ខណៈ ឬក៏ជាបញ្ហានៃការកំណត់លក្ខណៈទៅលើមេដឹកនាំបក្សកុម្មុយនីស្តកម្ពុជា។ នួន ជា នៅក្នុងការសម្ភាសឆ្នាំ១៩៩៨ ដែលលោកស្រីបានអាននូវការដកស្រង់មុននេះ គឺគាត់បានលើកនូវចំណុចមួយយ៉ាងសំខាន់អំពីបក្សកុម្មុយនីស្តរបស់ដាណឺម៉ាក គឺថាជាបញ្ហាសំខាន់មួយនៃបញ្ហាបក្សកុម្មុយនីស្តនានា។ ហើយអ្វីដែលគាត់និយាយហ្នឹង គឺវាបានពន្យល់ទៅលើបញ្ហាមួយចំនួន។ ខ្ញុំចាំថាខ្ញុំធ្លាប់និយាយជាមួយលោក ខៀវ សំផន ហើយលោក ខៀវ សំផន បាននិយាយថា លោកមិនអាចប្រាប់ប្រជាជនកម្ពុជាបានទេ ព្រោះប្រសិនបើប្រាប់ប្រជាជនកម្ពុជា ប្រជាជនកម្ពុជាហ្នឹងគាត់នឹងនិយាយក្រោយហ្នឹងមួយនាទី ប្រាប់ភ្លាម និយាយចេញភ្លាម។ ដូច្នេះហើយនេះជាអាកប្បកិរិយា

មួយរបស់ប្រជាជនកម្ពុជា។ លុះត្រាតែយើងអាចរក្សាការសម្ងាត់បាន។ ប្រសិនបើមិនអ៊ីចឹងទេ គេនាំគ្នាយកទៅនិយាយបែកអូរហូរស្ទឹងអស់ហើយ។

[១៤:២២:១១]

នៅក្នុងឆ្នាំ៦០ ទសវត្សរ៍ឆ្នាំ៦០ គឺកងកម្លាំងនគរបាលរបស់សម្តេច សីហនុ គឺខ្លាំង ហើយមានឥទ្ធិពល។ ហើយគឺពួកគេសម្រេចថានឹងលុបបំបាត់នូវឥទ្ធិពលរបស់កុម្មុយនីស្តកម្ពុជា។ ហើយប្រសិនបើយើងពិនិត្យឲ្យបានលម្អិតបន្ថែមទៀតនៅក្នុងសម័យអាណានិគមបារាំង គឺពួកឥស្សរៈនោះ គឺពួកឥស្សរៈគាត់មានលក្ខណៈថារក្សាការសម្ងាត់ដូចគ្នា។ អានេះគឺជាលក្ខណៈមួយដែលកំណត់ទាក់ទងទៅនឹងការរក្សាការសម្ងាត់។ នេះគឺវាពាក់ព័ន្ធទៅនឹងវប្បធម៌របស់កម្ពុជា។ វាជាលក្ខខណ្ឌមួយដែលមានលក្ខណៈសត្យានុម័តផងដែរ។

**ស៖** នៅក្នុងរយៈពេលមុនឆ្នាំ៧៥ លោកបានពណ៌នាថា នួន ជា ធ្វើការនៅក្នុងទីក្រុងភ្នំពេញជាកម្លាំងសំខាន់ នៅក្នុងទំព័រ១៨៣។ ហើយលោកបានរៀបរាប់ នួន ជា នៅក្នុងឆ្នាំ១៩៦៨ ថានួន ជា គឺជាមេរបស់កម្លាំងសម្ងាត់ដើម្បីបំបាំងរាងកាយគាត់ ដើម្បីបិតបាំងរាងកាយគាត់ ហើយនិងក៏ជាអ្នកធ្វើដំណើរដោយមិនមានការផ្តល់ព័ត៌មាន ហើយក៏ជាការជួយឧបត្ថម្ភនូវគ្រឿងសព្វាវុធនានាផងដែរ។ ហើយលោកក៏បាននិយាយថាលោក នួន ជា អាចលាក់ខ្លួននៅក្នុងទីក្រុងភ្នំពេញបានរយៈពេលយូរមុនពេលដែលគាត់រត់គេចទៅក្នុងព្រៃ។ ហើយគាត់លាក់បាំងខ្លួនដោយមិនមានតាមដានចាប់បាននៅក្នុងទីក្រុងភ្នំពេញនោះ។ នេះហើយគឺជាបញ្ហាមួយទាក់ទងទៅនឹងការសម្ងាត់របស់បក្សកុម្មុយនីស្ត។ តើវាមានបញ្ហាអីផ្សេងទៀតដែរឬទេទាក់ទងទៅនឹងការសម្ងាត់នេះ?

[១៤:២៤:២០]

**ឆ៖** ខ្ញុំគិតថា នួន ជា គាត់ពូកែខាងបញ្ហានេះ។ គឺថាគាត់លាក់ខ្លួនបានដែលមិនឲ្យមានអ្នកណាដឹង ហើយនៅពេលដែលគាត់ថាគាត់អាចនឹងប្រឈមគ្រោះថ្នាក់ខ្លាំង ទើបគាត់សម្រេចចិត្តទៅនៅក្នុងព្រៃ។ នេះគឺជាការបិតបាំង ឬក៏ការលាក់បំបាំងខ្លួនមួយ។ ប៉ុន្តែ នួន ជា គាត់អាច ប្រហែលជាគាត់រស់នៅដោយមានការភ័យខ្លាចផងដែរ។ នេះគឺជាបញ្ហាមួយផងដែរ។

**ស៖** នៅក្នុងរយៈពេលដដែលនេះ គឺមានការនិយាយយោងទៅលើការសម្ងាត់ផងដែរ គឺមន្ទីរសម្ងាត់របស់បក្សកុម្មុយនីស្តកម្ពុជា ហើយលោកបាននិយាយអំពីមន្ទីរសម្ងាត់មួយទៀតដែលគេហៅថា

ល-៧១ ដែលនិយាយអំពីទស្សនាវដ្ដីទង់បដិវត្តផងដែរ ដែលមានពីរគឺទី១ មានទង់បដិវត្តទង់ប្រាំ ដែលគេផ្សព្វផ្សាយសម្រាប់កម្មវិធីរបស់កម្មាភិបាលជាន់ខ្ពស់ និងមួយទៀតគឺមានទង់តែមួយទេសម្រាប់កម្មា-ភិបាលថ្នាក់កណ្ដាល និងថ្នាក់ទាប។ ហើយទាំងអស់នេះគឺជាការបង្ហាញពីការវិវត្តនៃអង្គបញ្ញត្តិមួយទាក់ទងនៅក្នុងជួរបក្ស ក៏ដូចជាការប្រាស្រ័យទាក់ទងរបស់អ្នកដឹកនាំខ្ពស់នៃបក្សមុនឆ្នាំ៧៥ តើខ្ញុំនិយាយអ៊ីចឹងត្រឹមត្រូវដែរឬទេ?

**ឆ៖** គឺថានៅឆ្នាំ៧១-- អ៎! ល-៧១ហ្នឹងគឺនៅកំពង់ធំ ហើយអ្វីដែលជាចំណេះដឹងរបស់គាត់ហ្នឹងគឺជាអំណាច។ ហើយការបែងចែកចំណេះដឹងហ្នឹង គឺត្រូវបានបែងចែកទៅដល់អ្នកណាដែលគេទុកចិត្ត គឺគេបែងចែកទៅតាមកម្រិត ឋានៈនីមួយៗនោះ។

[១៤:២៦:២០]

**ស៖** បន្ទាប់ពីការរំដោះទីក្រុងភ្នំពេញ ដូចដែលលោកបានបញ្ជាក់ ការរក្សាការសម្ងាត់នៅតែបន្ត ហើយលោកបាននិយាយនៅក្នុងឯកសារ E3/196 និយាយអំពីបក្សកុម្មុយនីស្តកម្ពុជា ហើយនិយាយអំពីការជួបរបស់បក្សកុម្មុយនីស្តកម្ពុជាជាមួយខាងបក្សកុម្មុយនីស្តដាណឺម៉ាក គឺនៅខែកក្កដា ឆ្នាំ៧៨ ហើយក៏និយាយអំពីបញ្ហាការរក្សាការសម្ងាត់ផងដែរ ដែលលោក នួន ជា បាននិយាយអំពីការរក្សាការសម្ងាត់បន្ទាប់ពីរំដោះទីក្រុងភ្នំពេញ។ ចាប់តាំងពីការរំដោះទីក្រុងភ្នំពេញមក គឺយើងនៅរក្សាការសម្ងាត់ ព្រោះថាវាជាមាគ៌ាយុត្តិសាស្ត្រ ដែលជាវិធីសាស្ត្រមួយដ៏រឹងមាំ ហើយយើងបង្កើត ហើយយើងបង្ហាញឈ្មោះកម្មាភិបាលតែមួយចំនួនតែប៉ុណ្ណោះ នៅក្នុងពេលសង្គ្រាមអ្វីៗទាំងអស់ត្រូវបានរក្សាការសម្ងាត់។ ហើយបានបន្តរៀបរាប់ថា គេធ្វើទាំងអស់នេះគឺដោយទទួលយកបទពិសោធន៍ពីបក្សកុម្មុយនីស្តកម្ពុជា ហើយក៏ផ្ដល់ឧទាហរណ៍ផងដែរ អំពីការប្រតិបត្តិដូចជាការប្រើប្រាស់សញ្ញា ការប្រើប្រាស់ទង់ ឬក៏ប្រើប្រាស់ពាក្យសម្ងាត់ផ្សេងៗនោះ។ ដូច្នេះ ខ្ញុំចង់ដឹងថា ហេតុអ្វីបានជាក្រោយរំដោះហើយវានៅតែសម្ងាត់ទៀត ដែលត្រូវរក្សាការសម្ងាត់មិនបង្ហាញឈ្មោះសមាជិកបក្ស ឬក៏អ្នកដឹកនាំជាន់ខ្ពស់ហ្នឹង ទៅរក្សាឈ្មោះមិនឲ្យដឹងតទៅទៀត។ តើវាមានមូលហេតុអ្វីដែរ?

[១៤:២៧:៥១]

**ឆ៖** ដោយសារលោកស្រីនិយាយអំពីប្រធានបទមួយដែលមិនកម្រិត កំណត់តែត្រឹមបញ្ហាមួយនេះ។ ដូច្នេះហើយខ្ញុំគិតថាការប្រើប្រាស់ពាក្យខ្លីមួយ គឺថាដោយសារតែការភ័យខ្លាចៗប៉ុណ្ណោះ។ អានេះ

គឺជាការភ័យខ្លាចដោយសារតែកម្ពុជានៅចន្លោះប្រទេសធំគឺប្រទេសវៀតណាម និងប្រទេសថៃ។ ហើយការភ័យខ្លាចមួយទៀត គឺដោយសារតែបញ្ហាខ្លាំងបង្កប់ស៊ីរូងផ្ទៃក្នុង។ អានេះ គឺជាអ្វីដែលខ្ញុំអាចពណ៌នាថាជាការភ័យខ្លាច។ ដោយសារតែមានការភ័យខ្លាចជាច្រើននៅក្នុងបក្សកុម្មុយនីស្តកម្ពុជា នៅក្នុងរបបបក្សកុម្មុយនីស្តកម្ពុជានេះ។ ខ្ញុំគិតថានេះជាបញ្ហាមួយ។ ប្រសិនបើយើងធ្វើការរៀបរាប់ដែល នួន ជា បានព័ត៌មានទៅប្រតិភូខាងបរទេសដូច្នោះដែរ។

**ចៅក្រម ស៊ីលវៀ ខាតវ៉ាយច័៖**

លោក ស្សូត! លោកប្រធាន! ដោយសារតែខ្ញុំមានការសួរច្រើនរួចមកហើយ ដូច្នេះខ្ញុំបញ្ចប់ការសួររបស់ខ្ញុំ ហើយសូមអរគុណលោកប្រហែលជាមានសំណួរខ្លះបន្ថែមទៀតចំពោះលោក ដោយសារអ្វីដែលខ្ញុំសួរវាហាក់ដូចជាចង្អៀតបន្តិចដែរ។

[១៤:២៨:០៩]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកចៅក្រម ហ្សង់ម៉ាក ឡាវែន៍!

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

បាទ សូមអរគុណលោកប្រធាន។

**សួរដោយចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

**ស៖** ជម្រាបសួរលោកអ្នកជំនាញ ស្សូត! បាទ ខ្ញុំមានសំណួរមួយចំនួនដើម្បីចោទសួរទៅកាន់លោក ដើម្បីបន្ថែមទៅលើសំណួរដែលសហភាគីរបស់ខ្ញុំបានចោទសួរទៅលោក។ បាទ ជាបឋម ខ្ញុំមានសំណួរមួយចំនួនទាក់ទងទៅនឹងប្រភពព័ត៌មានដែលលោកបានប្រើ ដើម្បីសរសេរសៀវភៅរបស់លោក គឺថា "ប៉ុល ពត: ប្រវត្តិសុបិនអាក្រក់នៃប្រទេសកម្ពុជា"។ លោកបាននិយាយអំពីឯកសារមួយនៅក្នុងសៀវភៅរបស់លោក គឺថាដែលជាឯកសារសរសេរដោយលោក អ៊ិន សុភាព ប្រហែលជាខ្ញុំអានមិនសូវច្បាស់ទេ ខ្ញុំសង្ឃឹមថាលោកយល់អំពីអ្វីដែលខ្ញុំចង់និយាយ។ ឯកសារហ្នឹងមានចំណងជើងថា "ខៀវ សំផន: ជឿ -- ធំឡើង ហើយនិងមានភាពជឿជាក់ក្នុងខ្លួន"។ ហើយនេះគឺជាកំណត់សម្គាល់រ៉ៃអង្គុលីលេខដែលប្រហែលជាមិនទាន់បានបោះពុម្ពនោះទេ។ ហើយនិងមានបង្កឲ្យមានបញ្ហាមួយចំនួន។

ឯកសារនេះប្រហែលជាអាចស្ថិតនៅក្នុងឯកសាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា។ ខ្ញុំទទួលបានឯកសារចម្លងមួយនៃឯកសារនេះ ហើយអ៊ីចឹងខ្ញុំចង់ដឹងថាតើលោកអាចបញ្ជាក់ពីយថាភាពនៃឯកសារនេះដែរឬទេ គឺឯកសារដែលលោកបានប្រើប្រាស់ដើម្បីសរសេរសៀវភៅរបស់លោក។ ហើយលោកបានយោងលើឯកសារនេះនៅក្នុងប្រភពឯកសាររបស់លោកនោះ។ លោកអាចបញ្ជាក់ពីយថាភាពនៃឯកសារនេះបានដែរឬទេ?

[១៤:៣១:១៧]

**លោក ហ្វីលីព ស្ហតៈ**

**ឆៈ** បាទ សូមអភ័យទោស បើសិនខ្ញុំបានឃើញ ខ្ញុំអាចនឹងកំណត់អត្តសញ្ញាណនោះបាន។

**សៈ** បាទ ខ្ញុំសូមឲ្យក្រឡាបញ្ជីផ្តល់ឯកសារនេះជូនទៅលោក ដើម្បីឲ្យលោកពិនិត្យបាន។ បើសិនជាសាក្សីពិនិត្យឯកសារនេះហើយ យើងមិនចែកចាយឯកសារនេះទៅភាគីបើសិនជាគាត់ពិនិត្យហើយនោះ។ ខ្ញុំសូមនិយាយអំពីចំណុចទី១ សិន ដែលចំណុចនេះទាក់ទងទៅនឹងទំនាក់ទំនងដែលអាចកើតមានឡើងរវាងចលនាប្រជាជន ហើយនិងការបង្កើតនយោបាយសមូហភាពដោយបង្ខំតាមរយៈការបង្កើតសហករណ៍ កម្រិតដែលថាកាន់តែខ្ពស់ឡើងៗ។ តើលោកអាចជម្រាបជូនតុលាការថាមុនពេលជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ ថ្នាក់ដឹកនាំខ្មែរក្រហមបានអនុវត្តគោលនយោបាយជម្លៀសប្រជាជនរួចមកហើយ។ ហើយបានអនុវត្តន៍គោលការណ៍នេះនៅក្នុងលក្ខខណ្ឌណាដែរ?

[១៤:៣២:៤៩]

**ឆៈ** ពិតជាបានចាប់ផ្តើមពីដំបូង គឺថាចាប់ផ្តើមដោយ--*(គ្មានការបកប្រែ)*

**សៈ** បាទ សូមលោក បើថានិយាយភាសាអ្វី លោករក្សាភាសាហ្នឹង បើមិនយ៉ាងដូច្នេះទេ គឺថាមានការលំបាកក្នុងបកប្រែ។ នៅអម្បាញ់មិញនេះ អ្នកបកប្រែជាភាសាបារាំងនោះ មិនបានឮឃ្លាដើមរបស់លោកក្នុងចម្លើយរបស់លោកទេ។ អ៊ីចឹងសូមលោកឆ្លើយម្តងទៀតបាទ។ សូមអរគុណ។

**ឆៈ** សូមអភ័យទោស ខ្ញុំយល់ពីការណ៍នេះ។ ខ្ញុំនិយាយថា ពិតជាមានការផ្លាស់ប្តូរទីលំនៅប្រជាជនពីដំបូងនោះមែន។ ដំបូងគេនោះ គឺចាប់ផ្តើមដែលយើងដឹងហ្នឹងក្នុងឆ្នាំ១៩៧៣ បន្ទាប់មកគឺមានការផ្លាស់ប្តូរទីលំនៅប្រជាជននៅខេត្តក្រចេះ ចេញពីឧដុង្គឆ្នាំ១៩៧៤ ហើយមានការផ្លាស់ប្តូរទីលំនៅប្រជាជននៅតាមព្រំដែនវៀតណាម ហើយប្រមូលផ្តុំជាក្រុមឲ្យដាក់ចូលជាសហករណ៍ ហើយពិតជា

បានចាប់ផ្តើមនៅក្នុងមុនឆ្នាំ១៩៧៥ គឺចាប់ផ្តើមមុន ប៉ុន្តែជាក្របខ័ណ្ឌតូចៗ ជាទ្រង់ទ្រាយតូចៗ គឺដោយសារមូលហេតុនៃការអនុវត្តនៅតាមជនបទ។ រីឯនៅឆ្នាំ១៩៧៥ វាជាការជម្លៀស ការផ្លាស់ប្តូរទីតាំងតាមមនោគមន៍វិជ្ជារបស់គេ។

[១៤:៣៤:៣៩]

**ស៖** បាទ បើខ្ញុំឥឡូវនេះខ្ញុំសូមអានសម្រង់មួយនៃសៀវភៅរបស់លោក ដើម្បីចង់ដឹងថាតើលោកនៅតែរក្សាខ្លឹមសារនេះដដែលឬក៏អត់? គឺថានៅ ERN ជាភាសាបារាំងគឺ 00639773 ទៅដល់74 ហើយជាភាសាអង់គ្លេសគឺ 00396446 ទៅដល់47។ បាទ លោកបានលើកឡើងដូចតទៅនេះ "ដោយយកលេសថា ជៀសវាងការទម្លាក់គ្រាប់បែកអាមេរិកាំង ភូមិជាច្រើនត្រូវបានជម្លៀសចេញ ហើយនិងបញ្ជូនទៅកន្លែងផ្សេង។ ចលនាប្រជាជននៅកម្រិតទាបជាងនេះ ធ្លាប់បានធ្វើមកហើយនៅក្នុងឆ្នាំ១៩៧២ ហើយកាលនៅរតនគិរីនោះ ចាប់តាំងពីឆ្នាំ១៩៦៨ មកម្ល៉េះ ក៏ប៉ុន្តែចំណុចនេះគឺថាចង់ធ្វើឲ្យមនុស្សគេចឲ្យរួចផុតពីការត្រួតត្រារបស់រដ្ឋាភិបាលដោយបញ្ជូនពួកគេទៅឆ្ងាយ ទៅក្នុងតំបន់រំដោះ"។

[១៤:៣៦:០៨]

យើងមើលក្នុងបរិបទនេះវិញ គឺថាលោកនិយាយថាឆ្នាំ៧៣ ក៏ប៉ុន្តែពេលនេះ គឺថាពួកគេត្រូវបានបញ្ជូនកាន់តែឆ្ងាយទៅទៀត ទៅតំបន់ភ្នំ និងតំបន់ព្រៃជាដើម។ បើសិនជាផ្ទះសម្បែងនោះ បើមិនបានបំផ្លាញទេ ក៏ដុតចោល ដើម្បីកុំឲ្យគេត្រឡប់មកវិញ ហើយនៅពេលដែលធ្វើការជា ថាម្នាក់ឯង ឬក៏ក្រុមតូចៗនោះ គឺថាពួកគេត្រូវបង្ខំឲ្យបង្កើតជាសហករណ៍ ដែលមានមនុស្សចំនួនពី៣០ ទៅ៤០នាក់ ដែលដាំដុះរួមគ្នា។ ហើយត្រង់ចំណុចនេះ វិធានការនេះ មិនមែនថាទើបតែធ្វើលើកហ្នឹងនោះទេ។ នៅក្នុងផ្នែកនិរតី ហើយនិងតំបន់ ភូមិភាគពិសេស ពួកគេបានខំព្យាយាមបញ្ចូលសហករណ៍ បង្កើតសហករណ៍បន្ទាប់ពីមានការប្រជុំនៅគណៈមជ្ឈិម ខែឧសភា ឆ្នាំ១៩៧២ ក៏ប៉ុន្តែដោយសារឃើញថា បាត់បង់ប្រជាប្រជាប្រិយភាព អាជ្ញាធរក៏មិនបានបង្ខំឲ្យធ្វើទៀតដែរ។ ក៏ប៉ុន្តែក្រោយ -- ប៉ុន្តែលើកនេះការធ្វើសមូហភាពនោះបានដាក់កំហិតឲ្យធ្វើនៅក្នុងតំបន់រំដោះទាំងស្រុងតែម្តង។ តើ -- សំណួរខ្ញុំថា តើលោកនៅតែរក្សាខ្លឹមសារនេះដដែលទេនៅក្នុងសៀវភៅរបស់លោកនោះ? ហើយលោកអាចពន្យល់ពីមូលហេតុបានដែរឬទេ ហេតុអ្វីក៏លោកបានសរសេរយ៉ាងដូច្នេះ?

[១៤:៣៧:៤៤]

**ឆ៖** បាទ ខ្ញុំយល់ស្របនឹងរក្សាអ្វីដែលខ្ញុំសរសេរ ប៉ុន្តែខ្ញុំឃើញថាមានភាពខុសគ្នាមួយរវាងសមូហភាពរូបនីយកម្ម ហើយនិងចលនាប្រជាជន។ សមូហភាពនិយមនេះគឺថាអាចកើតឡើង គឺថាដោយមិនចាំបាច់ប្តូរប្រជាជនពីភូមិមួយទៅភូមិមួយទេ។ នៅពេលដែលគេដុតភូមិចោល ហើយប្រជាជនផ្លាស់ទីតាំងទៅកន្លែងមួយផ្សេងទៀត គឺតាមធម្មតា គឺអាស្រ័យទៅលើមូលហេតុអនុវត្តរបស់បក្សកុម្មុយនីស្តកម្ពុជានៅពេលនោះគឺ ដូចដែលខ្ញុំបាននិយាយ គឺថាដើម្បីការត្រួតត្រានោះឯង។

ក្រោយមកការជម្លៀសនៅបាត់ដំបង នៅភ្នំពេញក្នុងខែមេសា ឆ្នាំ១៩៧៥ គឺជាការអនុវត្តមួយផ្សេងទៀត គឺថាមិនមែនជាការចងក្រងអ្នកភូមិទៅក្នុងសហករណ៍សមូហភាពទេ ប៉ុន្តែពេលនេះ គឺជាការបណ្តេញចេញប្រជាជនឲ្យអស់ពីទីក្រុង ទីប្រជុំជនទៅវិញ។

**ស៖** បាទ នៅពេលដែលប្រជាជនត្រូវបានគេជម្លៀសនោះ ទោះបីជាមុនឆ្នាំ៧៥ ឬក៏ក្រោយឆ្នាំ៧៥ក៏ដោយ តើមិនមែនដោយសារដើម្បីសម្រួលដល់ការបង្កើតសហករណ៍ទេ។ លោកទើបតែបាននិយាយថាវាមិនចាំបាច់ជម្លៀសប្រជាជនដើម្បីបង្កើតសហករណ៍នោះទេ។ ក៏ប៉ុន្តែនៅពេលដែលគេជម្លៀសមនុស្សហើយនោះ តើមានជម្រើសអ្វីផ្សេងទៀតក្រៅពីដាក់មនុស្សទាំងអស់ ឬក៏ប្រជាជនទាំងអស់នោះនៅក្នុងសហករណ៍ដែរឬទេ?

[១៤:៣៩:០១]

**ឆ៖** ប៉ុន្តែមិនតែងតែជាការចាំបាច់ដើម្បីប្តូរទីតាំងប្រជាជន ដើម្បីបង្កើតសហករណ៍នោះទេ។ អ្វីដែលខ្ញុំយល់ គឺថាភាគច្រើននៃសហករណ៍នោះ គឺធ្វើការមានទីតាំងនៅក្នុងភូមិដែលមានរួចហើយពីមុនមកនៅក្នុងតំបន់។ ជាពិសេសនៅតាមបណ្តោយព្រំដែនវៀតណាម-ខ្មែរ គឺថាភូមិត្រូវបានកម្ទេច គឺថាប្រជាជនត្រូវបានចេញទៅតំបន់ដាច់ស្រយាល។ ប៉ុន្តែមានតំបន់ផ្សេងទៀតគឺថាភាគច្រើនជាកន្លែងដែលសហករណ៍ហ្នឹងត្រូវបានបង្កើតឡើងនៅក្នុងភូមិចាស់ៗរបស់គេនោះឯង។ លោកបាននិយាយអំពីរតនគិរីអំពីការធ្វើចលនាប្រជាជននៅទីនោះ គឺថាគេធ្វើបែបនោះដើម្បីមូលហេតុនៃការអនុវត្តដើម្បីទាញយកអ្នកគាំទ្រអ្វីដែលគេយល់។ គឺថាដែលថាដើម្បីធ្វើការយុទ្ធនាការប្រឆាំងរដ្ឋាភិបាល គេបញ្ជូនទៅតំបន់សុវត្ថិភាពដែលគេស្រួលនឹងការពារពួកគេ។ នេះហើយជាមូលហេតុក្នុងការអនុវត្ត។ នេះគឺជាមូលហេតុពីរ គឺនិយាយពីសហសមូហភាពភាវូបនីយកម្ម ហើយនិងការចលនាទីតាំងនេះ។

**ចៅក្រម ហ្សង់ម៉ាក ឡាវែរ៍ន៖**

យើងនឹងត្រឡប់មកនិយាយពីបញ្ហានេះបន្តិចទៀត។

លោកប្រធានប្រហែលជាដល់ពេលត្រូវសម្រាកហើយលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ បាទឥឡូវនេះដល់ពេលសម្រាកហើយ អង្គជំនុំជម្រះប្រកាសសម្រាកចាប់ពីពេលនេះទៅរហូតដល់ម៉ោងបី សូមអញ្ជើញចូលវិញដើម្បីបន្តកិច្ចដំណើរការសវនាការ។

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលផ្តល់កន្លែងសម្រាកនៅបន្ទប់រងចាំសម្រាប់សាក្សី និងអ្នកជំនាញ ដល់អ្នកជំនាញរូបនេះនៅក្នុងអំឡុងពេលឈប់សម្រាក និងឲ្យអញ្ជើញគាត់ត្រឡប់មកកាន់កន្លែងផ្តល់សក្ខីកម្មនៅក្នុងបន្ទប់សវនាការនេះវិញនៅវេលាម៉ោងបី។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១៤:៤១ នាទី ដល់ម៉ោង ១៥:០១ នាទី)*

[១៥:០១:៣៦]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ អង្គជំនុំជម្រះសូមជម្រាបសួរទៅលោកអ្នកជំនាញថា អម្បាញ់មិញនេះមានបញ្ហាក្នុងការបកប្រែភាសា ដោយសារលោកមានភាពជំនាញទាំងពីរភាសា ភាសាបារាំង និងភាសាអង់គ្លេស។ ឥឡូវនេះលោកចៅក្រមដែលតាំងសំណួរចំពោះលោកនោះ គាត់ប្រើប្រាស់ភាសាបារាំង។ ហើយតាមព័ត៌មានថាលោកអាចឆ្លើយតបទៅនឹងសំណួរដែលសួរជាភាសាបារាំងវិញ ប្រសិនបើដូច្នេះអង្គជំនុំជម្រះនឹងជម្រាបទៅខាងអ្នកបកប្រែភាសា ដើម្បីផ្លាស់ប្តូរនូវឆានណែល ដើម្បីឲ្យងាយសម្រួលដល់កិច្ចពិភាក្សាដេញដោលនេះបានល្អប្រសើរ។

**លោក ហ្វីលីព ស្បូត៖**

បាទ សូមអរគុណលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

ដូច្នេះអ្នកបកប្រែភាសាគឺផ្លាស់ប្ដូរនូវ ឆានណែល ដើម្បីឱ្យស្របទៅនឹងអ្នកជំនាញដែលគាត់នឹងប្រើប្រាស់ភាសាបារាំងនៅក្នុងអំឡុងពេលដេញដោលដោយចៅក្រមដែលប្រើប្រាស់ភាសាបារាំងនៅពេលនេះតទៅ។

សូមអញ្ជើញ! សូមអញ្ជើញលោកចៅក្រម ហ្សង់ម៉ាក ឡាវែន៍!

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

បាទ សូមអរគុណលោកប្រធាន។

[១៥:០៣:០២]

**សួរដោយចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

**ស៖** ហើយនិងអរគុណលោកអ្នកជំនាញដែលឆ្លើយតបជាភាសាបារាំង។ ខ្ញុំគិតថា នៅពេលដែលចោទសំណួរលោកជាភាសាអង់គ្លេស លោកអាចឆ្លើយតបជាភាសាអង់គ្លេសបាន។ បាទ ឥឡូវយើងត្រឡប់មកនិយាយអំពីសំណួរទាក់ទងទៅនឹងគោលនយោបាយសមូហភូណីយកម្ម ហើយនិងសហករណ៍។ តើជាការត្រឹមត្រូវដែរឬទេក្នុងការនិយាយថា គោលនយោបាយនេះត្រូវបានបង្កើតឡើងតាំងពីថ្ងៃទី២០ ឧសភា ឆ្នាំ១៩៧៣? តើពីដើមទីនោះមានមូលហេតុនៃការធ្វើយ៉ាងណាឱ្យងាយស្រួលក្នុងការធានាដល់ការផ្គត់ផ្គង់ជាស្រូវ អង្ករ អំពីសំណាក់របស់កងកម្លាំងបដិវត្តន៍ ហើយនិងការធ្វើយ៉ាងដូច្នេះដើម្បីជៀសវាង កុំឱ្យកងទ័ពវៀតណាម ធ្វើឱ្យរាំងស្ទះដល់ការផ្គត់ផ្គង់ស្រូវ អង្ករនេះទៅតំបន់រំដោះ។ តើត្រឹមត្រូវដែរឬទេក្នុងការនិយាយយ៉ាងដូច្នេះ?

**លោក ហ្វីលីព ស្សូត៖**

**ឆ៖** បាទ ខ្ញុំគិតថា ជាការត្រឹមត្រូវគឺថាមានមូលហេតុទាំងពីរហ្នឹងឯង ក្នុងការរៀបចំការផ្គត់ផ្គង់ស្រូវ អង្ករ ហើយនិងការរាំងស្ទះមិនឱ្យវៀតណាមបង្ករាំងស្ទះ ប៉ុន្តែការងារទាំងអស់នេះត្រូវបានធ្វើឡើងពេលក្រោយមកទៀត។

**ស៖** អ៊ីចឹងគឺថាទិសដៅ គឺជាគោល -- ទិសដៅមនោគមន៍វិជ្ជាក្នុងការបង្កើតសង្គមមួយស្អាតស្អំ ហើយនិងស្មោះត្រង់ នេះគឺជាពាក្យសម្ដីដែលបានប្រើនៅក្នុងសៀវភៅលោក។ ហើយទៅតាម

ធម្មតាចំពោះអ្នកដឹកនាំ គឺការពាណិជ្ជកម្ម គឺចំពោះអ្នកដឹកនាំខ្មែរក្រហមនេះ មិនជាការល្អទេ មិនស្មោះត្រង់ទេ។ ហើយនៅក្នុងផ្នែកមួយទៀតនៃសៀវភៅរបស់លោក ដើម្បីលោកលើកឡើងថា ដើម្បីបញ្ជាក់ពីមូលហេតុនៃការធ្វើយ៉ាងដូច្នេះ ប៉ុល ពត បានបំប្លែងតថភាពដោយបញ្ជាក់ថា ដែលអះអាងថាប្រជាជនបីភាគបួនរស់នៅក្នុងភាពក្រីក្រមែនទែន។

[១៥:០៥:៣៩]

ចាប់ពីឆ្នាំ១៩៧៣ គោលនយោបាយបង្កើតសហករណ៍ខ្មែរក្រហម គឺឈរផ្អែកលើ ធ្វើចេញដោយសារមានភាពទុរ្ភិក្ស ដែលប្រជាជនខ្មែររស់នៅក្នុងរបបចាស់។ អ៊ីចឹងសហករណ៍ទាំងអស់នេះជាការរីកចម្រើនរបស់ខ្មែរក្រហម ពីព្រោះថាភាគច្រើនសប្បាយចិត្ត ហើយនិងស្មោះត្រង់ប្រព័ន្ធសមូហភាពថ្មីនេះ។ ដូចដែល ប៉ុល ពត បានលើកឡើង។ ការមិនសប្បាយចិត្តនោះ ត្រូវបានចាត់ទុកថាជាសញ្ញានៃសត្រូវវណ្ណៈ។ ដូចករណីភាគច្រើននៃវិធានការជាច្រើន គឺថា ប៉ុល ពត បានលើកឡើងថា យើងត្រូវតែកាត់ជើងតម្រូវនឹងស្បែកជើង។ តើលោកបញ្ជាក់អំពីដែលខ្ញុំទើបតែបានអានអម្បាញ់មិញនេះទេ? ហើយលោកអាចពន្យល់ខ្លះៗបានទេ?

**ឆ៖** តាមខ្ញុំបញ្ជាក់រក្សាខ្លឹមសារនេះដដែល គឺថាមានសម្រង់មួយដែលខ្ញុំចង់លើកឡើង មិនមែនថាត្រឹមតែកាត់ស្បែកជើង -- អ៉ំ!កាត់ស្បែកជើងតម្រូវតាមស្បែកជើងទេ។ ប៉ុន្តែម្តាយខ្ញុំដែលកាលណោះគាត់ជានិស្សិតនៅទីក្រុងប៉ារីសជាមួយ ប៉ុល ពត ដែរ ហើយដែលធ្លាប់នៅប្រទេសខ្មែរដែរក្នុងបដិវត្តន៍នោះ មានការលើកឡើងត្រឹមតែថា ក្នុងមនុស្សទាំងអស់ត្រូវតែកម្ពស់ត្រឹម ១,៦០ម៉ែត្របានហើយ។ អ៊ីចឹងអ្នកណាក៏ដោយរស់នៅរបបកម្ពុជាប្រជាធិបតេយ្យ ត្រូវតែស្របទៅនឹងពុម្ពដែលគេកំណត់ឲ្យ។ អ៊ីចឹង ពីព្រោះថា ប៉ុល ពត ដឹងច្បាស់ណាស់ថា ទោះបីជាមនុស្ស៧៥ភាគរយរស់នៅក្នុងភាពខ្វះខាត ហើយនិងទុរ្ភិក្សនោះ អានេះមិនមែនជាការពិតទេ។ នៅពេលដែលប្រជាជន ឬក៏មនុស្សចង់ចូលបក្សកុម្មុយនីស្តកម្ពុជាពួកអ្នកទាំងអស់នោះ ថ្នាក់ដឹកនាំនោះ ទទួលយកតែប្រជាកសិករសុទ្ធសាធទេ ឬក៏អ្នកវណ្ណៈក្រោមមធ្យម។ គឺថាមានក្រ ថ្នាក់ក្រោមក្រ ថ្នាក់លើអី ថ្នាក់ក្រោមថ្នាក់លើនោះ គឺគេមិនទទួលយកធ្វើជាបក្ខជនទេ។

[១៥:០៨:២៩]

អ៊ីចឹងគេដឹងថា មិនមែន៧៥ភាគរយដែល ប៉ុល ពត លើកឡើងនោះទេ គឺថាមានតិចជាងហ្នឹង ច្រើនណាស់អ្នកដែលថា ប៉ុល ពត បានលើកឡើងថាក្រក្នុងភាពទុរ្គិក្សនោះ។

**សៈ** អ៊ីចឹងគឺថាទទួលយកអ្នកណាម្នាក់មកចូលបក្សនោះ ទាល់តែអ្នកនុ៎ងជាអ្នកក្រ ហើយ ទទួលយកគោលនយោបាយរបស់បក្ស។ អ៊ីចឹងមែនទេ?

**ឆៈ** បាទ ត្រឹមត្រូវហើយ។ ខ្ញុំៗ គឺថាការដែលយើងនិយាយថាក្រីក្រនោះ គឺថាអ្នកដែលមិន ទទួលអំពើពុករលួយដោយសារឃើញទ្រព្យសម្បត្តិ។ ការភាពចាំបាច់ចេញ -- ឥឡូវខ្ញុំសូមនិយាយទៅ ឯកសារមួយទៀត គឺទស្សនាវដ្ដីបដិវត្តចុះខែសីហា ឆ្នាំ១៩៧៥ គឺឯកសារ E3/5 ERN ជាភាសាខ្មែរគឺ 00357556 រហូតដល់ 7597, ជាភាសាបារាំងគឺ 00538953 ទៅដល់ 62, ជាភាសាអង់គ្លេស គឺ 00401477 ទៅដល់ 1487។ បាទ នេះគឺជាអត្ថបទមួយដែលមានចំណងជើងថា “កម្មាភិបាល សមាជិកបក្សប្រជាជន និងកងទ័ពបដិវត្តន៍ ត្រូវតែស្របជាមួយបក្សដើម្បីពិនិត្យ និងវាយតម្លៃស្ថានភាព -- ស្ថានការណ៍ ដើម្បីបំពេញភារកិច្ចឲ្យបានជោគជ័យ ដោយមហាលោតផ្លោះ”។ ដូច្នេះកន្លែងនេះ ជា អត្ថបទដែលចុះនៅខែឧសភា ឆ្នាំ១៩៧៣ ដែលជាកាលបរិច្ឆេទ ដែលចាប់ពីពេលហ្នឹងទៅ គេនឹងធ្វើ នយោបាយប្រជាធិបតេយ្យដាច់ខាត -- បដិវត្តន៍ប្រជាធិបតេយ្យដាច់ខាត។ ដូច្នេះ គឺជាការធ្វើសមូហ-ភាពថា បំបាត់ដីធ្លី ហើយនិងបង្កើតសហករណ៍ ហើយនិងលុបបំបាត់រូបិយប័ណ្ណ គឺការត្រឡប់មកការ ដោះដូរទ្រព្យសម្បត្តិវិញ។ គេឲ្យអ្នកពាណិជ្ជកម្មហ្នឹងធ្វើការដោះដូរវិញ ហើយនិងធ្វើការងារ ដោយដៃ ហើយនិងធ្វើការដាំដុះ។

[១៥:១១:៤៥]

នៅទំព័រមួយទៀត គឺថា ERN 00538961 បើសិនយើងរក្សាទុក រក្សាទីក្រុងភ្នំពេញ គឺថាទ្រព្យ សម្បត្តិផ្ទាល់ខ្លួន ឬឯកជន នឹងមានអំណាចខ្លាំង។ បើពួកគេនៅស្រុកស្រែនោះ គឺថាយើងអាចគ្រប់គ្រង ផ្នែកឯកជនបាន។ បើសិនជាយើងទុកឲ្យនៅភ្នំពេញហ្នឹង គឺថាយើងមិនអាចគ្រប់គ្រងបានទេ។ ឥឡូវនេះ យើងបានជម្លៀសមនុស្សចេញពីទីក្រុងអស់ហើយ។ អ៊ីចឹងបានន័យថាទ្រព្យសម្បត្តិសួនតួនោះ លែង មានឥទ្ធិពលអីទៀត។

កាលពីព្រឹកមិញ លោកបានលើកឡើងថា ការធ្វើសមូហភាវូបនីយកម្មបានជំរុញ -- បានលើក ឡើងដោយ ប៉ុល ពត ថា នេះជាមូលហេតុនៃការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ។ តើអ្វីដែលខ្ញុំ

ទើបតែនឹងអាននេះ ផ្ទុះបញ្ជាំងពីមូលហេតុដែល ប៉ុល ពត បានលើកឡើង ឬក៏យ៉ាងណា? ឬក៏ជាអ្វីដែលលោកបាននិយាយពេលក្រោយមកហើយទេ?

[១៥:១២:៥៦]

**ឆ៖** ខ្ញុំយល់មិនច្បាស់ទេ ថាអ្វីដែលបន្ថែមពេលក្រោយអំមិញនេះ ខ្ញុំស្តាប់មិនទាន់។

**ស៖** តើមូលហេតុមនោគមន៍វិជ្ជានោះ បានកើតមុនពេលដណ្តើមបានទីក្រុងភ្នំពេញ ឬក៏ក្រោយពេលដែលដណ្តើមទីក្រុងភ្នំពេញហើយ។ គឺថាមនោគមន៍វិជ្ជាដែលជាមូលហេតុនៃការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ?

**ឆ៖** បាទ គឺកើតមុន។ មូលហេតុមនោគមន៍វិជ្ជានេះសំខាន់ណាស់។ អ៊ីចឹងយើងត្រូវគិតដល់ប្រទេសចិនផងដែរ ដែលកាលណោះ នៅជនបទ គេ -- ស្រុកជនបទ ចំពោះអ្នកបដិវត្តខ្មែរវិញ គឺថាស្អាតស្អំជាងទីក្រុង។ ហើយក៏វាជាមធ្យោបាយ ឬក៏បំបាត់ភាពពុករលួយរបស់មនុស្សនៅទីក្រុងផងដែរ។ ដូច្នេះនេះគឺជាមូលហេតុមួយ។ គឺថានៅពេលមួយ គឺថាមុន ឧសភា ឆ្នាំ៧៣ នៅពេលដែល ប៉ុល ពត ចាប់ផ្តើមដឹងថាពាណិជ្ជកម្មៗនៅជនបទនោះ បានចាប់ផ្តើមកើតមានឡើងវិញ។ អ៊ីចឹង ពេលនោះហើយបានគាត់ចាប់ផ្តើមថាធ្វើ ចាត់វិធានការផ្តាច់ការតែម្តង ដើម្បីបំបាត់ពាណិជ្ជកម្មនេះ។

[១៥:១៤:៣៦]

**ស៖** អ៊ីចឹងការធ្វើផ្តាច់ការដែលកើតមានឡើងនៅឆ្នាំ៧៣នេះ ថាកើត គឺថាត្រូវបានផ្ទុះបញ្ជាំងដោយសារបំបាត់ ការបំបាត់រូបិយប័ណ្ណដែលធ្លាប់មានពីមុនមក ដែលយើងធ្លាប់បានដឹងពីមុនមក។ អ៊ីចឹងមែនទេ?

**ឆ៖** តាមពិតមានពីរដំណាក់កាល។ ចាប់ពីឆ្នាំ១៩៧៣ គាត់ចាប់បង្កើតឲ្យមាននៅគេហៅថារបបដោះដូរសម្ភារៈគ្នានៅតាមជនបទ ក៏ប៉ុន្តែនៅពេលនោះមិនត្រូវប្រើប្រាស់ក្រដាសប្រាក់ លន់ នល់ នោះទេ មិនមែនដោយសារលុយនោះវាអាក្រក់នោះទេ។ ក៏ប៉ុន្តែនៅពេល ក្នុងពេលជាមួយគ្នានោះ នៅតំបន់រំដោះនោះក៏គេមានប្រើលុយនៃរបប លន់ នល់ ដែរ។ ហើយអ៊ីចឹងក៏គេចាប់ផ្តើមសុំឲ្យចិននោះបោះពុម្ពលុយបដិវត្តន៍នៅឆ្នាំ១៩៧៤ អង្កាល់នោះ ក៏នៅតែមានគ្រោងថា ការឲ្យមានការចាយវាយក្រដាសប្រាក់នៅកម្ពុជាប្រជាធិបតេយ្យដែរ។ តែក្រោយមក គឺថាចាប់ពីក្រោយឆ្នាំ៧៥ -- មេសា ៧៥ អ្វីដែលនៅសល់ពីធនាគារជាតិហ្នឹងថា វាខូចខាតអស់ហើយ ក៏ប៉ុន្តែខ្មែរក្រហមនៅតែព្យាយាមក្នុងការបង្កើត

ប្រព័ន្ធមួយក្នុងការបែងចែកថវិកា។ ក៏ប៉ុន្តែក្រោយមកទៀត នៅក្នុងឆ្នាំ៧៥ ដដែលគឺថាមានការសម្រេចចិត្តក្នុងការបញ្ឈប់ការបែងចែកលុយ ចែកចាយលុយដូចតាម៉ុក បានលើកឡើងអ៊ីចឹង។ គឺថារបួសមិនទាន់ជាទេ អ៊ីចឹងមិនត្រូវអេះរបួសនុ៎ងទៀតទេ ពីព្រោះថា ធ្វើឲ្យចេញឈាម។

[១៥:១៦:៤៣]

អ៊ីចឹងពួកខ្មែរក្រហមក៏ឈប់ឲ្យប្រើលុយកាក់នេះទៅ។ នេះគឺជាសេចក្ដីសម្រេចមួយដ៏សំខាន់ ពីព្រោះថានៅពេលដែលគ្មានលុយទេ យើងពុំមានជម្រើសអ្វីទាំងអស់ ទោះបីជាសម្រាប់កិច្ចការតូចមួយក៏ដោយ។ នេះគឺជាមូលហេតុមួយ ឬក៏ជានិមិត្តរូបមួយនៃរបបទាសករនិយមនេះ ដែលខ្ញុំបានសរសេរនៅក្នុងសៀវភៅរបស់ខ្ញុំ។

**ស៖** តើលោកជឿជាក់ទេ? ច្បាស់លាស់ទេថា ការបំបាត់រូបិយប័ណ្ណនេះត្រូវបានសម្រេចក្រោយ ១៧ មេសា ៧៥ ទេ ឬក៏សម្រេចតាំងពីមុន ១៧ មេសា ៧៥ ទៀត?

**ឆ៖** បាទ ខ្ញុំច្បាស់ណាស់ ពីព្រោះថា ពេជ ជាង ដែលក្លាយជាឯកអគ្គរាជទូតរបស់កម្ពុជាប្រជាធិបតេយ្យនៅប្រទេសចិន នៅឆ្នាំ១៩៧៥ ត្រូវបានតែងតាំងជាប្រធានធនាគារជាតិ ដើម្បីចែកចាយលុយនេះ ហើយយើងខ្ញុំបានសម្ភាសន៍គាត់។ គាត់បាននិយាយថា មានអ្នកខ្លះផ្ដល់សក្ខីកម្មអំពីសហ-ករណ៍របស់ខ្លួន ពួកគាត់បានបង្ហាញរូបលុយដែលនឹងចេញទៅថ្ងៃមុខនោះ លុយរបស់ -- រូបិយបណ្ណរបស់របបថ្មី។ ដូច្នេះ គឺថា មុនមានអស់រយៈពេលជាច្រើនខែ ដែលគេរៀបចំជាយន្តការដើម្បីបង្កើតឲ្យចេញជារូបិយប័ណ្ណនេះ។

[១៥:១៨:៤៥]

**ស៖** ទាក់ទងទៅនឹងការបង្កើតគោលនយោបាយសមូហភាព គឺថាតាមការបង្កើតសហករណ៍ហើយនិងនេះ គឺថាជាការរកបំបាត់ខ្មាំង ក្នុងបំណងអ៊ីចឹង ដើម្បីឲ្យដឹងថាអ្នកណាជាខ្មាំង អ្នកណាយល់ស្រប អ្នកណាមិនយល់ស្រប ឬក៏យ៉ាងម៉េច?

**ឆ៖** បាទ អ៊ីចឹង ខ្ញុំមិនដឹងថាវាជាមូលហេតុបន្ទាប់បន្សំ ឬក៏ជាគុណប្រយោជន៍របស់សហ-ករណ៍ទេ។ ខ្ញុំពិបាកនឹងនិយាយ ក៏ប៉ុន្តែការបង្កើតជាសហករណ៍នេះ វាសម្រួលការងារខ្មែរក្រហម។

**ស៖** បាទ ខ្ញុំមានសំណួរទូទៅមួយមុននឹងចូលប្រធានបទមួយទៀត។ បាទ ជាទូទៅនៅក្នុង

សៀវភៅរបស់លោក ខ្ញុំគិតថា លោកប្រហែលជាអានសៀវភៅនេះមុននឹងមកដល់ទីនេះហើយ នៅថ្ងៃនេះៗ តើលោកយល់ស្របទៅលើអ្វីដែលលោកបានសរសេរ ឬក៏មានផ្នែកណាមួយដែលក្រោយមកនោះរយៈពេលបានកន្លងផុតទៅ លោកមានការយល់ឃើញដូចខុសពីហ្នឹងបន្តិច ឬក៏ចុងកែប្រែលើអ្វីដែលលោកបានសរសេរ ព្រោះថាចំណុចនេះសំខាន់ណាស់ចំពោះតុលាការ?

[១៥:២០:២៦]

**ឆ៖** ខ្ញុំអានសៀវភៅខ្ញុំឡើងវិញ មានភាពច្រំដែលមួយចំនួនដែលត្រូវលុបចោល បើគិតជាផ្នែករចនាបថនោះ។ ក៏ប៉ុន្តែជាទូទៅមិនមានអ្វីដែលត្រូវដោះដកចេញនោះទេ។ ទោះបីយ៉ាងណាក៏ខ្ញុំគិតថាវានៅតែជាសៀវភៅមួយអាចទទួលយកបាន។

**ស៖** បាទឥឡូវយើងចូលទៅនិយាយពីប្រធានបទមួយទៀតដែលទាក់ទងទៅនឹងតួនាទីរបស់លោក ខៀវ សំផន។ បន្ទាប់ពីសម្ដេច សីហនុ ត្រូវបានទម្លាក់ចេញពីអំណាច ហើយចាប់ពីថ្ងៃ២៦ មីនា ឆ្នាំ៧០ គឺកាលណោះមានលិខិតមួយដែលផ្ញើជូនទៅរណសិរ្ស គឺថាលិខិតគាំទ្ររណសិរ្សដែលគាំទ្រ ខៀវ សំផន, ហ៊ូ យន់, ហ៊ូ នឹម។ ហើយលោកបានបង្ហាញថាសំបុត្រនេះប្រហែលជាទំនងសរសេរដោយ ប៉ុល ពត ដែលកាលណោះគាត់ទំនងជាស្នាក់នៅទីក្រុងប៉េកាំង។ តើលោកអាចបញ្ជាក់ចម្លើយនេះលោកបានទេ ឬក៏លោកអាចធ្វើការពន្យល់បន្ថែមបន្តិចបានទេ?

[១៥:២១:៤១]

**ឆ៖** អង្កាល់នោះ ប៉ុល ពត មិនមែននៅប៉េកាំងទេ។ តាមពិតគាត់ទៅធ្វើទស្សនកិច្ចគឺថានៅពេលដែលគេទម្លាក់សម្ដេច សីហនុ ពីអំណាចនោះ គាត់នៅទីក្រុងប៉េកាំង គាប់ជួនអ៊ីចឹងទេ។ មិនមែនគាត់នៅទីនោះទេ។ ក៏ប៉ុន្តែបើតាមផ្នែកសម្ភារៈនោះ គឺថាសំបុត្រមួយអាចទៅដល់ប៉េកាំងលឿនយ៉ាងដូច្នេះទេ។ អ៊ីចឹងបើយើងពិចារណាលើស្ថានភាពនេះគឺថា បើតាមប្រភពចិន គឺថា ប៉ុល ពត អ្នកសរសេរ។ សំបុត្រនោះត្រូវបានបោះពុម្ពនៅទីក្រុងប៉េកាំង! អ៊ីចឹងអ្វីដែលអាចកើតឡើងហ្នឹង គឺ ប៉ុល ពត ខ្លួនគាត់ផ្ទាល់ ឬក៏អ្នកនៅជុំវិញគាត់។ អ្នកយកសំបុត្រហ្នឹងទៅ ឬក៏សរសេរសំបុត្រហ្នឹង។ ហើយការសរសេរសំបុត្រនេះមានភាពប៉ិនប្រសប់ណាស់។ គឺថាមិនធ្វើឱ្យអ្នកណាភ័យខ្លាចនោះទេ ហើយមិនឱ្យនិយាយអាក្រក់ពីលទ្ធិកុម្មុយនីស្តនោះទេ។ អ៊ីចឹងគ្មានអ្វីក្រៅពី ប៉ុល ពត ទេជាអ្នកសរសេរនោះ។

**ស៖** ក្រោយពីការបោះពុម្ពផ្សាយសំបុត្រនេះបន្តិច គឺថាមានការបង្កើតរណសិរ្សរួបរួមជាតិកម្ពុជា។ ហើយយើងដឹងថាលោក ខៀវ សំផន មានវត្តមានក្នុងឋានៈជាឧបនាយករដ្ឋមន្ត្រី ហើយនិងជាអគ្គមេបញ្ជាការនៃកងទ័ពប្រជាជនរំដោះជាតិកម្ពុជា។ តើលោកដឹងថាលោក ខៀវ សំផន នោះបាន -- បាទ ខ្ញុំនិយាយក្រោយពេលរដ្ឋប្រហារ។ លោក ខៀវ សំផន អាចជួប ប៉ុល ពត នៅពេលណា? និង សីហនុ នៅពេលណា? តើលោកមានយោបល់អីទេ?

[១៥:២៣:៤៩]

**ឆ៖** បើតាមខ្ញុំចាំ គឺនៅពេលដែល ប៉ុល ពត មកតាំងលំនៅនៅជិតកំពង់ធំ គឺថាគាត់លែងនៅរតនគិរីទៀតហើយ។ គាត់បានចុះមកកំពង់ធំវិញ។ គឺថាមកផ្នែកកណ្ដាលប្រទេសតែម្ដង។ ហើយទីបញ្ជាការថ្មីរបស់បក្សកុម្មុយនីស្តកម្ពុជាហ្នឹង គឺថានៅជិតកំពង់ធំ។ ហើយ ខៀវ សំផន និងអ្នកដទៃទៀតនោះបានចេញពីភ្នំឱរ៉ាល់ ដែលគាត់ឈរជើង ហើយគឺថានៅពេលនោះហើយ ដែល ប៉ុល ពត និង ខៀវ សំផន បានធ្វើទំនាក់ទំនងគ្នា ឬក៏ជួបគ្នានោះ។

ខៀវ សំផន និងសម្ដេច សីហនុ ចំពោះអ្នកទាំងពីរនេះវិញ ខ្ញុំគិតថាប្រហែលជាអ្នកពួកគាត់ទាំងពីរនាក់នេះបានជួបគ្នានៅទីក្រុងប៉េកាំងរួចហើយ មុននឹងពេលដែលសម្ដេច សីហនុ បានមកធ្វើទស្សនកិច្ចនៅតំបន់រំដោះនោះ។ ក៏ប៉ុន្តែទោះបីជាណាក្តី គឺថា ខៀវ សំផន មានទំនាក់ទំនងតិចបំផុតជាមួយសម្ដេចសីហនុ ពីព្រោះថាកាលនោះ អៀង សារី ជាអ្នកតំណាងឲ្យបក្សកុម្មុយនីស្តនៅប៉េកាំង។ ហើយអីចឹង គឺថាអ្វីទាំងអស់នោះឆ្លងកាត់តាម អៀង សារី ហើយកាលនោះ ជួន ម៉ុម ដែលជាអតីតនិស្សិតនៅប៉ារីស គាត់បានចូលរួមជាមួយ សីហនុ ក្រោយពេលដែលសម្ដេច សីហនុ ត្រូវបានទម្លាក់ពីអំណាចហើយ។

[១៥:២៥:២៨]

**ស៖** ប្រហែលជាក្រុមមេធាវី ខៀវ សំផន អាចបំភ្លឺបានត្រង់ចំណុចនេះ។ ខ្ញុំមិនច្បាស់ថា ខៀវ សំផន បានសំណេះសំណាលគ្នានៅប៉េកាំងទេ មុនពេលដែលសម្ដេច សីហនុ បានមកប្រទេសកម្ពុជានៅឆ្នាំ១៩៧៣ ក្នុងតំបន់រំដោះ។ ខ្ញុំគិតថា ប្រហែលយើង ប្រហែលជាអាចច្រឡំ ក៏ប៉ុន្តែមេធាវី ខៀវ សំផន អាចបំភ្លឺចំណុចនេះបាន ប្រសិនជាយើងច្រឡំនោះ។ ក៏ប៉ុន្តែទោះជាយ៉ាងណាក្តី ក្រោយពីការបង្កើតរាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា តើមាន ខៀវ សំផន មានបានជួបជាមួយ សីហនុ ឬក៏សម្ដេច សីហនុ

បានពិគ្រោះជាមួយ ខៀវ សំផន អីពេលណាមួយទេ? បើសិនជាលោកមិនដឹងទេ លោកមិនបាច់មានយោបល់អ្វីក៏បានដែរបាទ។

**ឆ៖** បាទ ខ្ញុំគិតថាគាត់មិនត្រូវបានពិគ្រោះ ឬក៏សុំយោបល់អីគាត់ទេ ខ្ញុំមិនជឿថាអាចកើតមានឡើងទេ កាលណោះ ប៉ុល ពត នៅប៉េកាំង ហើយមានសម្តេច សីហនុ, មាន ជួន ម៉ុម ហើយនិងអ្នកផ្សេងទៀត ហើយអ៊ីចឹងគឺថាកាលនោះមានទំនាក់ទំនងគឺថាអាចមានជាមួយអ្នកទាំងប៉ុន្មាននាក់ហ្នឹង ហើយនិង ជូ អេនឡាយ តែប៉ុនន៉ុងទេ។

[១៥:២៦:៥៧]

**សៈ** គឺថាជាសេចក្តីសម្រេចមួយសំខាន់ណាស់ ព្រោះថាការតែងតាំងមនុស្សម្នាក់ជានាយករដ្ឋមន្ត្រីនេះវាសំខាន់ណាស់ ហើយក៏ប្រហែលជាលោក ខៀវ សំផន ក៏មានចំណាប់អារម្មណ៍អីដែរ។ តើពេលនោះគាត់ទទួលតួនាទីមួយ ហើយគាត់បានលើកឡើងហើយ គាត់ថាតួនាទីគាត់នោះគឺថា ដើម្បីផ្សារភ្ជាប់ខ្មែរក្រហម និងរណសិរ្ស។ អ៊ីចឹងខ្ញុំចង់សួរលោកថា តើការផ្សារភ្ជាប់ទំនាក់ទំនងនេះជា -- មានលក្ខណៈបែបណាដែរ?

**ឆ៖** កាលពីព្រឹកមិញ ខ្ញុំបាននិយាយថា ខៀវ សំផន នោះគាត់ស្មោះត្រង់នឹងបុព្វហេតុណាស់ អ៊ីចឹងគាត់អនុវត្តបញ្ជា។ ហើយខ្ញុំគិតថា ប៉ុល ពត ទុកចិត្តលើ ខៀវ សំផន។ ហើយគាត់ទុកចិត្តដោយមិនមានបារម្ភអ្វីទេ។ ហើយឃើញថារវាង ប៉ុល ពត ហើយនិង ខៀវ សំផន នេះគឺអាច -- ដែល ខៀវ សំផន នៅជាមួយ ប៉ុល ពត នៅកំពង់ធំ អ៊ីចឹងការទំនាក់ទំនងជាមួយ សីហនុ នោះត្រូវតែឆ្លងកាត់តាម អៀង សារី ហើយ ឬក៏តាមចិនហើយ។ រាល់ការទាក់ទងទាំងអស់ គឺថាឆ្លងកាត់តាម អៀង សារី ព្រោះថាប្រហែលជា -- ហើយខ្ញុំគិតថា ខៀវ សំផន នេះគាត់ដើរតួនាទីនេះពេលក្រោយមកហើយទេ គឺថាផ្សារភ្ជាប់ទំនាក់ទំនងនោះ។

[១៥:២៨:៣៨]

**សៈ** លោកបានពន្យល់គឺថា ប៉ុល ពត បាន -- ប្រហែលជាបានសម្រេចតែងតាំង ខៀវ សំផន ឲ្យកាន់ប៉ុស្តិ៍ជាយុទ្ធសាស្ត្រនេះ ជាឧបនាយករដ្ឋមន្ត្រី ពីព្រោះគាត់ដឹងថា ខៀវ សំផន ជាអ្នកស្មោះត្រង់ ហើយនិងបុព្វហេតុ ហើយគាត់ទទួលយកសេចក្តីសម្រេចរបស់ ប៉ុល ពត តើខ្ញុំត្រូវយល់យ៉ាងដូច្នេះ ឬក៏យ៉ាងម៉េច?

**ឆៈ** មិនមែនជាតំណែងជាយុទ្ធសាស្ត្រអ្វីទេ គ្រាន់តែជាខែលតែប៉ុណ្ណឹងទេ។ គាត់គ្រាន់តែជាគេហៅថា ជានិមិត្តរូបតែប៉ុណ្ណឹងទេ។

**សៈ** អានេះបើសិនជាយើងនិយាយថាគ្រាន់តែជាខែល ឬជាម៉ាកនុំង គឺវាអាចថាមានប្រយោជន៍ផ្នែកយុទ្ធសាស្ត្រចំពោះសាធារណជននោះ គឺថាគាត់ត្រូវមានមនុស្សបង្អែក គឺថាដែលមានភាពស្មោះត្រង់ ហើយដែលមិន ដែល -- អ៊ីចឹងគឺប្រហែលជារូបភាពជារូបភាពយុទ្ធសាស្ត្រ ឬក៏យ៉ាងម៉េច?

**ឆៈ** បាទ បើយើងគិតពីរូបភាពវិញនោះ គឺថាខ្ញុំយល់ស្របថា នេះវាជាអាចជាយុទ្ធសាស្ត្រមួយ ក៏ប៉ុន្តែបើយើងគិតអំពីផ្នែកឥទ្ធិពលវិញ ពីសំណាក់អ្នកដឹកនាំនោះ មិនមានប្រយោជន៍អីទាល់តែសោះ មានសារសំខាន់អីទាស់តែសោះ។

**សៈ** តើចំពោះលោកនោះ តើលោក ខៀវ សំផន បានយល់ព្រមធ្វើជាខែល ឬក៏ជារូបភាពមួយ ឬក៏គាត់សុខចិត្តទទួលយកការសម្រេចដែលគេធ្វើឲ្យគាត់ក្លាយជាអ្នកមានតួនាទីក្នុងការដឹកនាំប្រទេស?

[១៥:៣០:៤៣]

**ឆៈ** បាទ នេះជាសំណួរសំខាន់មែនទែន។ ក៏ប៉ុន្តែចម្លើយប្រហែលជាមិនសំខាន់ដល់សំណួរនេះទេ។ ខ្ញុំមានទំនោចង់លើកឡើងថា ក៏ប៉ុន្តែវាអាចគ្រាន់តែជាការសន្និដ្ឋានតែប៉ុណ្ណឹងទេ អំពីអត្តចរិតរបស់លោក ខៀវ សំផន។ គាត់សុខចិត្តធ្វើជាអ្នកអនុវត្តជាជាងអ្នកដែលដឹកនាំ។ អាស្រ័យដូចហេតុដូច្នេះហើយបានជាគាត់មានសារៈសំខាន់ចំពោះ ប៉ុល ពត និងចំពោះរបបខ្មែរក្រហម។ ព្រោះគាត់ថាគាត់ជាមនុស្សគួរឲ្យទុកចិត្តបាន ហើយគាត់មិនសូវចេះដឹកស្នួរដេញដោល។ ហើយអ៊ីចឹងគាត់មនុស្សងាយៗបត់បែន។

**សៈ** បាទ សូមអរគុណដែលបានឆ្លើយតបនឹងសំណួរនេះ។ ឥឡូវនេះ ខ្ញុំសូមចូលទៅប្រធានបទមួយទៀត ទាក់ទងទៅនឹងទំនាក់ទំនងដែលអាចផ្សារភ្ជាប់ខ្មែរក្រហម ហើយនិងសាធារណរដ្ឋប្រជាមានិតចិន។ លោកជាអ្នកជំនាញប្រវត្តិ ប៉ុល ពត ហើយនិងក៏ប្រវត្តិសាស្ត្រចិនផងដែរ។ តើលោកអាចជម្រាបជូនតុលាការបានទេបើតាមលោកចាំនោះ ថាតើកាលបរិច្ឆេទនៃការស្នាក់នៅដំបូងបំផុតរបស់ ប៉ុល ពត នៅប្រទេសចិននោះនៅពេលណាដែរ?

**ឆៈ** កាលនោះគឺថានៅចុងឆ្នាំ១៩៦៥ ហើយចុង -- ដើមឆ្នាំ៦៦។ ខ្ញុំមិនច្បាស់ប៉ុន្មានទេ ប៉ុន្តែ កាលនោះ គាត់នៅ -- កាលនោះប្រហែលជាយ៉ាងច្រើនពី១ខែ ទៅ៦អាទិត្យប៉ុនន៉ុងឯង។ គឺថាកាលនោះ គឺថាចាប់ផ្ដើមមុនបដិវត្តន៍វប្បធម៌ទៀត។ អ៊ីចឹងគាត់ពុំមានបទពិសោធន៍ទៅនឹងរយៈកាលនេះទេ។

[១៥:៣២:៥៦]

**សៈ** បាទ ៦៥, ៦៦ គឺជាពេលដែលគឺថាកាលនោះអាណាព្យាបាលវៀតណាមលើកម្ពុជានោះ ធំធេងណាស់។ ខ្ញុំគិតថាកាលនោះបើគាត់ទៅចិននោះ ត្រូវតែឆ្លងកាត់តាមវៀតណាម។ អ៊ីចឹងមែនទេ?

**ឆៈ** បាទ អ៊ីចឹងហើយ ពិតជាត្រឹមត្រូវហើយ គឺថាគាត់ចង់ទៅប្រទេសចិន ហើយគាត់ក៏ចង់ទៅកូរ៉េខាងជើងផងដែរ ហើយកាលនោះវៀតណាមថា ទេទៅៗមិនបានទេ ទៅកូរ៉េខាងជើងនោះ។ ក៏ប៉ុន្តែទៅ បើសិនទៅចិនវិញ វៀតណាមព្រមឲ្យទៅ។

**សៈ** សំណួរខ្ញុំនេះ ប្រហែលជាស្មុគស្មាញបន្តិចពីព្រោះថាជាទស្សនកិច្ចសម្ងាត់។ តើកាលនុ៎ងនោះ យើងអាចដឹងថាគាត់ជួបមនុស្សប៉ុន្មាននាក់នៅប្រទេសចិន? នៅក្នុងគណៈកម្មការបក្សកុម្មុយនីស្តចិននោះ កាលនោះគាត់អាចជួបប៉ុន្មាននាក់ដែរ ហើយនិងគណៈកម្មាធិការថ្នាក់ដឹកនាំប្រទេសបរទេសផ្សេងៗទៀតនោះ?

[១៥:៣៤:១០]

**ឆៈ** ខ្ញុំដឹងថាគាត់ កាលនោះគាត់ជួប ភឹង យន់ ដែលនៅជាចៅហ្វាយក្រុងប៉េកាំង ហើយត្រូវបានដកចេញពីតំណែងនៅក្នុងបដិវត្តន៍វប្បធម៌ចិន។ ខ្ញុំមិនច្បាស់ទេ ដឹងថាគាត់ជួប កាន់ ឈុង នោះនៅពេលណាទេ។ គឺថាមេធំដែលថាអ្នកផ្សារភ្ជាប់ទំនាក់ទំនងជាមួយខាងក្រៅប្រទេសនោះ។ ហើយកាលនោះ គាត់ក៏ជួបនឹងរដ្ឋមន្ត្រីក្រសួងការបរទេសចិនដែរ។ អាហ្នឹងយើងច្បាស់ហើយ យើងដឹង ហើយក៏ដឹងថាគាត់ស្នាក់នៅវិទ្យាស្ថានសម្រាប់អ្នកធ្វើបដិវត្តន៍នៅខាងទ្វីបអាស៊ី ហើយនិងអាមេរិកឡាទីន។ នៅជាយក្រុងប៉េកាំង ក៏ប៉ុន្តែគឺជាការជួបលើកទី១ ដំបូងតែប៉ុណ្ណឹងទេ។ អ៊ីចឹងខ្ញុំសង្ស័យថា ប្រហែលជាគាត់ត្រឡប់មកស្រុកវិញហ្នឹង ប្រហែលជាថាបានរៀនសូត្រច្រើនពីប្រទេសចិន។

**សៈ** លោកបាននិយាយឈ្មោះ គង់ ឆេង *(តាមសូរស័ព្ទ)* អំមិញនេះ គឺជាឈ្មោះសំខាន់ណាស់ជា កង់ ឆេង *(តាមសូរស័ព្ទ)* កាលនោះ គាត់ជាមនុស្សទទួលបន្ទុកក្នុងការទំនាក់ទំនងបក្សកុម្មុយនីស្ត

បរទេសទាំងអស់ជាមួយប្រទេសចិន។ តើលោកអាចជម្រាបជូនតុលាការបានទេថា គង់ ឆេង *(តាមសូរស័ព្ទ)* ជាអ្នកណា? កង ឆេង ជាអ្នកណា? កង ឆេង *(តាមសូរស័ព្ទ)* នេះគាត់ជាអ្នកណា?

**ឆៈ** កង ឆេង នេះជាសមាជិកគណៈអចិន្ត្រៃយ៍ការិយាល័យនយោបាយ គាត់ជាមនុស្សដែលមានអំណាច ហើយមានឥទ្ធិពលខ្លាំង ដែលត្រូវទទួលការបណ្តុះបណ្តាលនៅសហភាពសូវៀត នៅទសវត្សរ៍ឆ្នាំ៣០ ហើយគាត់នោះ នៅជាប់នឹង ម៉ៅ សេទុង ហើយគាត់ធ្វើការបម្រើ ម៉ៅ សេទុង រហូត។ អ៊ីចឹងគាត់ជាកាលនោះ គាត់ជាប្រធានការិយាយល័យពិសេសមួយ ហើយគាត់នោះ ឈ្មោះគាត់នោះជាអ្នកណាក៏ស្គាល់ដែរ។ កាលនុ៎ង បើសិនជា ប៉ុល ពត និងមិនបានជួបខ្លួនគាត់ផ្ទាល់នោះ យ៉ាងហោចណាស់ក៏គាត់បានជួបអ្នកដែលស្គាល់ កង ឆេង នេះដែរ។ អ៊ីចឹង ខ្ញុំគិតថានេះជាចំណុចសំខាន់នៅក្នុងទស្សនកិច្ចរបស់គាត់នៅប៉េកាំងនេះ។ អ៊ីចឹងគឺអ្នកដែលថាជួយគាំទ្រ ប៉ុល ពត ហ្នឹងសុទ្ធតែជាអ្នកដែលនៅជុំវិញ កង ឆេង នេះទេ។ អ្វី ដល់ក្រោយមកហ្នឹងគេហៅថា ពួកក្រុមទាំងបួនហ្នឹង ពួកដាច់ខាតទាំងបួនហ្នឹង។ អ៊ីចឹងយើងអាចកំណត់ការជួបដំបូងរបស់ ប៉ុល ពត ជាមួយនឹងអ្នកដែលដាច់ខាតបំផុតរបស់ចិន។ អ៊ីចឹងថាវាក្នុងអំឡុងរវាងចុង៦៥ ដើម៦៦។

[១៥:៣៧:៤៦]

**សៈ** បាទ យើងដឹងថា ប៉ុល ពត នៅប៉េកាំងនៅឆ្នាំ១៩៧០។ តើនៅចន្លោះឆ្នាំ៦៦ នៅឆ្នាំ-- និងឆ្នាំ៧០ ហ្នឹង តើ ប៉ុល ពត ត្រឡប់ទៅប៉េកាំងទៀតទេ?

**ឆៈ** ចម្លើយអត់ទេ។ បើតាមយើងដឹងនោះ គឺថាគាត់អត់បានធ្វើដំណើរទៅក្រៅប្រទេសទេក្រៅពីការទស្សនកិច្ចពីរនោះ។

**សៈ** នៅក្នុងសៀវភៅរបស់លោកនោះ មានកំណត់សម្គាល់ជើងទំព័រមួយដែលមានសារៈសំខាន់ណាស់ដែលយោងទៅដល់ការសម្ភាត់ ដែលលោកបានទទួលពីលោក អៀង សារី ពីព្រោះលោកបានសម្ភាសលោក អៀង សារី។ ក្នុងនោះ អៀង សារី គាត់បានប្រាប់លោកថា "នៅឆ្នាំ៧០ ប៉ុល ពត ប្រហែលជាមានទំនាក់ទំនងញឹកញាប់ជាមួយនឹង កាង សេង(Kang Sheng)។ តើលោកបានលើចម្លើយនេះពីលោក អៀង សារី ផ្ទាល់ ឬក៏យ៉ាងណា? ហើយតើយ៉ាងម៉េចដែរចំពោះបញ្ហាអ្វីដែលលោក អៀង សារី បានប្រាប់លោកនេះ?

**ផ៖** បាទ គឺខ្ញុំរក្សាចម្លើយហ្នឹង គឺនៅឆ្នាំ៧០ គឺគាត់បានជួប។ ខ្ញុំមិនបានសរសេរនៅក្នុងសៀវភៅទេពាក់ព័ន្ធនឹងបញ្ហាចិននោះ ក៏ប៉ុន្តែ -- បាទពិតមែន គឺថាពាក់ព័ន្ធនឹងចំណុចដែល អៀង សារី បានលើកឡើងនោះ។ ខ្ញុំគិតថា គឺថានៅដើមឆ្នាំ៦៦ គឺមានទំនាក់ទំនងជាមួយ កាង សេង។

[១៥:៣៩:២៨]

**ស៖** ខ្ញុំសូមបញ្ជាក់ថាកំណត់សម្គាល់ជើងទំព័រដែលខ្ញុំនិយាយដល់នោះ គឺលេខ២០០ ជាភាសាអង់គ្លេស នៅក្នុងសៀវភៅរបស់លោកដែលមានលេខ ERN ជាភាសាអង់គ្លេស 00396704 គឺនៅទំព័រ ២៥៩។ នៅក្នុងសៀវភៅជាភាសាបារាំង ERN គឺ 00639714 ពាក់ព័ន្ធទៅនឹងលោក កាង សេង ដដែលនេះ។ នៅក្នុងសំណុំរឿង យើងមានសេចក្តីសង្ខេបនៃការផ្សាយព័ត៌មានមួយគឺរបស់ FBES គឺជាផ្សាយវិទ្យុរបស់ទីក្រុងភ្នំពេញរបស់ -- នៃផ្ទៃកក្នុង យើងឃើញមានលេខ E3/1356 ERN ជាភាសាអង់គ្លេស 00167593, ERN ជាភាសាបារាំង 00700106។ នេះជាការផ្សាយពាក់ព័ន្ធទៅនឹងការរំលែកទុក្ខរបស់សាធារណរដ្ឋប្រជាមានិតចិនក្រោយពីមរណភាពរបស់លោក កាង សេង។ ការផ្សាយនេះគឺនៅថ្ងៃ២៤ ខែធ្នូ ឆ្នាំ១៩៧៥។ ខ្ញុំសូមបញ្ជាក់ថាមានការទៅស្ថានទូតនោះ គឺមាន ប៉ែន នុត, មានឧបនាយករដ្ឋមន្ត្រី ដូចជាលោក ខៀវ សំផន និង អៀង សារី។ អ្នកទាំងបីនេះបានទៅកាន់ស្ថានទូតសាធារណរដ្ឋប្រជាមានិតចិនក្នុងភ្នំពេញ ដើម្បីសម្តែងការចូលរួមរំលែកទុក្ខដ៏ស្មោះស្ម័គ្រចំពោះមរណភាពរបស់ឯកឧត្តម កាង សេង អនុប្រធានគណៈមជ្ឈិមបក្សកុម្មុយនីស្តចិន។ ឯកឧត្តម កាង សេង បានទទួលមរណភាពក្នុងក្រុងប៉េកាំង នៅថ្ងៃ១៦ ខែធ្នូ ក្នុងជន្មាយុ៧៧ឆ្នាំ។ សម្តេចនាយករដ្ឋមន្ត្រី និងសមមិត្តបក្សនាយករដ្ឋមន្ត្រីបានប្រគល់ជូននូវកម្រងផ្កាជាមួយនឹងពាក្យពេចន៍ដូចតទៅ៖ “សូមចូលរួមរំលែកទុក្ខអស់ពីដួងចិត្ត និងជ្រាលជ្រៅបំផុតចំពោះមរណភាពយ៉ាងក្រៀមក្រំ របស់ឯកឧត្តម កាង សេង ដែលជានិមិត្តរូបបដិវត្តន៍ចិនដ៏ឆ្នើម និងជាសមមិត្តរួមអាវុធយ៉ាងជិតស្និទ្ធបំផុតរបស់ប្រជាជនកម្ពុជា”។ បាទនេះជាករណីមួយដែលបង្ហាញអំពីឥទ្ធិពលមួយចំនួនរបស់លោក កាង សេង។ បើតាមយោបល់របស់លោកនោះ តើមានអ្នកណាផ្សេងទៀតដែលក្រោយមកនោះក្លាយទៅជាបនទាំងបួននោះ? តើលោកស្គាល់ឈ្មោះ ហ្សង់ ស៊ុនកែវ ទេ?

[១៥:៤២:៥២]

**ឆៈ** ឆាង ឈុនឆាវ ហ្នឹងជាឧបនាយករដ្ឋមន្ត្រី។ គាត់ជាអ្នកមានឥទ្ធិពលខ្លាំងណាស់។ គាត់មានការទទួលការពារពី កាង សេង។ គាត់បានធ្វើទស្សនកិច្ចជាដំបូងនៅកម្ពុជាប្រជាធិបតេយ្យនៅសម័យនោះ។ បើលោកចៅក្រមសួរខ្ញុំថានៅពេលណានោះ គឺថាខ្ញុំគិតថានៅក្នុងសៀវភៅខ្ញុំ ខ្ញុំសរសេរហើយ ប្រហែលជានៅឆ្នាំ៧៦, ៧៥។ នេះគឺជាទស្សនកិច្ចដ៏ធំមួយរបស់មេដឹកនាំចិននៅកម្ពុជា យើងមានរូបភាពដែលបង្ហាញថាគាត់ទៅទស្សនកិច្ចនៅអង្គរវត្តជាមួយនឹងប៉ុល ពត ផ្ទាល់តែម្តង។ ហើយក្នុងនោះ ក៏មាន អៀង សារី ដែលជាអ្នកអមគណៈប្រតិភូចិនផងដែរ។ ឆាង ឈុនឆាវ *(តាមសូរស័ព្ទ)* នោះគឺជាមនុស្សដែលសំខាន់ណាស់នៅក្នុងទំនាក់ទំនងរវាងកម្ពុជា និងចិន។ នៅពេលដែលគាត់ត្រូវបានទម្លាក់ពីតំណែងនិងចាប់ខ្លួននោះ គឺមានការស្រឡាំងកាំងយ៉ាងខ្លាំងនៅក្នុងទីក្រុងភ្នំពេញនៅប្រទេសកម្ពុជា។

[១៥:៤៤:០០]

**សៈ** ដូច្នេះមានទស្សនកិច្ចផ្លូវការដែលមានបង្ហាញជារូបថត ហើយយើងមានមនុស្សម្នាក់ផងដែរ ដែលមកទស្សនកិច្ចសម្ងាត់ ដែលទស្សនកិច្ចសម្ងាត់នេះគឺថាប្រព្រឹត្តទៅនៅក្រោយថ្ងៃ១៧ មេសា ៧៥ បន្តិច។ ហើយនៅពេលហ្នឹងគឺ កាំង ហ្កេកអ៊ាវ ហៅឌុច នោះបានឆ្លើយថា គាត់ទទួលការសម្ងាត់ពីគ្រូចិនម្នាក់ដែលបានគាត់ជួបនៅប៉េកាំង។ ហើយម្នាក់ហ្នឹងបានប្រាប់គាត់ថា ឆាង ឈុនឈាវ *(តាមសូរស័ព្ទ)* នេះប្រហែលជាមកជាសម្ងាត់មកទស្សនកិច្ចកម្ពុជាជាសម្ងាត់នៅឆ្នាំ៧៥។ គឺឯកសារE3/441, ERN ជាភាសាបារាំង 00188763, អង់គ្លេស 00270559។ ខ្ញុំសូមអភ័យទោសផង ខ្ញុំអត់មានលេខ ERN ជាភាសាខ្មែរទេ។ នេះគឺជាព័ត៌មានមួយដែលមិនស៊ីសង្វាក់គ្នាជាមួយនឹងព័ត៌មានផ្សេងទៀតទេ ក៏ប៉ុន្តែតើលោកអាចនិយាយបានទេអំពីទស្សនកិច្ចសម្ងាត់របស់ ឆាង ឈុនឈាវ នៅកម្ពុជានេះ? និយាយបានទេ អំពីទស្សនកិច្ចសម្ងាត់របស់ ឆាង ឈុនឈាវ នៅកម្ពុជានេះ?

[១៥:៤៥:១៧]

**ឆៈ** ខ្ញុំគិតថាប្រហែលជាមានបញ្ហា មានកំហុស។ វាជាការលំបាកណាស់ក្នុងការកំណត់កាលបរិច្ឆេទនៃទស្សនកិច្ចរបស់ ឆាង ឈុនឈាវ នេះ។ នេះជាទស្សនកិច្ចសម្ងាត់មិនមានការផ្សព្វផ្សាយរូបថតជាផ្លូវការឲ្យយើងឃើញនោះទេ មិនមានការប្រកាសផ្សាយទាំងនៅស្រុកចិន ទាំងនៅកម្ពុជាតាមរយៈប្រព័ន្ធវេបសាយ ឬតាមរយៈវិទ្យុ មិនមានការផ្សាយអីទាំងអស់។ ក៏ប៉ុន្តែខ្ញុំអាចកំណត់ថា ការ

ទស្សនកិច្ចនោះប្រហែលនៅខែមេសា ឆ្នាំ៧៦ ពីព្រោះថាខ្ញុំមានប្រភពមួយនៅប៉េកាំង ដែលបានពន្យល់ប្រាប់ខ្ញុំថា ឆាំង ឈុនឆាវ នេះគឺពិតជាត្រឡប់ចូលមកប៉េកាំងវិញនៅចុងខែមេសា។ ដូច្នេះវាអាចកំណត់បានថា គាត់មកទស្សនកិច្ចនៅកម្ពុជាជាសម្ងាត់ហ្នឹងប្រហែលជានៅពាក់កណ្ដាលខែមេសា ឆ្នាំ៧៦។

មានសក្ខីកម្មផ្សេងទៀត ដូចជានៅមន្ទីរប-១ គឺក្រសួងការបរទេសកម្ពុជានុំង គឺបញ្ជាក់ថាមានការធ្វើជាប៉ាន់ណូ បង្ហាញពីការស្វាគមន៍ដែលគេមានដាក់ថា "ស្វាគមន៍លោក ឆាង ឈុនឆាវ" ជាដើមហ្នឹង។ ដូច្នេះវាជាប្រភពមួយហើយដែលអាចបង្ហាញឲ្យឃើញថា នៅប្រហែលជានៅចុង៧៥ ឬដើម៧៦ហ្នឹង គាត់បានមកទស្សនកិច្ច។ ដូច្នេះប្រហែលជាអាចមានការច្រឡំ -- ដូច្នេះខ្ញុំគិតថា បើគិតមើលឡើងវិញទៅប្រហែលជានៅខែមេសា ឆ្នាំ៧៦។

[១៥:៤៦:៤៤]

**ស៖** ទោះជាយ៉ាងណាក៏ដោយគាត់មកកម្ពុជាម្ដង ហើយគាត់បានជួបបុគ្គលសំខាន់ៗនៅកម្ពុជា។ ឥឡូវនេះយើងត្រឡប់មកឆ្នាំសំខាន់ គឺឆ្នាំ១៩៧៥ គឺពាក់ព័ន្ធទៅនឹងជំនួបរវាងមេដឹកនាំចិន និងមេដឹកនាំបដិវត្តន៍ខ្មែរក្រហម។ ជាបឋមពាក់ព័ន្ធទៅនឹង អៀង សារី លោកបានសរសេរនៅក្នុងសៀវភៅរបស់លោកថា "មុនចូលមកកម្ពុជាវិញ អៀង សារី បានឆ្លងកាត់តាមទីក្រុងប៉េកាំង"។ តើលោកអាចជម្រាបតុលាការបានទេថា ការឆ្លងកាត់ទីក្រុងប៉េកាំងហ្នឹងមានមូលហេតុពិសេសជាក់លាក់ណាមួយទេ? ហើយលទ្ធផលនៃការឆ្លងកាត់តាមរយៈទីក្រុងប៉េកាំងហ្នឹងយ៉ាងម៉េចដែរ?

**ឆ៖** ខ្ញុំត្រូវពិនិត្យផ្ទៀងផ្ទាត់មើលសិន ព្រោះខ្ញុំភ្លេចទៅហើយ។ សូមទោសផងលោកចៅក្រម ប្រសិនបើលោកចៅក្រមអាចតម្រង់ទិសខ្ញុំបន្តិចប្រហែលជាខ្ញុំអាចនឹកឃើញបានប្រសើរជាងនេះ។

**ស៖** តើនៅនុំងមានការគ្រោងទទួលបានពីចិននូវជំនួយសំខាន់ៗសម្រាប់ខ្មែរក្រហម ឧទាហរណ៍ដូចជា ជំនួយយោធា គឺថាមិនឆ្លងកាត់តាមវៀតណាមទៀតនោះ គឺថាជំនួយគឺអាចឆ្លងកាត់តាមកំពង់ផែកំពង់សោមផ្ទាល់តែម្ដង។

[១៥:៤៨:១៩]

**ឆ៖** បាទ ពិតណាស់ ចំពោះខ្ញុំនោះគឺខ្ញុំអត់ចាំថ្ងៃខែទេ ហើយវាដូចជាស្មុគស្មាញ។ អៀង សារី ទៅប៉េកាំង ហើយគាត់ត្រឡប់មកវិញ ហើយពេលនោះមានឈ្មោះ មានមួយទៀត គឺដែលជាអនុប្រធានការិយាល័យទំនាក់ទំនងបរទេសនៃបក្សកុម្មុយនីស្តចិន គឺមួយសប្ដាហ៍ក្រោយថ្ងៃ១៧ មេសា គឺនេះហើយ

គឺជាយន្តហោះទី១ ដែលហោះចេញពីប៉េកាំងមកចុះនៅទីក្រុងភ្នំពេញ។ តាំងពីពេលហ្នឹងមកគឺមានការចាប់ផ្តើមការចរចាគ្នា ហើយនៅចុងការចរចាគ្នានោះ គឺនៅប៉េកាំង នៅពេល ប៉ុល ពត ទៅជួបម៉ៅ សេទុង ហើយនៅពេលនោះគឺថាមានការជជែកគ្នាលម្អិតពាក់ព័ន្ធទៅនឹងជំនួយចិនមកកម្ពុជា។ នេះគឺប្រហែលជានៅឆ្នាំ៧៥ នៅរដូវរំហើយ។

**ស៖** លោកបានបញ្ជាក់អំពីការជួបគ្នារវាង ប៉ុល ពត និង ម៉ៅ សេទុង ដែលបានពិភាក្សាគ្នាអំពីវិសាលភាពនៃជំនួយរបស់ចិនមកដល់កម្ពុជា។ លោកបានបញ្ជាក់ថានៅខែកញ្ញា ឆ្នាំ៧៥ មែនទេ? ពីព្រោះខ្ញុំឃើញថាមានកំណត់សម្គាល់មួយចំនួនដែលនិយាយអំពីទស្សនកិច្ចនៅខែឧសភា ឬក៏ខែមិថុនានៅឆ្នាំ១៩៧៥។ តើលោកអាចបញ្ជាក់ពីចំណុចនេះបានទេ?

[១៥:៤៩:៥៤]

**ឆ៖** បាទ ត្រឹមហើយលោកចៅក្រមគឺខែមិថុនា ឆ្នាំ៧៥ គឺខែនុ៎ងហើយនៅខែមិថុនា។ ការជួបគ្នាជាមួយ ម៉ៅ សេទុង នោះគឺជាការចរចាគ្នាពិភាក្សាគ្នាអំពីបញ្ហាមនោគមន៍វិជ្ជា និងទស្សនវិជ្ជាធំៗ។ ហើយព័ត៌មានលម្អិតនោះ គឺមានជាមួយនឹង តេង ស៊ាវពីង ដែលកាលពេលនុ៎ងនោះ គាត់គឺជាអនុប្រធានបក្សចិន ហើយនិងគាត់ក្លាយជាអ្នកស្នងតំណែងពី ម៉ៅ សេទុង។ ហើយក្រោយមកនោះគាត់ក៏ត្រូវបានគេដកទម្លាក់ចេញពីតំណែងដែរ។

**ស៖** ការជួបគ្នាផ្សេងទៀតនោះ ក្នុងរយៈពេលហ្នឹងដូចជាសារសំខាន់ណាស់។ ឧទាហរណ៍ ដូចជាជំនួបរវាង ម៉ៅ សេទុង ហើយនិង ជូ អេនឡាយ ជាពិសេសនោះគឺជំនួបរវាងសម្តេច សីហនុ និង ខៀវ សំផន គឺប្រហែលជានៅខែសីហា ឆ្នាំ១៩៧៥ យើងដឹងថាសម្តេច សីហនុ នៅប៉េកាំងនៅឡើយ ហើយ ខៀវ សំផន នោះគាត់បានធ្វើដំណើរទៅប៉េកាំងដើម្បីទៅជួបសម្តេច សីហនុ ដើម្បីបញ្ចុះបញ្ចូលគ្នាឲ្យសម្តេច សីហនុ យាងត្រឡប់មកកម្ពុជាវិញ។ តើលោកអាចនិយាយអំពីជំនួបនេះបានទេ? លោកបាននិយាយយោងទៅដល់កំណត់ហេតុរបស់កិច្ចប្រជុំដែលលោកអាចទទួលបាន ដែលមាននៅក្នុងបណ្ណសារដ្ឋានមជ្ឈិមរបស់ចិននៅទីក្រុងប៉េកាំង។ ដូច្នេះយើងពិបាកចូលទៅមើលនៅបណ្ណសារដ្ឋានរបស់ចិននេះណាស់។ ដូច្នេះហើយ ខ្ញុំពិតជាចង់បានឯកសារនេះ។

[១៥:៥១:៤៨]

**ឆ៖** មិនមែនតែលោកចៅក្រមទេដែលលំបាកនោះ ខ្ញុំហ្នឹងក៏លំបាកដែរ។ ខ្ញុំអត់មានលទ្ធភាពអីទៅចូលមើលនៅបណ្ណសារដ្ឋានរបស់ចិនទេ។ អ្វីដែលខ្ញុំអាចធ្វើបាននោះ គឺថាខ្ញុំអាចនិយាយជាមួយនឹងកម្មាភិបាលចិនដែលបានឃើញឯកសារនេះ។ ការពិសន្ទនាគ្នាជាមួយនឹង ជូ អេនឡាយ នោះគឺថាយើងដឹងតិចតួចណាស់ ហើយមិនដឹងថាគាត់បានពិភាក្សាអីខ្លះនោះទេ។ ក៏ប៉ុន្តែយើងអាចដឹងច្រើនអំពីការជួបជុំគ្នារវាង ខៀវ សំផន, អៀង សារី, និង ម៉ៅ សេទុង។ ម៉ៅ សេទុង បានសូមឲ្យអ្នកទាំងពីរហ្នឹងគោរពសម្តេច សីហនុ និង ប៉ែន នុត។ គឺថាសូមឲ្យ អៀង សារី និង ខៀវ សំផន ហ្នឹងធ្វើម៉េចកុំឲ្យគាត់ទៅធ្វើស្រែធ្វើអីដូចអ្នកផ្សេងដូចជាប្រជាជនផ្សេងទៀតនោះ។ ហើយលោក ខៀវ សំផន ពេលនោះក៏បានសន្យាថាគាត់នឹងគោរពសម្តេច សីហនុ ណាស់ នៅពេលដែលសម្តេច សីហនុ យាងទៅត្រឡប់ហ្នឹង គាត់នឹងគោរព សីហនុ។ ក៏ប៉ុន្តែមានរយៈពេលនៃការអល់ឯកគ្នាសំខាន់ៗ មុនពេលដែលសម្តេច សីហនុ យាងត្រឡប់មកកម្ពុជាវិញ។

**ស៖** ដូច្នេះយើងអាចបាននិយាយថា នៅក្នុងចំណោមមជ្ឈដ្ឋានមេដឹកនាំចិន គឺមានមេដឹកនាំមួយផ្នែកនោះគឺថាព្យាយាមធ្វើយ៉ាងម៉េច ធ្វើថាឲ្យមេដឹកនាំខ្មែរក្រហមនុំងមានប្រកាន់នូវភាពកណ្តាល គឺថាកុំឲ្យតឹងតែងពេក។ ហើយឲ្យគឺថាឲ្យកាន់ មិនមែនថាឲ្យកាន់របបម៉ៅនិយមទេ ក៏ប៉ុន្តែថាធ្វើម៉េចឲ្យគោរពទៅតាមបដិវត្តន៍ខ្មែរក្រហមដែលបានបង្កើតឡើងនោះ។

[១៥:៥៣:៣៦]

**ឆ៖** ពិតណាស់លោកចៅក្រម គឺមាន ជូ អេនឡាយ ផ្ទាល់តែម្តង ដែលគាត់មានការព្រួយបារម្ភនិងចំពោះអ្វីដែលនឹងកើតឡើងនៅកម្ពុជា។ គាត់បានប្រាប់លោក ខៀវ សំផន ថាដាច់ខាតនោះថា មិនត្រូវលុបចោលនូវភាពអស្ចារ្យ ភាពមហារភ្ជីស្វាង លោតផ្លោះរបស់ចិនទេ។ គឺគាត់យល់ថាជាបញ្ហាមហន្តរាយធ្ងន់ធ្ងរ។ ដូច្នេះត្រូវធ្វើម៉េចកុំឲ្យតឹងតែងពេក ត្រូវប្រកាន់ផ្លូវកណ្តាល។ នេះជាសម័យមួយដែលនៅពេលនោះ គឺថានៅពេលដែលខ្មែរក្រហម គឺថាគាត់ក្រអឺតក្រទម គឺរបៀបថា អឿនៅពេលដែលខ្លួនឯងទទួលបានជ័យជម្នះហ្នឹង គឺថាខ្លួនឯងក្អេងក្អាងណាស់ អត់ចង់ស្តាប់ដំបូន្មានរបស់ម៉ៅគេទេ។ ហើយនៅពេលដែល ម៉ៅ បានជួប ប៉ុល ពត នោះ ការប្រជុំគ្នាហ្នឹង គឺជាការប្រជុំណែនាំ ហើយមានការនិយាយចេញក្រៅប្រធានបទ គឺថាមានបញ្ជាក់ថាអ្នកឯងមិនបានដើរតាមមាគ៌ាត្រឹមត្រូវទេ អ្នកឯងត្រូវ

ប្រកាន់ផ្លូវកណ្ដាល។ ដូច្នេះហើយវាមានការងាកចេញទាំងស្រុងតែម្ដង។ ពេលនុ៎ងម៉ៅគាត់មានការភ្ញាក់ផ្អើលទៅនឹងអ្វីដែលខ្មែរក្រហមបានធ្វើ ក៏ប៉ុន្តែទន្ទឹមនឹងនុ៎ងគាត់ក៏មានការព្រួយបារម្ភដែរ។

**ស៖** តើយើងអាចនិយាយបានថា ក្នុងទស្សនវិស័យរបស់មេដឹកនាំនោះ សម្ដេច សីហនុ មកយាងមកកម្ពុជាវិញនេះ គឺថាត្រូវធ្វើយ៉ាងម៉េចឱ្យបដិវត្តន៍នុ៎ងមានភាពធូរស្រាល កុំឱ្យមានភាពតឹងតែងពេក។ ហេតុអីបានជាមេដឹកនាំខ្មែរក្រហម -- ចិននឹងព្យាយាមធ្វើម៉េចដើម្បីឱ្យសម្ដេច សីហនុ យាងមកកម្ពុជាវិញហ្នឹងក្នុងលក្ខខណ្ឌមួយដ៏ល្អប្រសើរនោះ?

[១៥:៥៥:៤៣]

**ឆ៖** នេះ គឺជាសំណួរមួយដ៏លំបាកណាស់។ ខ្ញុំគិតថា យើងក៏មិនដឹងថាតើសម្ដេច សីហនុ នុ៎ងគាត់ទទួលរងនៅឥទ្ធិពលរបស់តរិយាបថខ្មែរក្រហម ឬក៏អត់នោះទេ។ ព្រះអង្គគឺពិតជាបានយាងមកមែន ហើយព្រះអង្គជាប្រមុខរដ្ឋ ដូច្នេះវាផ្ដល់ជារូបភាពមួយទៀតនៃរបបកម្ពុជាប្រជាធិតេយ្យ។ ហើយពួកខ្មែរ -- ពួកចិននុ៎ង គឺថាមានភាពជាក់ស្ដែងណាស់ គឺថា គិតថាមានការប្រែប្រួលដោយសារតែសម្ដេច សីហនុ ហ្នឹងហើយ។

**ស៖** នៅសម័យនោះ មានពាក្យស្លោកមួយដែលយើងស្ដាប់ឮនៅស្ទើរតែគ្រប់ទីកន្លែង គឺថា "ឯករាជ្យម្ចាស់ការ ខ្លួនទីពឹងខ្លួន"។ ដូច្នេះយើងឃើញថា មានការប្ដេជ្ញាចិត្តយ៉ាងខ្លាំងរបស់មេដឹកនាំខ្មែរក្រហមដើម្បីការពារឯករាជ្យភាពរបស់ខ្លួន។ ក្នុងនោះយើងឃើញមានចំពោះចិនផងដែរ ពាក់ព័ន្ធទៅនឹងបញ្ហាឯករាជ្យ ម្ចាស់ការ ខ្លួនទីពឹងខ្លួននោះ?

**ឆ៖** បាទ ពិតណាស់។ គាត់ចង់ -- បាទ គាត់មិនចង់ទៅជាគោលដៅរបស់ចិននោះទេ។ គាត់ចង់កើត -- គាត់ចង់នៅក្បែរចិន ក៏ប៉ុន្តែគាត់មិនចង់ក្លាយទៅជា គ្រាន់តែជាមនុស្សរាយរងរបស់ចិនទេ។

ខ្ញុំអាចត្រឡប់មកក្រោយបន្តិចចំពោះសម្ដេច សីហនុ គឺថាមានមូលហេតុមួយផ្សេងទៀត ដែលចិនចង់យាងត្រឡប់មកវិញនេះ គឺថាបើសិនជាគាត់នៅក្រៅពីខ្មែរក្រហមនោះ គឺថាគាត់មិនមានឱកាសក្នុងការកាន់តួនាទីសំខាន់នៅកម្ពុជាទេ។ ដូច្នេះគាត់ត្រូវតែ -- ព្រះអង្គត្រូវតែយាងមកដើម្បីទទួលបាននូវឱកាសក្នុងការដឹកនាំនយោបាយនៅពេលអនាគតនោះ។

[១៥:៥៨:១២]

**ស៖** ជំនួយរបស់ចិននោះគឺជាជំនួយសំខាន់ ដែលយើងនិយាយថាជាជំនួយឥតលក្ខខណ្ឌ ពីព្រោះថាយើងឃើញមានភាពឡើងចុះរវាងទំនាក់ទំនងរវាងកម្ពុជា ហើយនិងចិន។ ហើយជំនួយទាំងអស់នេះជាជំនួយបច្ចេកទេស យោធា សេដ្ឋកិច្ច ដើម្បីបង្កើតប្រព័ន្ធធនាគារ ដើម្បីអាចលក់ផលិតផលកម្ពុជាទៅក្រៅប្រទេស។ តើនៅពេលណាមួយនោះ មានសំណើសុំជំនួយស្បៀងអាហារដែរឬទេ ពីសំណាក់មេដឹកនាំខ្មែរក្រហមចំពោះមេដឹកនាំនៃសាធារណរដ្ឋចិននោះ?

**ឆ៖** គឺខ្ញុំអត់ដឹងទេ ចំពោះចំណុចនេះ។

**ស៖** ឥឡូវនេះ ខ្ញុំចង់និយាយអំពីបុគ្គលម្នាក់ទៀតដែលមានតួនាទីសំខាន់ ដែលឈ្មោះ ចិន ជុងគី -- យុង យី *(តាមសូរស័ព្ទ)* ដែលគាត់នុំងគឺថា បានទស្សនកិច្ចកងកសិកម្មគំរូ នៅឃុំតាចៃ ចាប់ពីដើមដំបូងរហូតដល់ចុងក្រោយហ្នឹង គឺថាលោកបានដឹង។ ដូច្នេះ ប៉ុល ពត ប្រហែលជាមានទំនាក់ទំនងជាមួយនឹង ចិន យុងគី ហៅ ចិន យុងយី នេះ តើលោកអាចនិយាយអំពីចំណុចនេះបានទេ?

[១៦:០០:០៣]

**ឆ៖** ចិន យុងគី គឺជាកសិករគំរូដែលទទួលបានជំនួយពីរដ្ឋចិនជាច្រើន ដើម្បីកសាងជាឃុំគំរូមួយ។ គឺគាត់ជាមនុស្សគំរូ ហើយក្រោយមកគាត់ក្លាយជាសមាជិកការិយ៍យនយោបាយ។ គាត់មានទំនាក់ទំនងជាមួយនឹងពួកឆ្វេងនិយម ដូចជា ឆាង ឈុនឆាវ។ ហើយគាត់បានទស្សនកិច្ច១៥ថ្ងៃនៅប្រទេសកម្ពុជា។ ហើយគាត់គិតថារបបខ្មែរក្រហមនោះល្អ។ ក៏ប៉ុន្តែមិនមែនជាមនុស្សសំខាន់នោះទេ គាត់ជានិមិត្តរូបនៃនយោបាយកសិកម្មរបស់ចិន។ គាត់បានមកប្រទេសកម្ពុជា ហើយបន្ទាប់មកគាត់ត្រឡប់ទៅវិញដោយគ្មានលទ្ធផលអ្វីទាំងអស់។

**ស៖** អម្បាញ់មិញនេះលោកនិយាយថា គាត់ជាមនុស្សគំរូពីព្រោះថាឃុំតាចៃ នេះគឺជាឃុំគំរូនៅចិន។ ដូច្នេះនៅចិនហ្នឹង នៅកម្ពុជាប្រជាធិបតេយ្យហ្នឹងក៏គេនិយាយពីចំណុចនេះច្រើនដែរ។ ដូច្នេះតើតួនាទីនៃភាពគំរូរបស់គាត់នៅក្នុងការរៀបចំរចនាសម្ព័ន្ធសហករណ៍នេះយ៉ាងដូចម្តេចដែរ? តើគេរៀបចំនុំងតាមគំរូរបស់គាត់ ឬក៏យ៉ាងម៉េច តើលោកមានដឹងពីចំណុចនេះទេ?

[១៦:០១:៤១]

**ឆ៖** បាទត្រឹមត្រូវហើយលោកចៅក្រម។ នៅកម្ពុជាគឺគាត់ជាមនុស្សសំខាន់ណាស់។ គាត់គឺជាការពិសោធ -- គាត់តំណាងឲ្យការពិសោធកសិកម្មដ៏ជោគជ័យ។ បាទ ពិតណាស់គឺថាវាអាចមាន

ឥទ្ធិពលដល់កម្ពុជា គឺពាក់ព័ន្ធនឹងការបង្កើតសហករណ៍ហ្នឹង។ ក៏ប៉ុន្តែខ្ញុំមើលទៅថា ដូចមិនមានអ្វីផ្លាស់ប្តូរទេ ក្រោយពីការទស្សនកិច្ចរបស់ ចិន យុងគី នោះ។ គាត់មក គាត់សរសើរកម្ពុជាថាអីចេះអីចឹង។ ហើយដល់ពេលគាត់ត្រឡប់ទៅវិញ យើងអត់មានឃើញប្រែប្រួលទេនៅកម្ពុជា។

**ស៖** ទោះជាយ៉ាងណាក៏ដោយនោះ គឺថាគាត់បានសរសើរចំពោះស្នាដៃបដិវត្តន៍នៅកម្ពុជា តើអីចឹងមែនទេ?

**ឆ៖** បាទពិតណាស់។ គឺថានៅទីនេះ គឺមើលទៅ គឺអីចឹង។

**ស៖** អម្បាញ់មិញនេះ យើងនិយាយអំពីបដិវត្តន៍វប្បធម៌ តើមានឯកសារកម្ពុជាប្រជាធិបតេយ្យណាខ្លះ ដែលនិយាយអំពីបដិវត្តន៍វប្បធម៌នេះ? តើបដិវត្តន៍វប្បធម៌នេះអាចជះឥទ្ធិពលទៅដល់មេដឹកនាំកម្ពុជាប្រជាធិបតេយ្យដែរឬទេ? ហើយបើជះឥទ្ធិពលហ្នឹង នៅពេលណា ហើយក្នុងទិសដៅបែបណា? ហើយដូចជាមាន -- ឧទាហរណ៍ដូចជាបន្ទាប់ពីមានការចាប់ខ្លួនបនទាំងបួន ហើយនិងមានក្រោយពីការស្លាប់របស់មេដឹកនាំចិនជាដើមនោះ?

[១៦:០៣:២៩]

**ឆ៖** បើតាមខ្ញុំដឹងនោះ គឺមានឯកសារមួយដែលនិយាយអំពីបដិវត្តន៍វប្បធម៌ចិន។ នេះគឺជាសារដែលផ្ញើដោយគណៈមជ្ឈិមដែលដឹកនាំដោយប៉ុល ពត នោះទៅប្រជាជនចិន។ សារនោះគឺជាការអួតសរសើរបដិវត្តន៍វប្បធម៌របស់ចិន ក៏ប៉ុន្តែនៅសម័យនោះប្រសិនបើយើងសរសេរទៅឲ្យចិននោះ យើងត្រូវតែនិយាយថាបដិវត្តន៍ហ្នឹង គឺថាជាបដិវត្តន៍ដ៏អស្ចារ្យណាស់។ ដូច្នេះ នេះជាចំណុចសំខាន់ណាស់។ នេះជាវោហាសព្ទដែលថានៅពេលដែលយើងសរសេរទៅចិន ដាច់ខាតត្រូវតែសរសើរចិនហើយ។

**ស៖** ខ្ញុំសូមបន្តទៅនឹងសំណួរមួយចំនួនពាក់ព័ន្ធទៅនឹងប្រភពដែលលោកប្រើប្រាស់ដើម្បីសរសេរសៀវភៅរបស់លោក។ អម្បាញ់មិញនេះ លោកនិយាយអំពីសំបុត្រមួយចំនួន គឺជាសំបុត្រដែលលោកបានរកឃើញនៅក្នុងទម្រង់ជាឌីស ជាឯកសារអេឡិចត្រូនិក ហើយឥឡូវនេះខ្ញុំជឿថាបានផ្តល់ជូនភាគីរួចទៅហើយ។ ឯកសារនោះគឺយើងអាចហៅថាជាឯកសារដើម គឺមកពីបណ្ណសារដ្ឋានវៀតណាម។ ឯកសារទាំងអស់នោះគឺជាឯកសារដែលលោកទទួលបានពីបណ្ណសារដ្ឋានវៀតណាម។ តើលោកអាចពន្យល់បានទេ ថាលោកទទួលបានឯកសារហ្នឹងយ៉ាងម៉េច? នៅពេលដែលលោកទទួលនុ៎ង គឺថាមានជាច្បាប់ដើមជាខ្មែរ ឬបកទៅវៀតណាមរួចទៅហើយ? សូមលោកបញ្ជាក់អំពីឯកសារទាំងនេះ។

E1/189.1

[១៦:០៥:២៥]

**ឆ៖** ឯកសារទាំងអស់នេះត្រូវបានទទួលដោយអ្នកស្រាវជ្រាវអាមេរិកាំងមួយដែលឈ្មោះគ្រីស្តូហ្វោសៀង *(តាមសូរស័ព្ទ)* គាត់ធ្វើនិក្ខេបបទថ្នាក់បណ្ឌិតនៅសាកលវិទ្យាល័យប៉ារីស ដែលនិយាយអំពីសម័យបដិវត្តន៍ខ្មែរក្រហមមុនឆ្នាំ៧៥។ គាត់ទទួលបានការអនុញ្ញាតចូលទៅបណ្ណសារដ្ឋានវៀតណាមរបស់យោធារបស់វៀតណាម។ នៅក្នុងឯកសារទាំងអស់នោះមានឯកសារខ្លះបកពីភាសាខ្មែរទៅជាភាសាវៀតណាម ហើយភាសាដើមនោះគឺជាភាសាខ្មែរដែលចេញមកពីបក្សកុម្មុយនីស្តកម្ពុជា។

ឯកសារខ្លះទៀតនោះជារបាយការណ៍ផ្ទៃក្នុងរបស់វៀតណាម ហើយឯកសារខ្លះនុ៎ងវែងណាស់ដែលនិយាយអំពីការវិវត្តនៃស្ថានភាពនៅកម្ពុជា នៅចន្លោះឆ្នាំ៦៩ រហូតទៅដល់ឆ្នាំ៧៩ នោះ។ គឺថានៅក្នុងនោះមានការបង្ហាញអំពីប្រភពនៅក្នុងប្រភពនៅក្នុងឯកសារកម្ពុជាផ្សេងទៀត ដែលយើងអត់មានបានទទួលទាំងស្រុងទេ។ ដូច្នេះក្នុងនុ៎ងគឺថា មានទំនាក់ទំនងគួរឲ្យចាប់អារម្មណ៍ ក៏ប៉ុន្តែវាមានផ្ទៃផ្ការរវាងបក្សទាំងពីរ ហើយតាមទស្សនៈរបស់វៀតណាមនោះ គឺថាមានការវិវត្តនៃផ្នែកកម្ពុជាកុម្មុយនីស្ត។

[១៦:០៧:២៤]

**សះ** យើងនឹងត្រឡប់មកនិយាយអំពីឯកសារនេះនៅពេលក្រោយ ប្រសិនបើភាគីចង់ដាក់ចូលទៅក្នុងសំណុំរឿងនោះ។ ហើយខ្ញុំនឹងបង្ហាញឯកសារពីរដែលមានសារៈសំខាន់នោះគឺឯកសារ YYYTLM ដែលផ្ញើជូនការិយាល័យគណៈអចិន្ត្រៃយ៍បក្សកុម្មុយនីស្តចិន ដែលគេអួតសរសើរអំពីបដិវត្តន៍វប្បធម៌ ហើយនិងនិយាយអំពីលក្ខខណ្ឌដែលធ្វើឲ្យមានសង្គ្រាមប្រជាជននៅកម្ពុជានោះ។ ហើយឯកសារមួយទៀតនោះ គឺឯកសារដែលមានលេខកូដKK76 ដែលនេះជាសេចក្តីសម្រេចរបស់គណៈមជ្ឈិមរបស់បក្សកុម្មុយនីស្តកម្ពុជា ក៏ប៉ុន្តែខ្ញុំអត់មានពេលនិយាយអំពីបញ្ហានេះទេ។

ខ្ញុំមានចំណុចមួយទៀតពាក់ព័ន្ធទៅនឹងឯកសាររបស់ អ៊ិន សុភាព។ លោកដែលមានចំណងជើងថា "ខៀវ សំផន: *អាំងហ្រ្វង់ខឺអេរ៉េអែល*" *(តាមសូរស័ព្ទ)* ឯកសារនេះលោកបានឃើញហើយ ហើយលោកបានបញ្ជាក់វាពាក់ព័ន្ធទៅនឹងឯកសារដែលលោកបានសរសេរនៅក្នុងសៀវភៅរបស់លោក។ តើអ៊ីចឹងទេ?

**ឆ៖** បាទ ពិតណាស់គឺឯកសារហ្នឹងហើយ ឯកសារតែមួយទេលោកចៅក្រម។

**ស៖** តើលោកអាចនិយាយដោយខ្លីថា នរណាជា អ៊ិន សុភាព? លោកចាំទេ? លោកចាំថាលោកបានសម្ភាសគាត់ដែរឬទេ? តើលោកអាចជម្រាបបានអ្វីខ្លះពាក់ព័ន្ធទៅនឹងឯកសាររបស់ អ៊ិន សុភាព នេះ?

[១៦:០៩:១២]

**ឆ៖** បាទ លោកចៅក្រម អ៊ិន សុភាព នៅប៉ៃលិន។ ប៉ុន្តែឥឡូវខ្ញុំមិនដឹងថាគាត់នៅប៉ៃលិនទៀតអត់ទេ ពេលខ្ញុំជួបគាត់ហ្នឹង គាត់នៅប៉ៃលិន។ បងគាត់ហ្នឹងជាគ្រូពេទ្យ ហើយម្ដាយគាត់ហ្នឹងគឺលោកស្រី អ៊ិន ធុំងជាអ្នកគាំទ្របដិវត្តន៍កម្ពុជា។ ខ្ញុំបានសម្ភាសគាត់ជាច្រើនលើកច្រើនសា ហើយគាត់បានប្រគល់ឯកសារហ្នឹងមកឲ្យខ្ញុំ ខ្ញុំយល់ថាឯកសារនេះវាគួរឲ្យចាប់អារម្មណ៍ណាស់ ជាពិសេសហ្នឹងគឺផ្នែកដំបូង ផ្នែកចាប់ផ្ដើមនៃជីវិតរបស់លោក ខៀវ សំផន នោះ។ ហើយខ្ញុំបានដកស្រង់ឯកសារហ្នឹងជាច្រើននៅក្នុងសៀវភៅរបស់ខ្ញុំ។

**ស៖** គឺថាលោកទទួលបានឯកសារហ្នឹងផ្ទាល់ពីលោក អ៊ិន សុភាព តែម្ដង ហើយលោកអត់មានសង្ស័យចំពោះយថាភាពនៃឯកសារនេះទេ។ តើអ៊ីចឹងមែនទេ?

**ឆ៖** បាទ ពិតណាស់លោកចៅក្រម អត់មានការសង្ស័យទេ។

**ស៖** បាទ ឯកសារហ្នឹងនឹងដាក់ចូលទៅក្នុងសំណុំរឿងហើយ ហើយភាគីនឹងអាចសួរបានពាក់ព័ន្ធទៅនឹងឯកសារនេះ។

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

លោកប្រធាន ខ្ញុំបានចំណាយជាច្រើនដើម្បីសួរទៅដល់លោកជំនាញនេះហើយ។ ឥឡូវនេះសូមអរគុណ។ ខ្ញុំសូមបញ្ចប់។

[១៦:១០:៣៦]

**ប្រធានអង្គជំនុំ៖**

អរគុណលោកចៅក្រម។ អរគុណលោកអ្នកជំនាញ។ ឥឡូវនេះកិច្ចដំណើរការសវនាការសម្រាប់សវនាការថ្ងៃនេះដល់ពេលសម្រាកហើយ។ អង្គជំនុំជម្រះប្រកាសផ្អាកកិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះត្រឹមនេះ សវនាការលើកទៅបន្តធ្វើនៅថ្ងៃស្អែក ថ្ងៃអង្គារ ទី០៧ ខែឧសភា ឆ្នាំ២០១៣

ចាប់ផ្តើមពីម៉ោងប្រាំបួនព្រឹកទៅ។ ហើយសវនាការនៅថ្ងៃស្អែកនេះ អង្គជំនុំជម្រះនឹងធ្វើសវនាការបន្តស្តាប់សក្ខីកម្មសាក្សីអ្នកជំនាញ ហ្វីលីព ស្សូត ដែលនឹងសួរដេញដោលដោយតំណាងសហព្រះរាជអាជ្ញា និងសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី។ សូមភាគីនៃរឿងក្តី និងសាធារណជនជ្រាប។

លោក ហ្វីលីព ស្សូត ការស្តាប់សក្ខីកម្មរបស់លោកនៅមិនទាន់ចប់នៅឡើយទេ។ អង្គជំនុំជម្រះនឹងធ្វើសវនាការបន្តស្តាប់សក្ខីកម្មរបស់លោកនៅថ្ងៃស្អែកនេះទៀត។ ដូច្នេះអង្គជំនុំជម្រះសូមអញ្ជើញលោកមកបន្តផ្តល់សក្ខីកម្មនៅថ្ងៃស្អែកទៀត ដែលនឹងចាប់ផ្តើមពីម៉ោងប្រាំបួនព្រឹក។

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលជាមួយនឹងអង្គភាពគាំពារសាក្សី និងអ្នកជំនាញក្នុងការជូនលោកជំនាញ ហ្វីលីព ស្សូត ត្រឡប់ទៅកាន់ទីកន្លែងដែលគាត់ស្នាក់នៅ និងឲ្យអញ្ជើញគាត់ត្រឡប់មកកាន់កន្លែងផ្តល់សក្ខីកម្មនៅក្នុងបន្ទប់សវនាការនេះវិញនៅព្រឹកថ្ងៃស្អែកនាវេលាម៉ោងប្រាំបួនព្រឹក។

ហើយបង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនជនជាប់ចោទទាំងពីររូបគឺលោក ខៀវ សំផន និងលោក នួន ជា វិលត្រឡប់ទៅកាន់មន្ទីរឃុំឃាំងនៃអ.វ.ត.ក វិញចុះ និងបង្គាប់ឲ្យនាំខ្លួនគាត់ត្រឡប់មកចូលរួមសវនាការនេះវិញនៅថ្ងៃស្អែកឲ្យបានមុខម៉ោងប្រាំបួនព្រឹក។ ដោយឡែកលោក នួន ជា បង្គាប់ឲ្យនាំខ្លួនគាត់មកនៅត្រឹមបន្ទប់ឃុំខ្លួននៅពីក្រោមសាលសវនាការនេះ ដែលមានរៀបចំនូវឧបករណ៍សោតទស្សន៍សម្រាប់គាត់អាចចូលរួមនិងតាមដានកិច្ចដំណើរការសវនាការពីចម្ងាយតាមមធ្យោបាយសោតទស្សន៍។

សម្រាកចុះ៕

**ក្រឡាបញ្ជី៖**

សូមក្រោកឈរ!

*(សវនាការផ្អាកនៅម៉ោង ១៦:១២ នាទី)*